ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត




- គំនិតផ្ដួចផ្ដើមនៃការងារស្ម័គ្រចិត្ត
- ពិធីសម្ពោធចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម
- ឯកអគ្គរដ្ឋទូតហ្វីលីពីនទស្សនកិច្ចតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៦៦ ខែកុម្ភៈ ឆ្នាំ២០២២

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៦៦ ខែកុម្ភៈ ឆ្នាំ២០២២

## មាតិកា

### សំបុត្រ

◆ គំនិតផ្តួចផ្តើមនៃការផ្សារស្ម័គ្រចិត្ត............ ១

### ផ្នែកឯកសារ

◆ គុយ យ៉ុន គណៈយោធាស្រុកត្របែក ...... ២

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ ពិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធ ........ ៥
◆ សឿ ណាន៖ ពិការជើងដោយសារគ្រាប់មីន .. ១០
◆ ឯកអគ្គរដ្ឋទូតហ្វីលីពីនទស្សនកិច្ចតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ....... ១២
◆ ដំណើរទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និងសិទ្ធិមនុស្ស»................................ ១៥
◆ វេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជា . ១៨
◆ រឿងរ៉ាវរបស់ប្រជាជនតាមរយៈវេទិកាប្រវត្តិសាស្ត្រគ្រួសារក្នុងស្រុកអន្លង់វែង .... ២៣
◆ រឿងរ៉ាវរបស់ប្រជាជននៅស្រុកកំពង់ត្របែក.... ២៦
◆ រឿងរ៉ាវរបស់ប្រជាជនដែលឆ្លងកាត់របបខ្មែរក្រហមនៅភូមិថ្មល់កែង ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ...... ៣៨
◆ វេទិកាប្រវត្តិសាស្ត្រគ្រួសារនៅភូមិ មង់ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ..................... ៤៤
◆ ម៉ម រិន៖ ខ្មែរក្រហមធ្វើឲ្យស្ថានភាពគ្រួសារ... ៥៣

### ផ្នែកស្រាវជ្រាវរកគ្រួសារ

#### «ទួលពិឃាដ»

◆ ទណ្ឌកម្មអ្នកទោសកុមារ ................. ៥៨



លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីន និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅទីតាំងរូងលាក់ខ្លួន ប៉ុល ពត នៅក្បាលទន្សោង ស្ថិតនៅលើខ្នងភ្នំដងរែក និងមានចម្ងាយ២៤គីឡូម៉ែត្រពីរង្វង់មូលនៃស្រុកអន្លង់វែង។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, ដា៉រដ្ឋ មេត្តា, មេក វិន, ហ៊ាន ពិសី, សួត វិចិត្រ, មេន នឿន, អេង វណ្ណនីកា, ង៉ាន់ វីន, ដេង ពង្សរ៉ាស៊ី, ឡុង ដានី, គៀត ស្រីឡែន និង ឈុំ រ៉ា, វី លក្ខិណា និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាគ ចាន់សុនិតា **អ្នកបកប្រែ៖** លីម អុិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដា៉រដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង រ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# គំនិតផ្តួចផ្តើមនៃការងារស្ម័គ្រចិត្ត

ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា







អ្នកស្ម័គ្រចិត្តកម្ពុជា ជួបជាមួយចាស់ទុំដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា ជ្រើសរើសយកគំនិតផ្តួចផ្តើមនៃការងារស្ម័គ្រចិត្តហៅថា ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជា ជាផ្នែកនៃកិច្ចខិតខំ ប្រឹងប្រែងដើម្បីកសាងនិរន្តរភាពនៅក្នុងគម្រោងរបស់យើង ដើម្បីគាំទ្រសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាគឺ ជាកម្មវិធីសេវាកម្មស្ម័គ្រចិត្តរបស់យុវវ័យ សម្របសម្រួលដោយមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការផ្តល់ការ គាំទ្រដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ គំនិតផ្តួចផ្តើមនេះគឺយកគំរូពីក្រុមអ្នកស្ម័គ្រចិត្តរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក។ សេវាកម្មអ្នកស្ម័គ្រចិត្តនេះនឹងរួមបញ្ចូលអ្នកស្ម័គ្រចិត្តចំនួន៨០០នាក់ មកពី២៥ខេត្តក្រុងនៃប្រទេសកម្ពុជា។ គោលបំណងនៃ គំនិតផ្តួចផ្តើមនេះគឺដើម្បីធ្វើឲ្យអ្នកស្ម័គ្រចិត្តម្នាក់ៗ សម្របខ្លួននិងធ្វើការជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងគោលបំណង ផ្តល់ជំនួយជាបុគ្គលដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជា គឺមានលក្ខណៈពិសេសមិនត្រឹមតែជួយ ឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទទួលបានជំនួយជាបុគ្គលតែប៉ុណ្ណោះទេ អ្នកស្ម័គ្រចិត្តអាចជួយឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឲ្យទទួលបានការថែរក្សាសុខភាព ហើយយុវជនស្ម័គ្រចិត្តផ្ទាល់នឹងទទួលបានអត្ថប្រយោជន៍និងឱកាសរៀនសូត្រពី អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម លើលពីនេះទៅទៀតដើម្បីបង្ហាញអំពីសេវាកម្មសង្គម ភាពជាអ្នកដឹកនាំ និងការប្តេជ្ញាចិត្តចំពោះប្រទេសជាតិកម្ពុជា។

# គុយ យ៉ុន គណៈយោធាស្រុកត្របែក

ដារ៉ារដ្ឋ មេត្តា



កងយោធាខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំមានឈ្មោះដើម គុយ យ៉ុន និងឈ្មោះក្នុងជួរបដិវត្តន៍ គុយ សារ៉ាន ភេទប្រុស អាយុ៣៦ឆ្នាំ (នៅឆ្នាំ១៩៧៦)។ ខ្ញុំមានស្រុកកំណើតនៅភូមិព្រៃស្វាំង ឃុំពញាលៀង ស្រុកព្រះស្ដេច ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ គុយ យ៉ាន ស្លាប់នៅក្នុងឆ្នាំ១៩៦៨ និងម្ដាយខ្ញុំឈ្មោះ ព្រាំ ប៊ុ។ ខ្ញុំមានបងប្អូនបង្កើតទាំងអស់ចំនួន៨នាក់ និងបានចូលបម្រើបដិវត្តន៍ចំនួន៧នាក់។ បងទី១) គុយ យុន ក្រោយមកធ្វើជាលេខាឃុំរាធរ ស្រុកកោះដ័យ, ទី២) ខ្ញុំ (គុយ យ៉ុន) ទី៣) គុយ ឈន គឺជាបុគ្គលិកវប្បធម៌, ទី៤) គុយ នៅ គឺជាពេទ្យឃុំពញាលៀង ខ, ៥) គុយ នាត នៅអង្គភាពឃុំរាធរ, ៦) គុយ ណា អង្គភាពវប្បធម៌, ៧) គុយ ហ៊ាន ពេទ្យតំបន់២៤ និង ទី៨) ប្អូនពៅរស់នៅជាមួយម្ដាយ។

នៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៥ អង្គការបានរៀបចំឲ្យខ្ញុំមានប្រពន្ធឈ្មោះ ឡុង ខឿន អាយុ២៣ឆ្នាំ គឺប្រជាជននៅស្រុកកោះដ័យ ខេត្តព្រៃវែង។ ប្រពន្ធរបស់ខ្ញុំធ្វើការនៅក្នុងអង្គភាពសេដ្ឋកិច្ច ស្រុកត្របែក ផ្នែកកាត់ដេរ។

នៅពេលដែលខ្ញុំមានអាយុ៥ឆ្នាំ ឪពុកម្ដាយខ្ញុំបានមករស់នៅក្នុងភូមិស្នាយព្រីមដែលជាស្រុកកំណើតខាងម្ដាយ។ មូលហេតុដែលគ្រួសារខ្ញុំមករស់នៅភូមិស្នាយព្រីមវិញដោយសារមានវៀតណាមបះបោរកាប់សម្លាប់ ឆក់ប្លន់ប្រជាជននៅក្នុងភូមិ។ នៅពេលខ្ញុំអាយុ១១ឆ្នាំ គ្រួសារខ្ញុំត្រឡប់មករស់នៅក្នុងភូមិស្វាំងវិញ។ ពេលខ្ញុំមានអាយុ១៦ឆ្នាំ ឪពុកម្ដាយខ្ញុំនាំខ្ញុំមកនៅវត្តថ្មីស្ថិតនៅឃុំពញាលៀង ខ។ ក្រោយមកខ្ញុំបួសជានេនបានរយៈពេល១ឆ្នាំ និងបួសជាភិក្ខុបានរយៈពេល២ឆ្នាំ។ នៅឆ្នាំ១៩៦៧ ខ្ញុំទៅប្រឡងយកសញ្ញាបត្រសាលាបាលីរង នៅក្នុងក្រុងព្រៃវែង ហើយខ្ញុំប្រឡងជាប់និងទទួលបានសញ្ញាបត្រ។ បន្ទាប់ពីប្រឡងរួចខ្ញុំបានមកស្នាក់នៅក្នុងវត្តថ្មីបានរយៈពេល១ខែ ទើបខ្ញុំមករស់នៅវត្តទួលសាំង ស្ថិតនៅក្នុងឃុំកោះរកា ស្រុកពាមជរ ខេត្តព្រៃវែង។

នៅក្នុងឆ្នាំ១៩៦៨ ខ្ញុំបានសឹកនិងមករស់នៅផ្ទះបានរយៈពេល២ខែ។ ដោយជីវភាពគ្រួសារមានការខ្វះខាតខ្ញុំបានមករស់នៅជាមួយប្រជាជនដែលមានផ្ទះនៅក្បែរវត្តទួលសាំង។ គាត់ធ្លាប់រស់នៅជាមួយខ្ញុំកាលខ្ញុំបួសជាសង្ឃ។ ខ្ញុំបានរស់នៅជាមួយគាត់និងធ្វើស្រែចម្ការ ដាំសណ្តែក ល្ង ពោត ដោយមានការជួយពីអ្នកភូមិជិតខាង ដូចជា ផ្តល់ដីស្រែឲ្យធ្វើ ផ្តល់កម្លាំងសត្វគោ និងក្របីឲ្យភ្ជួររាស់។ ក្រោយមកឪពុកមារខ្ញុំឈ្មោះ គុយ សាន់បានទិញមងខ្នាតតូចឲ្យខ្ញុំទុកនេសាទត្រី។ ក្នុងរយៈពេលដែលខ្ញុំប្រកបមុខរបរនេសាទត្រី ខ្ញុំទទួលបានការអប់រំជាបណ្តើរៗពីបងធុច គឺជាលេខាតំបន់២៣ និង បងភន បច្ចុប្បន្នគឺនៅអង្គភាពកសិកម្មតំបន់២៤ ដោយសារបងទាំងពីរនេះរស់នៅភូមិព្រៃស្វាំងជាមួយខ្ញុំ។

នៅខែកុម្ភៈ ឆ្នាំ១៩៦៩ ខ្ញុំចូលបដិវត្តន៍នៅភូមិព្រៃស្វាំង ដោយមានបងភនជាអ្នកនាំចូល និង បងធុច គឺជាអ្នកទទួលស្គាល់។ ក្រោយពីខ្ញុំចូលបដិវត្តន៍ខ្ញុំក៏ចូលនៅក្នុងចលនាយុវជនយុវនារី៣ភូមិ គឺភូមិក្រសាំងទង ភូមិព្រៃស្វាំង និងភូមិទឹកជូរ។ ខ្ញុំមានតួនាទីជាអនុប្រធានសាខាយុវជនឃុំពញាលៀង និងជាទីស្តីការភូមិព្រៃស្វាំង។ នៅខែកុម្ភៈ ឆ្នាំ១៩៧០ ខ្ញុំចូលអង្គការដោយក្លាយជាសមាជិកយុវកកដោយមានសមិត្ត ខាំ សុខ គឺជាអ្នកខ្ទេនាម និងសមមិត្តម៉ុង គឺជាអ្នកទទួលស្គាល់។ ខ្ញុំចូលជាសមាជិកអង្គការបន្តទៀតគឺចូលបក្សនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៧០ នៅអង្គភាពស្រុកត្របែក ដោយមានសមមិត្តសុខសានអ្នកខ្ទេសនាមទី១, សមមិត្តចាន់ថនអ្នកខ្ទេសនាមទី២ និងសមមិត្តជ័យ សារិន គឺជាអ្នកទទួលស្គាល់។

រិន គឺជាលេខាស្រុកកំពង់ត្របែក អប់រំខ្ញុំចាប់តាំងពីឆ្នាំ១៩៧៣ និង១៩៧៤ ដោយមានវិធីពីរយ៉ាងគឺអប់រំស្របច្បាប់ គឺឲ្យខិតខំពង្រឹងកម្លាំងបក្សដើម្បីពង្រីកការអប់រំដឹកនាំក្នុងអង្គភាព ប៉ុន្តែខ្លឹមសារមិនមែនផ្អែកលើមាគ៌ាវណ្ណៈរបស់បក្សដោយជ្រើសរើសយកសភាពមិនល្អ ដូចជា សមាសភាពសេរី ភ្លើតភ្លើនពាក់ព័ន្ធនិន្នាការនយោបាយ ខ្វាំង និងពាលាអាវ៉ាសែ។ មួយផ្នែកទៀតគឺអប់រំចំហរ ដោយលើកឡើងថា នៅប្រទេសវៀតណាមគេមិនខ្វះអ្វីទេ ហើយសម្បូរសប្បាយមានតាំងពីបៀរ អាប៉ោង រហូតដល់វៀតណាមរំដោះ ហើយនៅតែមានល្បែងស៊ីសងស្រីស្រាពេញប្រទេសរបបនាយទុន និងឯកជនក៏មានដែរ។ ឯប្រទេសកម្ពុជាយើងខ្វះខាតច្រើនណាស់។ រិន អប់រំនិងមានវិធានការឲ្យខ្ញុំទៅ ទប់ទឹកទុករហូតធ្វើឲ្យលិចសន្ទូងរលួយសំណាប ដំណាំដាំដុះ លិចផ្ទះសម្បែងរបស់បប្រជាជនមូលដ្ឋាននៅក្នុងឆ្នាំ១៩៧៥។ រិនឲ្យខ្ញុំទៅបើកទឹកបង្ហូរចេញពីប្រឡាយធំឲ្យអស់ពីស្រែហើយគាត់នឹងបញ្ចូលទឹកថ្នាំចូលវិញ ប៉ុន្តែមិនឃើញបញ្ចូលទេ ធ្វើឲ្យសន្ទូងខូចអស់។ រិនចាត់តាំងឲ្យខ្ញុំធ្វើការពិនិត្យតាមដានផ្ទៃក្នុងគណៈស្រុក ហើយរាយការណ៍ឲ្យគាត់វិញ ព្រោះគាត់ខ្លាចក្នុងគណៈស្រុកមានគោលបំណងអ្វីផ្សេងមិនល្អចំពោះគាត់។ រិន មានផែនការឲ្យខ្ញុំដាក់ឈ្លបតាមព្រំដែន រាយចម្រូងបន្តិចបន្តួចត្រង់កន្លែងណាដែលសំខាន់ប៉ុណ្ណោះ ហើយឲ្យខ្ញុំយកមីនចេញពីខ្សែបន្ទាត់ព្រំដែន។ ប្រសិនបើឃើញវៀតណាមចូលមកក្នុងទឹកដីខ្មែរឲ្យខ្ញុំបាញ់យ៉ាងណាធ្វើឲ្យខុសឲ្យខូចនយោបាយបដិវត្តន៍។ រិន ប្រាប់ខ្ញុំឲ្យបន្ថយរបបអាហារនៅក្នុងអង្គភាពដើម្បីសន្សំសំចៃត្រៀមទុកពេលខ្វះខាតទៅថ្ងៃមុខៗ ប៉ុន្តែគោលបំណងយុទ្ធសាស្ត្រគឺដើម្បីឲ្យយុទ្ធជនហូបមិនគ្រប់គ្រាន់និងតឹងតែលើបញ្ហាហូបចុក។ កន្លងមក លើការស្លៀកពាក់ក៏មានការកាត់បន្ថយដែរ គឺខ្ញុំមិនដែលបើកសម្លៀកបំពាក់បានគ្រប់ម្តងណាទេ រហូតដល់មានការលើកឡើងថា «ធ្វើបដិវត្តន៍ស្លៀកពាក់ដូចឈ្លើយសឹក» ហើយអនុញ្ញាតឲ្យមានគ្រួសារបន្តឲ្យមានភាពគ្រឹកគ្រេង រហូតដល់មានសភាពខុសសីលធម៌ទី៦ កើតមានឡើងនៅក្នុងអង្គភាព។ ក្រោយមក ខ្ញុំបានយកទៅអនុវត្តដាក់ស្តែងដោយបានយកទៅផ្សព្វផ្សាយដល់យុទ្ធជន និងកម្មាភិបាលថ្នាក់ក្រោមៗ នៅពេលដែលខាងក្រោមអនុវត្តមិនបាន ខ្ញុំបញ្ចេញអាកប្បកិរិយា អាជ្ញា សម្លុត គម្រាមកំហែង។ ចលនាក្បត់នេះមានឈ្មោះថា ចលនាសេរីនិយមដែលយកសមាសភាពជាប់និន្នាការសង្គមចាស់

ជាមេភូមិ មេកង ប៉ូលីស ទាហាន សមាសភាពពលាអាវ៉ាសែ សន្តិសុខធ្វើជាខ្មាំងបង្កែក។ ចលនាសេរីនិយមនេះបានកើតឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៥ នៅពេលដែលរិនបានអប់រំខ្ញុំហើយដើមកំណើតដំបូងខ្ញុំមិនបានដឹងពិតប្រាកដទេ។ ម៉្យាងទៀតចលនានេះមានការគាំទ្រពីប្រទេសសូវៀត និងប្រទេសវៀតណាមទាំងផ្លូវចិត្ត និងសម្ភារ តាមរយៈគណៈទាក់ទងវៀតណាមឈ្មោះ បៃម៉ាន់។ ជំនួយដែលវៀតណាមបានផ្តល់ឲ្យមកខ្ញុំមានដូចជា អាអ៊ែ១៥ ចំនួន៧៥ដើម, សេកាសេ ចំនួន៤០ដើម, អឹម៣០ ចំនួន៤ដើម, កាំភ្លើងត្បាល់៦០មីលីម៉ែត្រ ចំនួន៣ដើម, បេ៤០ ចំនួន២ដើម, អឹម៧៩ ចំនួន៦ដើម, កា៥៤ និងអាបេ ចំនួន១២ដើម, ថ្នាំពេទ្យ៣ផុង ដោយមានបណ្តោយកន្លះម៉ែត្រ ទទឹក៣ទឹកនិង កម្ពស់៤តឹក។ សម្ភារទាំងអស់នេះគឺយោធាស្រុកកំពង់ត្របែកជាអ្នកទទួលពី ប៉ៃម៉ាន់ នៅនៅផ្សារពាមបន្ទារ នៅខែតុលា ឆ្នាំ១៩៧៥ ហើយអាវុធនិងសម្ភារទាំងអស់នេះយើងមិនទាន់បានយកមកប្រើប្រាស់ទេ។ ផែនការក្បត់នេះមានទិសដៅវាយរំលំរដ្ឋអំណាច ដណ្តើមអំណាចមកគ្រប់គ្រង និងចាត់ចែងតាមសេរីនិយម។ ក្រោយមកខ្ញុំត្រូវអង្គការចាប់ខ្លួន និងយកមកសួរចម្លើយនៅថ្ងៃទី២ ខែតុលា ឆ្នាំ១៩៧៦។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីសេចក្តីកត់ហេតុសួរចម្លើយឯកសារ J00255។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខ ស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ គុយ យ៉ុន ពិតប្រាកដយ៉ាងណានោះទេ?**



យោធាខ្មែរក្រហមនៅសមរភូមិ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ពិធីសម្ពោធចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះ ពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម

**ទូច វណ្ណោត**



ការចាក់បញ្ចាំងវីដេអូរឯកសារ «កុំស្មានបងភ្លេច៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់ អេនរ៉ូល» នៅក្នុងពិធីសម្ពោធចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃព្រហស្បតិ៍ ទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ សមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គាំទ្រដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) និងមជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំពិធីសម្ពោធដាក់ឲ្យប្រើប្រាស់សំណង់ចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម និងការចងចាំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅកណ្ដាលវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ កម្មវិធីពិធីសម្ពោធចេតិយ៍មានការចូលរួមពីលោក សៀង ស៊ីផាន ក្រុមប្រឹក្សាឃុំគគរ, លោកស្រី នែនស៊ី អ៊ីសស្លិក ប្រធានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID), អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំគគរ, លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។

ជាកិច្ចចាប់ផ្ដើម លោក សៀង ស៊ីផាន ក្រុមប្រឹក្សាឃុំគគរ ថ្លែងអំពីសារសំខាន់នៃការចងចាំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ លោក ស៊ីផាន រំឭកអំពីរឿងរ៉ាវដែលខ្លួនបានឆ្លងក្នុងរបបខ្មែរក្រហម រួមមាន ការឃ្លាតឆ្ងាយពីក្រុមគ្រួសារ ការអត់ឃ្លាន និងការកាប់សម្លាប់។ លោក ស៊ីផាន បានបញ្ជាក់ថា «រឿងរ៉ាវរបស់ខ្ញុំ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិចំការសាមសិប គឺត្រូវបានរំឭកនៅ ទីតាំងចេតិយ៍



ពិធីសម្ពោធចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកស្រី នែនស៊ី អ៊ីសស្ទិក ប្រធានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ថ្លែងសុន្ទរកថា នៅក្នុងពិធីសម្ពោធចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ថ្ងៃព្រហស្បតិ៍ ទី១៧ ខែកុម្ភៈ ឆ្នាំ២០២២។

ដែលជាទីតាំងប្រវត្តិសាស្ត្រ»។ លោក ស៊ីផាន បានថ្លែងអំណរគុណដល់ម្ចាស់ជំនួយគឺទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ដែលបានសាងសង់ចេតិយ៍នេះ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានរៀបចំកម្មវិធីពិធីសម្ពោធនេះឡើង។

លោកស្រី នែនស៊ី អ៊ីសស្ទិក ប្រធានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ថ្លែងអំពីការពេញចិត្ត និងគាំទ្រចំពោះការផ្តួចផ្តើមគំនិតក្នុងការសាងសង់ចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហមនៅក្នុងមូលដ្ឋាន។

លោក គុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិគគរ ថ្លែងថា «ថ្ងៃនេះគឺជាថ្ងៃដ៏មានសារសំខាន់ចំពោះខ្ញុំ និងអ្នកភូមិចំការសាមសិប ក្នុងការដាក់សម្ពោធសំណង់ចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម។ ចេតិយ៍នេះគឺជាទីតាំងរំឭកអំពីប្រវត្តិរឿងរ៉ាវអំពីការរស់នៅក្នុងរបបខ្មែរក្រហម និងការចងចាំអំពីរឿងរ៉ាវទុកលំបាករបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ខ្ញុំ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិចំការសាមសិប ឃុំគគរ បន្តចូលរួមផ្តួចផ្តើមគំនិត និងចែករំលែករឿងរ៉ាវរបស់ខ្លួនដែលបានឆ្លងកាត់ទៅដល់ក្មេងជំនាន់ក្រោយដើម្បីទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញ។ ជាចុងក្រោយ ខ្ញុំបាទតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិចំការសាមសិប សូមថ្លែងអំណរគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលបានឧបត្ថម្ភក្នុងការសាងសង់ចេតិយ៍ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងក្រុមការងារដែលបានគាំទ្រដល់គំនិតផ្តួចផ្តើមនេះឲ្យកើតចេញជារូបរាង។ សូមអរគុណដល់អ្នកស្ម័គ្រចិត្តកម្ពុជា ដែលបានចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយកចិត្តទុកដាក់លើសុខភាពរបស់គាត់»។

បន្ទាប់ពីការថ្លែងសុន្ទរកថា គណៈអធិបតី លោកតាលោកយាយ លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សចូលរួមពិធីបង្វិលពពិលនៅជុំវិញចេតិយ៍ចំនួន៣ជុំ បន្ទាប់មកប្រគេនទេយ្យទានដល់ព្រះសង្ឃ និងសូត្រ



ពិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

មន្តបង្សុកូលឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម។

ស្របពេលកម្មវិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំកម្មវិធីមួយចំនួនទៀតដូចខាងក្រោម៖

## ពិព័រណ៍រូបថតអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

នៅវេលាម៉ោង៣:៣០នាទីរសៀល អ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៣ ប្រចាំខេត្តកំពង់ចាម រៀបចំដាក់តាំងពិព័រណ៍រូបថតអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ការចាប់ផ្តើមការសាងសង់សំណង់ចេតិយ និងសកម្មភាពការងាររបស់ស្ម័គ្រចិត្តកម្ពុជាចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅមូលដ្ឋាន។ លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សនៃអនុវិទ្យាល័យគគរ និងអ្នកភូមិជាច្រើនបានចូលទស្សនាពិព័រណ៍រូបថតនេះ។ ខាងក្រោម គឺជាទស្សនៈយល់ឃើញរបស់អ្នកចូលរួម៖

អ៊ំប្រុស **អៀង សារឿន** យល់ថា «ការដាក់តាំងបង្ហាញរឿងរ៉ាវរបស់អ្នកដែលបានឆ្លងកាត់របបខ្មែរក្រហម បានរំឭកដល់ខ្ញុំអំពីការចងចាំមិនអាចបំភ្លេចបាននៃការបាត់បង់សាច់ញាតិ ការលំបាក និងការកាប់សម្លាប់នៅក្នុងរបបខ្មែរក្រហម។ ពិព័រណ៍នេះមានសារសំខាន់ណាស់ដើម្បីឲ្យក្មេងជំនាន់ក្រោយយល់ដឹងអំពីប្រវត្តិសាស្ត្រ»។

លោកយាយ **មុយ ហ៊ាង** លើកឡើងថា «នៅពេលខ្ញុំឃើញរូបភាព និងរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្សេងទៀត ខ្ញុំនឹកឃើញដល់ពេលវេលាលំបាកដែលខ្ញុំធ្វើការនៅកងចល័តនារីនៅក្នុងរបបខ្មែរក្រហម»។

លោកគ្រូ **រស់ បញ្ញា** បង្រៀនមុខវិទ្យាប្រវត្តិសាស្ត្រនៅអនុវិទ្យាល័យភូមិថ្មី បង្ហាញចំណាប់អារម្មណ៍ថា ការដាក់តាំងពិព័រណ៍នៅទីតាំងចេតិយនេះ គឺល្អខ្លាំងណាស់ដើម្បីផ្តល់ការយល់ដឹងពីរឿងរ៉ាវ



លោកស្រី នែនស៊ី អ៊ីសស្ទីក ប្រធានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ចូលរួមពិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងរបបខ្មែរក្រហមបន្ថែមទៀត ដើម្បីរំឭកដល់ប្រជាជនកម្ពុជាដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម។ ខ្ញុំស្នើសុំឲ្យមានការដាក់តាំងពិព័រណ៍បែបនេះបន្តទៀត។ ខ្ញុំនឹងដឹកនាំសិស្សមកធ្វើទស្សនកិច្ចនៅទីតាំងចេតិយនេះនាពេលអនាគត។



មន្ត្រីនគរបាលកំពុងមើលពិព័រណ៍រូបថតនៅក្នុងពិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ការចាក់បញ្ចាំងវីដេអូឯកសារ «កុំស្មានបងភ្លេច៖ ខ្មែរបាត់បង់តន្ត្រី រ៉ក់ អេន រ៉ូល»

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំការចាក់បញ្ចាំងវីដេអូរឯកសារ ចំណងជើងថា **«កុំស្មានបងភ្លេច»** ដែលបង្ហាញអំពីតន្ត្រី វប្បធម៌ និងប្រវត្តិសាស្ត្រកម្ពុជា។ ការបញ្ចាំងវីដេអូឯកសារនេះ គឺធ្វើឡើងនៅកណ្តាលវាលស្រែជិតទីតាំងចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម ដោយមានការចូលរួមទស្សនារបស់អ្នកភូមិចំការសាមសិបជាច្រើន។ ការបញ្ចាំងវីដេអូឯកសារនេះចាប់ផ្តើមពីវេលាម៉ោង៦:៣០នាទីល្ងាចដល់វេលាម៉ោង៨:៣០នាទីយប់។



សិស្សានុសិស្សចូលរួមពិធីសម្ពោធចេតិយរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាដាក់តាំងពិព័រណ៍រូបថតនៅក្នុងពិធីសម្ពោធចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ការដាក់តាំងពិព័រណ៍រូបថតនៅក្នុងពិធីសម្ពោធចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សឿ ណាន ៖ ពិការជើងដោយសារគ្រាប់មីន

**ង៉ាន់ វីន**



សឿ ណាន មានអាយុ៨៤ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិត្រពាំងផ្អែល ឃុំម្រោម ស្រុកអង្គរជ័យ ខេត្តកំពតៗ (ង៉ាន់ វីន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សឿ ណាន មានអាយុ៨៤ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិត្រពាំងផ្អែល ឃុំម្រោម ស្រុកអង្គរជ័យ ខេត្តកំពតៗ ណាន មានប្ដីឈ្មោះ ពៅ ឃីន និងមានកូនប្រុសស្រីចំនួន៦នាក់ ក្នុងនោះមានប្រុសចំនួន៥នាក់ និងស្រីចំនួន១នាក់ ។

កាលពីសម័យ លន់ នល់ ណាន រស់នៅទីក្រុងភ្នំពេញៗ ណាន មានមុខរបរជាអ្នកលក់បន្លែ ចំណែកប្ដីរបស់គាត់គឺជា ទាហាន លន់ នល់ៗ ប្ដីរបស់ ណាន មិនមានប្រាក់ខែច្រើនទេៗ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ណាន និងក្រុមគ្រួសារ ត្រូវយោធាខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅតាមតំបន់ជនបទៗ ណាន បានធ្វើដំណើរមកដល់ស្រុកអង្គរជ័យៗ ដោយសារតែ ណាន ធ្លាប់រស់នៅភ្នំពេញ ទើបអង្គការចាត់ទុក ណាន គឺជាប្រជាជន១៧ មេសាៗ អង្គការដាក់ឲ្យគ្រួសាររបស់ ណាន រស់នៅដោយឡែក ដោយមិនឲ្យរស់នៅលាយឡំជាមួយអ្នកមូលដ្ឋានឡើយៗ ខ្មែរក្រហមបានយកកូនរបស់ ណាន ទាំង៥នាក់ឲ្យទៅរស់នៅក្នុងកងកុមារដោយមិនឲ្យរស់នៅជាមួយម្ដាយៗ អង្គការប្រើ ណាន និងប្រជាជនផ្សេងទៀតឲ្យធ្វើការហួសកម្លាំង និងមិនផ្ដល់អាហារឲ្យហូបចុកគ្រប់គ្រាន់ឡើយៗ ណាន រស់នៅឃ្លាតឆ្ងាយពីក្រុមគ្រួសារបងប្អូន និងភ័យខ្លាចខ្លាចជារៀងរាល់ថ្ងៃៗ ក្រោយពីរបបខ្មែរក្រហមដួលរលំ ណាន បានមក នៅក្នុងស្រុកអង្គរជ័យដដែលជាមួយនឹងក្រុមគ្រួសារៗ

នៅឆ្នាំ១៩៨៣ ពេល ណន ទៅកាប់ឈើនៅភ្នំម្រោមដើម្បីយកមកប្រើប្រាស់ ក៏បានជាន់មីនធ្វើឲ្យគាត់ពិការជើងខាងស្តាំ ដែលពេលនោះគាត់ទើបតែសម្រាលកូនបានរយៈពេល៥ខែតែប៉ុណ្ណោះ។ នៅក្នុងឆ្នាំ១៩៩១ មានមនុស្សបានយកគ្រាប់មីនមកដាក់ក្នុងចម្ការបន្លែរបស់គាត់ ហើយពេលដែលប្តីរបស់ ណន ដើរទៅចម្ការដូចសព្វដង ក៏ជាន់មីនបណ្តាលឲ្យពិការជើងម្ខាងដែរ។ រយៈពេល៥ឆ្នាំក្រោយមក ប្តីរបស់ ណន បានស្លាប់។ ណន រស់នៅជាមួយនឹងកូនៗចំនួន៦នាក់ ហើយបន្ទុកគ្រួសារទាំងអស់ត្រូវធ្លាក់មកលើ ណន។ ណន ខិតខំដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូនៗឲ្យបានរស់រហូតមកដល់សព្វថ្ងៃ។ បច្ចុប្បន្ន ណន កាន់តែមានវ័យចំណាស់ហើយភ្នែករបស់គាត់ក៏ស្រវាំងៗ ណន ដើរដោយប្រើឈើច្រត់ទប់កុំឲ្យដួល។ ណន មានអារម្មណ៍ដូរស្រាលដោយសារគាត់បាននិយាយរឿងរ៉ាវដែលគាត់ធ្លាប់បានឆ្លងកាត់ពីរបបខ្មែរក្រហម។ ដោយសារតែមានការលំបាកពេលក្រោកដើរម្តងៗ ដូច្នេះ ណនបានស្នើសុំរទេះសម្រាប់ជនពិការមួយគ្រឿងដើម្បីសម្រួលដល់ការធ្វើដំណើរ និងស្នើសុំវ៉ែនតាពាក់ព្រោះភ្នែករបស់គាត់មើលមិនច្បាស់ឡើយ។



លោកយាយ សៀ ណន និងអ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តតាកែវឈ្មោះ សៀង កញ្ញា។
(សៀង កញ្ញា/មជ្ឈមណ្ឌលឯកសារកម្ពុជា)




សាលាស្រុកអង្គរជ័យ ខេត្តកំពត។
(ង៉ាន់ វិន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឯកអគ្គរដ្ឋទូតហ្វីលីពីនទស្សនកិច្ចតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង

*មេក ទិន*



លោក ឆាំង យុ ធ្វើបទបង្ហាញទាក់ទងដែនទីនៃស្រុកអន្លង់វែង ដល់លោកជំទាវ ម៉ារី អាមេលី តា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីន និងគណៈប្រតិភូ នៅការិយាល័យរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅជាប់ស្ពានអូរជីក ក្នុងស្រុកអន្លង់វែង។ (ស្នូត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីន, លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ឌិត លី សុខឃាង នាយកជម្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅទីតាំងបូជាសព ប៉ុល ពត។ (ស្នូត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីន និងគណៈប្រតិ បានធ្វើដំណើរទៅទស្សនារូងលាក់ខ្លួន ប៉ុល ពត នៅក្បាលទន្សោងដែលមានទីតាំងស្ថិតនៅលើភ្នំដងរែក និងមានចម្ងាយ២៨គីឡូម៉ែត្រពីរង្វង់មូលនៃស្រុកអន្លង់វែង។ (ឆាំង យុ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាព្រឹកថ្ងៃសៅរ៍ ទី២៦ ខែកុម្ភៈ ឆ្នាំ២០២២នេះ លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីនប្រចាំនៅប្រទេសកម្ពុជា បានធ្វើដំណើរមកកាន់តំបន់ប្រវត្តិសាស្ត្រក្នុងស្រុកអន្លង់វែងជាលើកដំបូង។

នៅវេលាម៉ោង៨:០០នាទីព្រឹក លោកជំទាវឯកអគ្គរដ្ឋទូត និងអនុព័ន្ធយោធាហ្វីលីពីនបានមកដល់ការិយាល័យរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដោយមានការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។

បន្ទាប់មក បណ្ឌិត លី សុខឃាង ធ្វើបទបង្ហាញអំពីផែនការសកម្មភាពរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ផែនទីប្លង់គោលក្នុងស្រុកអន្លង់វែង និងបង្ហាញពីគម្រោងធ្វើរបងតាមបណ្តោយជួរភ្នំដងរែក។

បន្ទាប់មក គណៈប្រតិភូនៃដំណើរទស្សនកិច្ចនេះបានធ្វើដំណើរទៅកាន់ផ្ទះលាក់ខ្លួន ប៉ុល ពត និង ខៀវ សំផន នៅក្បាលទន្ទេរាងដែលមានទីតាំងស្ថិតនៅលើភ្នំដងរែក និងមានចម្ងាយ២៨គីឡូម៉ែត្រពីរផ្ទង់មូលនៃស្រុកអន្លង់វែង។ នៅតាមដងផ្លូវមានទេសភាពស្រស់ត្រកាល ដែលរំលេចដោយព្រៃឈើ និងអាងស្តុបទឹកជាច្រើនកន្លែងដែលបន្សល់ទុកតាំងពីជំនាន់ខ្មែរក្រហម។ ក្រៅពីទេសភាពព្រៃឈើ ក៏ឃើញចម្ការដំណាំពណ៌បៃតងស្រស់ត្រកាលរបស់អ្នកភូមិ និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជានៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។ ផ្ទះលាក់ខ្លួនរបស់ ប៉ុល ពត ត្រូវបានសាងសង់ឡើងក្នុងឆ្នាំ១៩៩៣ បន្ទាប់ពីមេដឹកនាំខ្មែរក្រហមបានជ្រើសរើសទីសំចតចុងក្រោយ និងជាទីតាំងយុទ្ធសាស្ត្រសង្គ្រាមរបស់ខ្លួន។ គណៈប្រតិភូនៃដំណើរទស្សនកិច្ចនេះ ក៏បានធ្វើដំណើរចូលទៅក្នុងរូងលាក់ខ្លួន ប៉ុល ពត។ លោកជំទាវឯកអគ្គរដ្ឋទូត បានស្វែងយល់អំពីប្រវត្តិសាស្ត្រនៃចលនាលាក់ខ្លួន និងសង្គ្រាមទ័ពព្រៃនៅពេលដែលតំបន់អន្លង់វែងបានក្លាយជាទីតាំងចុងក្រោយរបស់ខ្មែរក្រហម។

គណៈប្រតិភូនៃដំណើរទស្សនកិច្ចនេះក៏បានត្រឡប់មកកាន់អតីតផ្ទះប្រជុំរបស់ តាម៉ុក ដែលស្ថិតនៅលើខ្នងភ្នំដងរែក ដែលបច្ចុប្បន្ននេះបានប្រែក្លាយទៅជាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ផ្ទះនេះត្រូវបានសាងសង់ឡើងនៅឆ្នាំ១៩៩៥ សម្រាប់ការជួបប្រជុំមេដឹកនាំខ្មែរក្រហមដូចជា ប៉ុល ពត, ខៀវ សំផន, នួន ជា, សុន សេន និងមេបញ្ជាការកងពលមួយចំនួនទៀត។

ទីតាំងបូជាសព ប៉ុល ពត គឺជាចំណុចទីបីនៃដំណើរទស្សនកិច្ចនេះ។ នៅពេលនោះលោកជំទាវឯកអគ្គរដ្ឋទូតក៏បានស្តាប់ពីការរៀបរាប់ប្រវត្តិសាស្ត្រាប់ចាប់តាំងពីការកាត់ទោស ប៉ុល ពត ដោយ





លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីន ព្រមទាំងគណៈប្រតិភូ និង លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាទស្សនារូងលាក់ខ្លួន ប៉ុល ពត នៅក្បាលទន្ទេរាងដែលមានទីតាំងស្ថិតនៅលើភ្នំដងរែក និងមានចម្ងាយ២៨គីឡូម៉ែត្រពីរផ្ទង់មូលនៃស្រុកអន្លង់វែង។ ។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីន ព្រមទាំងគណៈប្រតិភូ និង លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាទស្សនារូងលាក់ខ្លួន ប៉ុល ពត នៅក្បាលទន្ទេរាងដែលមានទីតាំងស្ថិតនៅលើភ្នំដងរែក និងមានចម្ងាយ២៨គីឡូម៉ែត្រពីរផ្ទង់មូលនៃស្រុកអន្លង់វែង។ ។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)




*លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីន (រូបទី៤រាប់ពីស្តាំ) ព្រមទាំងគណៈប្រតិភូ និង លោក ឆាំង យុ (រូបទី៣រាប់ពីស្តាំ) និងក្រុមការងារនៅខាងមុខការិយាល័យរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅជាប់ស្ពានអូរជីក ក្នុងស្រុកអន្លង់វែង។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

តុលាការប្រជាជន និងគម្រោងសាងសង់ដំបូលផ្ទះប៉ុល ពត ដែលនឹងចាប់ផ្តើមនាពេលខាងមុខទៀតផង។ ការសន្ទនារវាងលោកជំទាវឯកអគ្គរដ្ឋទូតហ្វីលីពីន និងនាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានចំណាយពេលប្រមាណ៣០នាទី។

នៅវេលាម៉ោង ២ រសៀល លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីនប្រចាំនៅប្រទេសកម្ពុជា និងអនុព័ន្ធយោធាហ្វីលីពីន ទៅជួបសម្តែងការគួរសមឯកឧត្តម នាយឧត្តមសេនីយ៍ គន់ គីម ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានសមាគមអតីតយុទ្ធជនកម្ពុជា និងប្រធានអនុគណៈកម្មការសាងសង់ «ស្តូបឈ្នះ ឈ្នះ អន្លង់វែង»។

បន្ទាប់មក គណៈប្រតិភូនៃដំណើរទស្សនកិច្ចនេះបានបន្តដំណើរមកកាន់សារមន្ទីរ តាម៉ុក ឬអតីតផ្ទះតាម៉ុក ដែលបានសាងសង់ឡើងនៅក្នុងឆ្នាំ១៩៩៣។ បច្ចុប្បន្ននេះអតីតផ្ទះតាម៉ុក គឺជាទីកន្លែងដ៏សំខាន់មួយនៅក្នុងស្រុកអន្លង់វែងដែលអាចទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកទស្សនា។

ជាកិច្ចបញ្ចប់លោកជំទាវឯកអគ្គរដ្ឋទូតហ្វីលីពីនរួមទាំងអនុព័ន្ធយោធា សម្តែងនូវសេចក្តីសោមនស្សរីករាយចំពោះការទទួលស្វាគមន៍លោកជំទាវមកកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង។

# ដំណើរទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និងសិទ្ធិមនុស្ស»

ហាន ពិសី




ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងកំពុងនាំសិស្សមកធ្វើទស្សនកិច្ចសិក្សានៅ ទីតាំងប្រវត្តិសាស្ត្រផ្នូរ ប៉ុល ពត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំដំណើរទស្សនកិច្ចសិក្សាស្តីពី «**សន្តិភាព និងសិទ្ធិមនុស្ស**» នៅស្រុកអន្លង់វែង។ ទស្សនកិច្ចសិក្សានេះចាប់ផ្តើមនៅម៉ោង៧:០០ នាទីរសៀល ក្នុងគោលបំណង «លើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងប្រវត្តិសាស្ត្រនៅក្នុងសហគមន៍អន្លង់វែង» ដែលមានយុវជនចំនួន១៦នាក់ (ស្រី១១នាក់ និងប្រុស៥នាក់) មកពីស្រុកត្រពាំងប្រាសាទ៥នាក់ និងស្រុកអន្លង់វែង១១នាក់ បានមកចូលរួម។

ទស្សនកិច្ចសិក្សានេះចាប់ផ្តើមចេញដំណើរពីការិយាល័យកណ្តាលរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងស្ថិតនៅជាប់ស្ពានអូរជីក ឆ្ពោះទៅកាន់អតីតផ្ទះកណ្តាលរបស់ តាម៉ុក នៅលើភ្នំដងរែក ដែលបច្ចុប្បន្នគឺជាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ រថយន្ត

ដែលដឹកក្រុមយុវជនបានធ្វើដំណើរសន្សឹមៗតាមផ្លូវភ្នំដងរែក ដែលមានរុក្ខជាតិតូចធំជាច្រើនដុះអមសងខាងផ្លូវ។ បន្ទាប់មក ក្រុមយុវជន និងក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានទៅដល់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ នៅក្នុងការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងមានការដាក់តាំងពិព័រណ៍រូបភាពជាច្រើនផ្ទាំង ទាក់ទងទៅនឹងដំណើរទស្សនកិច្ចរបស់គណៈប្រតិភូចិនមកកាន់ប្រទេសកម្ពុជា និងរូបភាពពេលកងកម្លាំងខ្មែរក្រហមធ្វើសមាហរណកម្មចុងក្រោយនៅស្រុកអន្លង់វែង នៅឆ្នាំ១៩៩៨។ ក្រៅពីរូបភាពទាំងនេះ នៅមានសៀវភៅជាច្រើនទៀតដែលត្រូវបានដាក់តាំងដោយក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងសម្រាប់ឲ្យភ្ញៀវទស្សនា និងអាន។

មគ្គុទ្ទេសក៍ ចាប់ផ្តើមធ្វើបទបង្ហាញយ៉ាងក្បោះក្បាយទៅកាន់ក្រុមយុវជនឲ្យបានយល់ដឹងអំពីមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ឬអតីតផ្ទះកណ្តាលរបស់ តាម៉ុក ដែលត្រូវបានកសាងឡើងនៅឆ្នាំ១៩៩៥។ ផ្ទះនេះត្រូវបាន តាម៉ុក ទុកសម្រាប់ជាទីកន្លែងប្រជុំសំខាន់ៗ ជាមួយនឹងថ្នាក់ដឹកនាំធំៗរបស់ខ្មែរក្រហម ដូចជា ប៉ុល ពត, ខៀវ សំផន, នួន ជា ព្រមទាំងមេបញ្ជាការកងពលខ្មែរក្រហមផ្សេងៗទៀត។

បច្ចុប្បន្ន មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ឬអតីតផ្ទះកណ្តាលរបស់ តាម៉ុក នេះ គឺជាបណ្ណាល័យ និងជាទីកន្លែងសាកសួរព័ត៌មានសម្រាប់ភ្ញៀវជាតិ និងអន្តរជាតិ ហើយក៏ជាការិយាល័យសិក្សាមួយសម្រាប់អ្នកដែលចង់មកស្រាវជ្រាវ ទាំងក្នុងនិងក្រៅប្រទេសដែរ។

ជាកិច្ចបន្ទាប់នៃដំណើរទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងលើភ្នំដងរែកនេះ ក្រុមយុវជនទាំងអស់បានវិលត្រឡប់មកកាន់រថយន្ត ដើម្បីចេញដំណើរទៅកាន់ទីកន្លែងបូជាសព ប៉ុល ពត បន្តទៀត។ នៅទីតាំងបូជាសព ប៉ុល ពត នេះ មគ្គុទ្ទេសក៍បានធ្វើការអធិប្បាយយ៉ាងលម្អិតទៅកាន់ក្រុមយុវជនទាក់ទងនឹង ប៉ុល ពត ដែលជាមេដឹកនាំនៅសម័យខ្មែរក្រហម។ ប៉ុល ពត បានស្លាប់នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៨ ដោយសារជំងឺគាំងបេះដូង។ នៅក្នុងអំឡុងពេលដែល ប៉ុល ពត ស្លាប់គឺជាពេលដែលកងកម្លាំងរាជរដ្ឋាភិបាលវាយលុកចូលមកកាន់តំបន់អន្លង់វែងកាន់តែខ្លាំង ជាហេតុធ្វើឲ្យក្រុមគ្រួសាររបស់ ប៉ុល ពត ពុំអាចរកឈើប្ុខសបានគ្រប់គ្រាន់សម្រាប់យកមកបូជាសពរបស់ ប៉ុល ពត។ ដូច្នេះ សាកសពរបស់ ប៉ុល ពត ត្រូវបានបូជាជាមួយនឹងកៅអីរួមជាមួយនឹងសម្បកកង់ឡានចាស់ៗ។ ក្រោយពីបូជារួចហើយ ឆ្អឹងរបស់ ប៉ុល ពត ក៏ត្រូវបានទុកចោលនៅទីនោះរហូតមកដល់ពេលបច្ចុប្បន្ន។

មិនបង្អង់យូរ ក្រុមយុវជនធ្វើដំណើរទៅសារមន្ទីរតាម៉ុក បន្តទៀត។ នៅពេលដែលទៅដល់ទីនោះ យុវជន ព្រមទាំងក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានទៅទស្សនារូបគំនូរ រូបថត ទិដ្ឋភាពនៅជុំវិញសារមន្ទីរផ្ទះ តាម៉ុក ក្នុងគោលបំណងសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ មគ្គុទ្ទេសក៍ចាប់ផ្តើមធ្វើបទបង្ហាញអំពីប្រវត្តិនៃទីតាំងសារមន្ទីរនេះ។ ផ្ទះតាម៉ុក ឬសារមន្ទីរផ្ទះតាម៉ុក ត្រូវបានកសាងឡើងដោយមេដឹកនាំខ្មែរក្រហមឈ្មោះ ឈិត ជឿន ហៅ តាម៉ុក នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៣។ នៅទីនោះមានផ្ទះចំនួន៤ខ្នង ដែលហ៊ុំព័ទ្ធដោយបឹងមានផ្ទៃក្រឡាទំហំ៤១៧ហិចតា។ ផ្ទះទាំងបួននេះត្រូវបានបែងចែកមុខងារខុសៗពីគ្នាគឺ ផ្ទះទី១) សម្រាប់ដាក់ឡាន។ ផ្ទះទី២) មានបីជាន់ ជាន់លើជាបន្ទប់ស្នាក់នៅរបស់តាម៉ុក, ជាន់កណ្តាលជាកន្លែងទទួលភ្ញៀវ និងជាន់ក្រោមគឺជាទីកន្លែងលាក់ខ្លួនរបស់តាម៉ុក។ ផ្ទះទី៣) សម្រាប់ក្រុមគ្រួសាររបស់ តាម៉ុក រស់នៅ និង ផ្ទះទី៤) គឺជារោងបាយ និងជាកន្លែងស្នាក់នៅរបស់ចុងភៅ។

មុនពេលដំណើរទស្សនកិច្ចសិក្សានេះត្រូវបានបញ្ចប់ ក្រុមយុវជនលើកជាមតិ និងចំណាប់អារម្មណ៍របស់ខ្លួនដូចតទៅ ៖

**ហូ លីនដា** ភេទស្រី អាយុ១៧ឆ្នាំ គឺជាសិស្សមកពីវិទ្យាល័យ ហ៊ុន សែន ត្រពាំងតាវ បាននិយាយថា «ខ្ញុំពិតជាសប្បាយរីករាយ ខ្លាំងណាស់ដែលបានចូលរួមនៅក្នុងដំណើរទស្សនកិច្ចសិក្សានេះ។ វាគឺដំណើរទស្សនកិច្ចមួយដែលធ្វើឲ្យខ្ញុំ និងយុវជនផ្សេងៗទៀតមានការយល់ដឹងច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ អ្វីដែលសំខាន់គឺខ្ញុំអាចមកដល់ទីតាំងផ្ទាល់ ដែលស្ថិតនៅក្នុងស្រុកអន្លង់វែងនេះ និងបានស្តាប់ដំណើរដើមទងនៃប្រវត្តិនៃទីតាំងប្រវត្តិសាស្ត្រនីមួយៗថែមទៀត»។

**ព្រេក សុជាតិ** ភេទស្រី ១៩ឆ្នាំ គឺជាសិស្សលើកឡើងថា «នេះគឺជាលើកដំបូងរបស់ខ្ញុំដែលបានមកចូលរួមនៅក្នុងដំណើរទស្សនកិច្ចសិក្សាបែបប្រវត្តិសាស្ត្រនេះ។ ពីមុនខ្ញុំធ្លាប់តែបានសិក្សានៅតាមសាលាជាទ្រឹស្តី ប៉ុន្តែនៅក្នុងឱកាសនេះ ខ្ញុំបានចុះមកដល់ទីតាំងផ្ទាល់ ក៏ដូចជាបានមកស្តាប់នូវរឿងរ៉ាវជាច្រើនទាក់ទងនឹងទីតាំងប្រវត្តិសាស្ត្រនីមួយៗថែមទៀត។ ខ្ញុំចាប់អារម្មណ៍ខ្លាំងជាងគេគឺ ទីតាំងផ្ទះកណ្តាលរបស់ តាម៉ុក ដែលបច្ចុប្បន្នគឺជាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ព្រោះមានទេសភាពស្អាតដែលភ្ជាប់ជាមួយនឹងប្រវត្តិសាស្ត្រនៅទីនោះ»។

**ឆោម និមល** ភេទស្រី អាយុ១៩ឆ្នាំ គឺជាសិស្សមកពីស្រុកត្រពាំងប្រាសាទបាននិយាយថា «ក្រោយពីបានចូលរួមដំណើរទស្សនកិច្ចសិក្សានេះរួចមក ខ្ញុំពិតជាមានអារម្មណ៍ប្លែកៗ ខ្ញុំធ្លាប់តែមកកម្សាន្តនៅ ពើយ តាម៉ុក, សារមន្ទីរ តាម៉ុក ប៉ុន្តែពុំធ្លាប់បានដឹងពីដំណើរសាច់រឿងនៃទីតាំងប្រវត្តិសាស្ត្រទាំងអស់នេះឡើយ។ ទស្សនកិច្ចនៅថ្ងៃនេះបានផ្តល់នូវចំណេះដឹងជាច្រើនសម្រាប់ខ្ញុំក៏ដូចយុវជនផ្សេងទៀតដែលបានចូលរួម។ ខ្ញុំគិតថាបើមានឱកាសលើកក្រោយ ខ្ញុំចង់ចូលរួមម្តងទៀត និងជាពិសេសខ្ញុំចង់យុវជនផ្សេងៗទៀតមានឱកាស



ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងកំពុងបង្ហាញអំពីផ្ទាំងពិព័រណ៍ទៅកាន់សិស្សនៅសារមន្ទីរផ្ទះ តាម៉ុក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សានុសិស្សកំពុងមើលផ្ទាំងពិព័រណ៍រូបថត និងថតរូបភាពនៅសារមន្ទីរផ្ទះ តាម៉ុក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បានមកចូលរួមដំណើរទស្សនកិច្ចសិក្សាដូចខ្ញុំដែរ ដើម្បីឲ្យយុវជនបានសិក្សា ក៏ដូចជាចងចាំនូវប្រវត្តិសាស្ត្រដ៏ជូរចត់នេះ»។

ដំណើរទស្សនកិច្ចនេះត្រូវបានបញ្ចប់នៅម៉ោង៥ រសៀលថ្ងៃដដែល និងមានការថតរូបជុំគ្នានៅខាងមុខសារមន្ទីរ តាម៉ុក ទុកជាអនុស្សាវរីយ៍។

# វេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»

**ស្វួត វិចិត្រ**



យុវជនស្រុកត្រពាំងប្រាសាទ និងស្រុកអន្លង់វែង ចូលរួមទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និងសិទ្ធិមនុស្ស» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានទទួលស្វាគមន៍សិស្សានុសិស្សចំនួន១៦នាក់ (ប្រុស៥នាក់ និងស្រី ១១នាក់) មកពីវិទ្យាល័យ ហ៊ុន សែនត្រពាំងតាវ និង វិទ្យាល័យ ហ៊ុន សែន ត្រពាំងប្រាសាទ ដើម្បីចូលរួមក្នុងវេទិកាថ្នាក់រៀនស្តីអំពី « ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»។

វេទិកានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទ្រឹស្តីសំខាន់ទាក់ទងនឹងសន្តិភាព។

យុវជននៃវិទ្យាល័យទាំងពីរនេះ បានទទួលការស្វាគមន៍គ្នាដោយភាពរួសរាយរាក់ទាក់ និងមានការស្វែងយល់ពីគ្នាទៅវិញទៅមក បើទោះបីសាលារៀនរបស់សិស្សទាំងពីរក្រុមនេះមានចម្ងាយឆ្ងាយពីគ្នាយ៉ាងណាក៏ដោយ។

ក្នុងឱកាសនៃការជួបសំណេះសំណាលនេះ ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានយកចិត្តទុកដាក់ខ្ពស់ទៅលើការអនុវត្តវិធានការថែរក្សានូវសុខុមាលភាព ដើម្បីទប់ស្កាត់ និងជៀសឆ្ងាយពីជំងឺវីរ៉ុសថ្មីអូមីក្រុង តាមរយៈការអនុវត្តវិធានការបិទកុំ និងបីការពាររបស់ក្រសួងសុខាភិបាល។ ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានធ្វើការវាស់កម្ដៅ



បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងកំពុងធ្វើបទបង្ហាញទៅកាន់យុវជនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការបាញ់ទឹកអាល់កុលសម្អាតដៃសិស្សានុសិស្ស ការរក្សាគម្លាត និងការបើកបង្អួចឲ្យមានខ្យល់ចេញចូលគ្រប់គ្រាន់។

បន្ទាប់ពីការរៀបចំ និងអនុវត្តវិធានការការពាររួចមក ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងចែកជូនក្រដាសស្ទាបស្ទង់ចំណេះដឹង (មុនវេទិកាចាប់ផ្តើម) ចំនួន១៦ច្បាប់ ទៅកាន់សិស្សានុសិស្សដើម្បីបំពេញ។ បន្ទាប់មក ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនឹងធ្វើការប្រៀបធៀបនៅក្រោយវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដើម្បីឲ្យដឹងថាសិស្សានុសិស្សចំនួនប៉ុន្មាននាក់ ឬប៉ុន្មានភាគរយមានការកើនឡើងចំណេះដឹងផ្នែកប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។

ក្រោយបំពេញសំណួរស្ទាបស្ទង់ចំណេះដឹងចប់ក៏មានការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការបង្រៀនបែបសហការដើម្បីស្វែងយល់អំពីជំពូកសំខាន់ៗ នៅក្នុងសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ព្រមទាំងនិយមន័យនៃអំពើប្រល័យពូជសាសន៍ ដោយបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។

សិស្សានុសិស្សមានពេលវេលាគ្រប់គ្រាន់ ក្នុងការសិក្សាស្វែងយល់កាន់តែច្បាស់ទៅលើអំពើប្រល័យពូជសាសន៍ដែលបានកើតឡើងប្រមាណជាង៤០ឆ្នាំមុន នៅក្នុងប្រទេសកម្ពុជា ដែលបណ្តាលឲ្យប្រជាជនប្រមាណជិតពីរលាននាក់ បានស្លាប់បាត់បង់ជីវិតដោយសារភាពអត់ឃ្លាន ការធ្វើទារុណកម្ម និងការសម្លាប់។ សំណួរពាក់ព័ន្ធនឹងប្រធានបទនេះត្រូវបានចោទសួរដោយសិស្សានុសិស្សនៅក្នុងក្រុមថា តើហេតុអ្វីបានជាខ្មែរក្រហមមិនឲ្យប្រជាជនហូបឆ្អែត ហើយទិន្នផលដែលធ្វើបាន តើខ្មែរក្រហមបានយកទៅណា? ទន្ទឹមគ្នានេះដែរ សិស្សានុសិស្សបានចោទសួរបន្ថែមថា តើហេតុអ្វីបានជាខ្មែរក្រហមបង្កើតរបបកម្ពុជាប្រជាធិបតេយ្យឡើង? តើបង្កើតឡើងដើម្បីបំបិទសិទ្ធិសេរីភាពប្រជាជន ឬលុបបំបាត់អ្នកចេះដឹង? ឬសម្លាប់មនុស្សទូទៅដោយមិនញញើតដៃបែបនេះឬយ៉ាងណា? សិស្សានុសិស្សបានសួរសំណួរបន្ថែមថា តើរបបខ្មែរក្រហមបង្កើតឡើងដោយទទួលឥទ្ធិពលមនោគមវិជ្ជាពីខាងណា ឬប្រទេសណា ហើយមានស្តេចគ្រងរាជ្យដែរឬទេក្នុងជំនាន់នោះ?

ដើម្បីឆ្លើយតបទៅនឹងចម្ងល់របស់សិស្សានុសិស្សខាងលើនេះ វាគ្មិនបានប្រើប្រាស់វិធីសាស្ត្រទៅ

លើការបែងចែកការងារជាក្រុមទៅកាន់សិស្សានុសិស្ស ដោយផ្តោតលើជំពូកផ្សេងៗគ្នា ដោយបានដកស្រង់ចេញពីសៀវភៅមេរៀនគោល «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដើម្បីឲ្យសកម្មភាពនៅក្នុងក្រុមមានការផុសផុលឡើង តាមរយៈការស្រង់យកនូវខ្លឹមសារសង្ខេបនៃមេរៀន ឬចំណុចសំខាន់ដើម្បីធ្វើបទបង្ហាញទៅកាន់ក្រុមដទៃផ្សេងទៀតៗ នៅក្នុងកិច្ចការនេះ សមាជិកចំនួន៤នាក់នៅតាមក្រុមនីមួយៗ ត្រូវបានបែងចែកតួនាទីផ្សេងៗគ្នាទៀតគឺ ១) អ្នកសម្របសម្រួល, ២) អ្នកកត់ត្រា ៣) អ្នកជំរុញលើកទឹកចិត្ត និង ៤) អ្នករាយការណ៍ផ្ទាល់ ដែលជាការជំរុញឲ្យកិច្ចការក្រុមទាំងមូលមានប្រសិទ្ធភាពខ្ពស់ៗ

មួយវិញទៀត វេទិកានេះ បានជំរុញឲ្យសិស្សានុសិស្សមានការចងចាំពីខ្លឹមសារមេរៀន តាមរយៈការចាក់បញ្ចាំងខ្សែភាពយន្តឯកសារអំពីមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង ដែលប្រភេទខ្សែភាពយន្តឯកសារដ៏កម្រដែលរក្សាទុកនៅក្នុងបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងត្រូវបានយកមកប្រើប្រាស់ជំនួសឲ្យការពន្យល់ក្នុងវិធីសាស្ត្រដទៃផ្សេងទៀតៗ ការការចាក់បញ្ចាំងខ្សែភាពយន្តឯកសារបែបនេះ គឺធ្វើឲ្យមានការគិតយ៉ាងទូលំទូលាយទៅលើប្រវត្តិសាស្ត្រ និងជំរុញឲ្យមានការចងចាំក្នុងរយៈពេលយូរៗ ខ្សែភាពយន្តឯកសារនេះ ពិតជាបានបង្ហាញនូវអត្ថន័យនៃភាពអកុសលនៃជនរងគ្រោះដែលត្រូវបានឃុំឃាំង និងធ្វើទារុណកម្មនៅក្នុងមន្ទីរសន្តិសុខស-២១ មុននឹងត្រូវយកទៅសម្លាប់ចោលនៅវាលពិឃាតបឹងជើងឯកៗ ភាពអសោចនៃសាកសពជនរងគ្រោះ ត្រូវបានបង្ហាញតាមរយៈវីដេអូដែលថតដោយកងទ័ពវៀតណាមតែប៉ុន្មានថ្ងៃប៉ុន្មានក្រោយកងទ័ពទាំងនោះបានចូលមកដល់ទីក្រុងភ្នំពេញៗ

រូបនៃអំពើប្រល័យពូជសាសន៍ទាំងនេះ បានពិពណ៌នាដោយចេតនានៃភាពស្អប់ខ្ពើម និងការរើសអើងដែលឈានទៅដល់ការបំផ្លិចបំផ្លាញស្ទើរទាំងស្រុងទៅលើក្រុមជនជាតិជាតិពិន្ទុពូជសាសន៍ឬក្រុមសាសនាដទៃផ្សេងទៀត ដោយមានការប្រកាន់



បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងកំពុងធ្វើបង្ហាញទៅកាន់យុវជនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងប្រវត្តិសាស្ត្រសហគមន៍អន្លង់វែងៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



*យុវជនកំពុងអានសៀវភៅ និងពិភាក្សាគ្នាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

និន្នាការនិយមលាបពណ៌។ ចេតនានៃអំពើឃោរឃៅទាំងនេះ ហាក់បានឆ្លុះបញ្ចាំង និងដាស់តឿនដល់សិស្សានុសិស្សឲ្យរៀនសូត្រពីរឿងរ៉ាវដែលសង្គមរបស់ខ្លួនបានឆ្លងកាត់ហើយងាកមករកសាមគ្គីភាព និងរស់នៅដោយចេះទទួលស្គាល់នូវភាពសម្បូរបែបរបស់មនុស្សជាតិនៅក្នុងសង្គម។ ទាំងនេះគឺជាគោលដៅដែលជំរុញឲ្យមានការបង្កើតសកម្មភាពនៃការបណ្តុះគំនិតក្នុងការធានាបានថា បទពិសោធន៍ដ៏ជូរចត់របស់សង្គមកម្ពុជានឹងមិនវិលត្រឡប់សារជាថ្មីម្តងទៀតទេ។ ក្រោយមកទៀត ខ្សែភាពយន្តឯកសារ «ខ្មែរបាត់បង់តន្ត្រីរ៉ក់» ក៏ត្រូវបានចាក់បញ្ចាំងបន្ថែមទៀត បន្ទាប់ពីសិស្សានុសិស្សហូបអាហារថ្ងៃត្រង់រួច។ ខ្សែភាពយន្តឯកសារនេះបានទាញចំណាប់អារម្មណ៍សិស្សានុសិស្សឲ្យមើលឃើញពីភាពប្រែប្រួលរបស់តន្ត្រីខ្មែរតាមសម័យកាល និងបង្ហាញពីការជម្នះក្នុងស្ថានភាពណាក៏ដោយរបស់តន្ត្រីករខ្មែរ ដើម្បីគេចផុតពីការរលាយសាបសូន្យ ទោះបីទទួលឥទ្ធិពលនយោបាយ ឬវប្បធម៌បរទេសក៏ដោយ។ នៅក្នុងចំណុចនេះ សិស្សានុសិស្សនៅក្នុងក្រុមយល់ឃើញថា ទោះក្នុងកាលៈទេសៈណាក៏ដោយ ក៏ប្រជាជនខ្មែរស្វែងយល់នូវការសប្បាយតាមរយៈដូរយតន្ត្រីក្នុងសង្គមរបស់ខ្លួន។

នៅក្រោយវេទិកាថ្នាក់រៀននេះ សិស្សានុសិស្សទាំង១៦នាក់ ស្មើនឹងមួយរយភាគរយមានការកើនឡើងចំណេះដឹង និងយល់ថា ការទប់ស្កាត់អំពើប្រល័យពូជសាសន៍តាមវិធីណាក៏ដោយ គឺពិតជាមានសារសំខាន់សម្រាប់បុគ្គល សហគមន៍ និងសង្គមជាតិតាមរយៈការពិនិត្យជាក់ស្តែងទៅលើក្រដាសស្ទាបស្ទង់របស់សិស្សានុសិស្សម្នាក់ៗ។

បន្ទាប់ពីបានចូលក្នុងវេទិកានេះ សិស្សានុសិស្សចំនួន៤នាក់ មានចំណាប់អារម្មណ៍ និងការយល់ឃើញដូចខាងក្រោម ៖

**ស៊ាន ចន្ទី** *ភេទស្រី អាយុ១៩ឆ្នាំ គឺជាសិស្សនៃវិទ្យាល័យ ហ៊ុន សែន ត្រពាំងប្រាសាទ លើកឡើងថា «ខ្ញុំបានយល់ដឹងប្រវត្តិសាស្ត្រខ្មែរក្រហមកាន់តែច្បាស់តាមរយៈវេទិកាថ្នាក់រៀន ដោយមានការធ្វើបាបប្រជាជន ការហូបចុកមិនគ្រប់គ្រាន់ ការរស់នៅរួម និងធ្វើការរួមរបស់ប្រជាជនក្នុងជំនាន់នោះ។ តាមរយៈវីដេអូឯកសារនៃមន្ទីរសន្តិសុខស-២១ ខ្ញុំឃើញប្រជាជនទទួលរងទុក្ខវេទនា ដែលរំពុកដល់យើងទាំងអស់គ្នាថា ត្រូវតែបន្តស្វែងយល់ពីរបបខ្មែរក្រហមឲ្យកាន់តែច្បាស់លាស់បន្ថែមទៀត»។*

**ហ៊ាន ស៊ីណា** ភេទស្រី អាយុ១៩ឆ្នាំ រៀបរាប់ថា «វាពិតជាគួរឲ្យភ្ញាក់ផ្អើលសម្រាប់ប្រវត្តិសាស្ត្រខ្មែរយើងតាំងពីដើមមកខាងផ្នែកចម្រៀង។ ដំបូងខ្ញុំមិនបានដឹងថា ប្រវត្តិរបស់ ស៊ិន ស៊ីសាមុត យ៉ាងណានោះទេ គឺខ្ញុំមានការភ្ញាក់ផ្អើលព្រោះគាត់គឺជាតន្ត្រីករឆ្នើម ប៉ុន្តែនៅក្នុងជំនាន់លន់នល់ តន្ត្រីកររូបនេះប្រែក្លាយជាកងទ័ពបម្រើជាតិទៅវិញ។ ខ្ញុំយល់ថាទិដ្ឋភាពបែបនេះបញ្ជាក់ថា មានការប្រែប្រួលពីសម័យមួយដែលលូតលាស់ ទៅជាសម័យកាលមួយជួបប្រទះនូវភ្លើងសង្រ្គាមទៅវិញ។ ខ្ញុំអាណិតចាស់ជរា និងក្មេងៗដែលរងគ្រោះដោយសារការទម្លាក់គ្រាប់បែកនេះ»។

**ផាន ខណ្ណា** ភេទប្រុស អាយុ១៧ឆ្នាំ គឺជាសិស្សនៃវិទ្យាល័យ ហ៊ុន សែន ត្រពាំងតាវ លើកឡើងថា «ក្រោយពីខ្ញុំបានចូលរួមវេទិកាថ្នាក់រៀនប្រវត្តិសាស្ត្រ ខ្ញុំពិតជាមានអារម្មណ៍ស្រណោះប្រជាជន និងជនរងគ្រោះខ្លាំងណាស់។ ខ្ញុំដឹងប្រវត្តិសាស្ត្របានច្រើនជាងមុន ថាហេតុអ្វីបានជាមានអំពើប្រល័យពូជសាសន៍កើតឡើង។ ខ្ញុំយល់ថា ប្រសិនបើយើងចង់ទប់ស្កាត់អំពើប្រល័យពូជសាសន៍ គឺយើងជាយុវជនត្រូវរៀនសូត្រឲ្យបានខ្ពង់ខ្ពស់ ត្រូវទប់ស្កាត់អំពើហិង្សា និងការរើសអើង”។

**ភាព រក្សា** ភេទប្រុស អាយុ១៧ឆ្នាំ គឺជាសិស្សនៃវិទ្យាល័យតេជោ ហ៊ុន សែន ត្រពាំងតាវ យល់ឃើញថា «វាជាឱកាសល្អដែលបានរៀនសូត្រ និងបានស្គាល់ពីប្រវត្តិសាស្ត្រនៃការតស៊ូរបស់ខ្មែរ ភាពឃោរឃៅរបស់ខ្មែរក្រហម និងអំពីសិល្បៈរបស់ខ្មែរ។ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ គឺយើងត្រូវសិក្សារៀនសូត្រ និងបំបាត់ការរើសអើង»។



យុវជនធ្វើបទបង្ហាញអំពីការយល់ដឹងរបស់ខ្លួនទាក់ទងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីចូលរួមវគ្គបណ្តុះបណ្តាលរួច។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវរបស់ប្រជាជនតាមរយៈវេទិកាប្រវត្តិសាស្ត្រគ្រួសារក្នុងស្រុកអន្លង់វែង

ស្ងួត វិចិត្រ, មេក វិន និង ហ៊ាន ពិសី

## បិត ខា

បិត ខា ភេទស្រី អាយុ៦៣ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិដីបូកខ្ពស់ ឃុំបរសេដ្ឋ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ បច្ចុប្បន្ន ខា កំពុងរស់នៅក្នុងភូមិយាងត្បូង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ខា បាននិយាយរៀបរាប់អំពីបទពិសោធន៍ជីវិតរបស់ខ្លួនក្នុងសម័យខ្មែរក្រហមថា ខ្ញុំរស់នៅក្នុងគ្រួសារកសិករនៅក្នុងស្រុកសំរោងទង។ ខ្ញុំមានបងប្អូនបង្កើតចំនួន៩ នាក់ ហើយខ្ញុំគឺជាកូនស្រីទី៧ នៅក្នុងគ្រួសារ។ កាលពីកុមារភាពខ្ញុំមិនបានរៀនសូត្រទេដោយសារតែជីវភាពគ្រួសារលំបាក។ នៅចុងឆ្នាំ១៩៧២ ភូមិរបស់ខ្ញុំទទួលរងការទម្លាក់គ្រាប់បែកដែលធ្វើឲ្យអ៊ំស្រីម្នាក់ដែលមានវ័យចាស់ជរាត្រូវស្លាប់បាត់បង់ជីវិត។ ពេលនោះខ្ញុំនៅកុមារភាពនៅឡើយ ហើយម្ដាយខ្ញុំបានប្រើឲ្យខ្ញុំនៅផ្ទះមើលថែប្អូន។ រហូតដល់ឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្ដើមប្រមូលប្រជាជនឲ្យចូលរស់នៅ និងធ្វើការងាររួមក្នុងសហករណ៍។ នៅក្នុងឆ្នាំដដែល ខ្ញុំបានត្រូវអង្គការបញ្ជូនឲ្យទៅនៅក្នុងកងកុមារ ដើម្បីកាប់ទន្រ្ទានខែត្រ ដាំដំឡូងជ្វា ស្ពៃ ត្រសក់ និងត្រកួន។ ក្រៅពីការងារទាំងនេះ ខ្ញុំមានឱកាសដើម្បីរៀនសូត្រមួយបានរយៈពេលខ្លីដែរ។ លុះដល់ឆ្នាំ១៩៧៧ ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនទៅកាន់ខេត្តកំពត ដើម្បីធ្វើការងារក្នុងស្រែអំបិល។ នៅទីនោះសមាជិកក្រុមរបស់ខ្ញុំមានគ្នាប្រហែល៣០ទៅ៦០នាក់ដើម្បីធ្វើការងារស្រែអំបិលនេះ។ យើងបូមទឹកសមុទ្រទៅបញ្ចូលក្នុងស្រែពីស្រែលេខមួយ រហូតដល់ស្រែលេខប្រាំ ដោយ



បិត ខា ទទួលប្រអប់អនុស្សាវរីយ៍ពីក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។
(ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

បង្ហាប់ដី និងវាស់ទឹកទៅតាមបច្ចេកទេសនៃការបណ្ដុះអំបិល។ អំបិលអាចដុះក្នុងរយៈពេលមួយសប្ដាហ៍ឬយូរជាងនេះ បន្ទាប់មក យើងនាំគ្នាប្រមូលអំបិលទាំងនោះទៅទុកក្នុងឃ្លាំងដោយគ្មានពេលសម្រាក។ យើងអាចធ្វើការងារចាប់ពីម៉ោង១១ថ្ងៃត្រង់ រហូតដល់ម៉ោងជិតភ្លឺនាថ្ងៃបន្ទាប់ ហើយសម្រាករហូតដល់ម៉ោង១១ថ្ងៃត្រង់វិញ។ អំបិលដែលធ្វើបានគឺត្រូវបានដឹកជញ្ជូនដោយឡានរបស់ខ្មែរក្រហមទៅកាន់តំបន់ភូមិភាគផ្សេងៗគ្នា។ ទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនធ្លាប់ជួបប្រទះនឹងភាពអត់ឃ្លានដែរ។

## សៅ សួរ

សៅ សួរ ភេទប្រុស កើតក្នុងឆ្នាំ១៩៥៧ មានទីកន្លែងកំណើតនៅក្នុងភូមិស្នួល ស្រុកក្រឡាញ់ ខេត្ត



សៅ សួរ ទទួលប្រអប់អនុស្សាវរីយ៍ពីក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។

សៀមរាប។ បច្ចុប្បន្ន សួ រស់នៅក្នុងភូមិយាងត្បូង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សួរ បានចែករំលែកពីបទពិសោធន៍របស់ខ្លួនថា នៅឆ្នាំ ១៩៧៣ ខ្ញុំស្ម័គ្រចិត្តចូលបម្រើកងទ័ពខ្មែរក្រហមនៅមន្ទីរស្រុកក្រឡាញ់។ ក្រោយមក ខ្ញុំត្រូវបានអង្គភាពខ្មែរក្រហមបញ្ជូនទៅកាន់តំបន់៥ ក្នុងខេត្តបាត់ដំបង ដើម្បីប្រយុទ្ធជាមួយទាហាន លន់ នល់។ បន្ទាប់ពីយើងបានហាត់រៀនពីរបៀបរបបរបស់យោធា និងប្រតិបត្តិការសឹកសង្គ្រាម ខ្មែរក្រហមបានបំផុសបំផុលឲ្យយើងស្អប់អ្នកមាន និងការជិះជាន់ផ្សេងៗពីពួកសក្តិភូមិ។ ខ្ញុំឃើញថា សង្គ្រាមពិតជាបង្កនូវមហាវិនាសកម្មដ៏ធំធេង ក៏ប៉ុន្តែយើងត្រូវតែបង្ខំចិត្តតស៊ូនៅក្នុងព្រៃរហូតដល់ទទួលបានជ័យជម្នះ ក្នុងឆ្នាំ ១៩៧៥ ទៅលើទាហាន លន់ នល់។ ក្រោយមកទៀត កងកម្លាំងរបស់យើងបានឡើងកាណូត រួចធ្វើដំណើរទៅកាន់ស្រុកស្នួល ខេត្តក្រចេះ ដើម្បីឈរជើងការពារព្រំដែនជាប់ប្រទេសវៀតណាម ដែលនៅទីនោះ ខ្ញុំនៅកងពលតូចលេខ១១៧ គ្រប់គ្រងដោយ តារ៉ុម។ នៅទីនោះ យើងបានវាយប្រហារជាប្រចាំជាមួយនឹងកងទ័ពវៀតណាម ដែលបណ្តាលឲ្យកងកម្លាំងរបស់យើងបានស្លាប់បាត់បង់ជីវិតជាច្រើននាក់។ កងទ័ពអាចប្រឈមនឹងការស្លាប់ ប្រសិនបើការវាយប្រហារបានកើតឡើង។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំជាយោធាម្នាក់ដែលមានសំណាង ហើយអាចរួចរស់ជីវិតរហូតមកដល់សព្វថ្ងៃនេះ។

---

## ឈុន យឿត

ឈុន យឿត ភេទស្រី អាយុ៥៥ឆ្នាំ មានទីកន្លែងកំណើតនៅភូមិក្តីរុន ឃុំក្តីរុន ស្រុកពួក ខេត្តសៀមរាប។ បច្ចុប្បន្ន យឿត រស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ យឿត បានចែករំលែកថា « ខ្ញុំមានបងប្អូនបង្កើតចំនួន៩ នាក់ គឺស្រី៧ នាក់ និងប្រុស២ នាក់។ គ្រួសារខ្ញុំគឺជាកសិករ។ កាលពីកុមារភាព ខ្ញុំមិនបានរៀនសូត្រទេ ដោយសារស្រុកទេសកើតមានសង្គ្រាម។ លុះដល់អាយុប្រហែល១០ឆ្នាំ គ្រួសាររបស់ខ្ញុំ និងអ្នកភូមិផ្សេងទៀតក៏ត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិ ដើម្បីធ្វើការងារនៅក្នុងភូមិព្រៃយាង។ បន្ទាប់មក ខ្ញុំត្រូវបានខ្មែរក្រហមជ្រើសរើសឲ្យចូលធ្វើការនៅក្នុងកងកុមារ ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីភូមិ។ ខ្ញុំត្រូវដើរកាប់ទន្រ្ទានខែត្រ និងរែកដីដាក់ស្រែ ជាមួយក្រុមគ្រួសាររបស់ខ្ញុំ។ ការហូបចុកវិញ គឺយើងមិនបានជួបប្រទះនឹងភាពខ្វះខាតនោះទេ។ ក្រោយមកទៀត បងប្អូន និងឪពុកម្តាយរបស់ខ្ញុំត្រូវ ខ្មែរក្រហមបំបែកចេញគ្នាឲ្យធ្វើកិច្ចការរៀងៗ



ឈុន យឿត ភេទស្រី អាយុ៥៥ឆ្នាំ រស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កំពុងរៀបរាប់អំពីរឿងរ៉ាវជីវិតរបស់ខ្លួនទៅកាន់ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (ស្ទួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្លួនៗ ទោះជាយ៉ាងនេះក្តី រៀងរាល់ពេលល្ងាច គ្រួសាររបស់ខ្ញុំគឺបានត្រឡប់មកជួបជុំគ្នាវិញៗ នៅក្នុងកងខ្មែរក្រហមមិនធ្វើបាបកុមារទេ ប៉ុន្តែប្រធានកងនឹងណែនាំ ឬអប់រំកុមារនៅក្នុងក្រុមឲ្យកែប្រែនូវទង្វើរបស់ខ្លួន ដូចជា ធ្លាប់លួចដំឡូង ឬចំណីអាហារៗ ជួនកាលប្រធានកងកុមារក៏មិនយកទោសអ្វីដែរ ដោយសារកុមារទាំងនោះនៅក្មេងៗពេកៗ ខ្ញុំមិនសូវជួបការលំបាកនោះទេកាលជំនាន់នោះ ដោយសារប្រធានកងរបស់ខ្ញុំជាមនុស្សដែលមានសន្តានចិត្តល្អ និងចេះសណ្តោសប្រណីដល់កុមារនៅក្នុងក្រុមៗ នៅក្នុងឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពវៀតណាមចូលមកក្នុងប្រទេសកម្ពុជា ក្រុមគ្រួសាររបស់ខ្ញុំក៏ត្រូវបានរំសាយចេញពីភូមិយ៉ាង ទៅកាន់ភូមិក្តីរុនវិញៗ នៅពេលនោះ ខ្ញុំបានឃើញកងទ័ពវៀតណាមជាច្រើននាក់នៅទីនោះៗ កងទ័ពវៀតណាមមិនធ្លាប់ធ្វើបាបមកលើក្រុមគ្រួសាររបស់ខ្ញុំ ឬប្រជាជនដទៃផ្សេងទៀតទេ ប៉ុន្តែជួយមកវិញ កងទ័ពរដ្ឋាភិបាលនិងវៀតណាម ទាំងនោះ បានផ្គត់ផ្គង់ស្បៀងអាហារមកកាន់ពួកយើងៗ លុះដល់ឆ្នាំ១៩៨០ ក្រុមគ្រួសាររបស់ខ្ញុំ និងប្រជាជនផ្សេងទៀតនៅក្នុងភូមិបានរត់ភៀសខ្លួនទៅរស់នៅក្នុងព្រៃម្តងទៀត ដើម្បីគេចផុតពីការវាយប្រយុទ្ធរវាងកងទ័ពខ្មែរក្រហម និងវៀតណាមៗ លុះនៅឆ្នាំ១៩៩២ ខ្ញុំបានសម្រេចធ្វើដំណើរដោយថ្មើរជើងមកកាន់អន្លង់វែងតាមរយៈបងស្រីបង្កើតរបស់ខ្ញុំៗ ផ្ទះបងស្រី ខ្ញុំពេលនោះគឺ នៅជិតរង្វង់មូលស្រុកអន្លង់វែងៗ រហូតដល់ឆ្នាំ១៩៩៣ អ៊ុនតាក់បានចូលមកក្នុងប្រទេសកម្ពុជា ប៉ុន្តែទោះជាយ៉ាងណាក៏ដោយសង្គ្រាមនៅតែបន្តកើតមាន ដែលធ្វើឲ្យប្រជាជនបង្ខំចិត្តរត់ភៀសខ្លួនទៅរស់នៅក្នុងជុំវិញប្រទេសថៃជាបណ្តោះអាសន្ន រហូតដល់ស្ថានភាពបានស្ងប់ស្ងាត់ទៅវិញ ទើបខ្ញុំនិងក្រុមគ្រួសារបានវិលត្រឡប់មករស់នៅក្នុងស្រុកអន្លង់វែងមកទល់នឹងពេលបច្ចុប្បន្នៗ



កសិករនៅក្នុងឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ កំពុងប្រមូលដំឡូងៗ
( ស្ងួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# រឿងរ៉ាវរបស់ប្រជាជននៅស្រុកកំពង់ត្របែក ក្រោមរបបខ្មែរក្រហម

ផេង ពង្សរ៉ាស៊ី



យស់ ហ៊ិន អាយុ៧៩ឆ្នាំ រស់នៅភូមិបេង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ផ្តល់បទសម្ភាសន៍ដល់ ភាវ ស្មី បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ១. យស់ ហ៊ិន

ខ្ញុំឈ្មោះ យស់ ហ៊ិន អាយុ៧៩ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅភូមិបេង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ឪពុករបស់ខ្ញុំឈ្មោះ យស់ ជិន ស្លាប់តាំងពីខ្ញុំអាយុ១០ឆ្នាំ និងម្តាយឈ្មោះ វ៉ា សោរ ស្លាប់តាំងពីខ្ញុំអាយុ៥ឆ្នាំ។ ខ្ញុំមានបងប្អូន៤នាក់(ប្រុស ១នាក់) ហើយសព្វថ្ងៃស្លាប់អស់ហើយ។ បន្ទាប់ពីឪពុកម្តាយរបស់ខ្ញុំស្លាប់ទៅ ខ្ញុំបានទៅរស់នៅជាមួយអ៊ំរបស់ខ្ញុំ និងជួយធ្វើស្រែចម្ការគាត់។ កាលនៅក្មេងខ្ញុំមិនបានចូលរៀនសូត្រអ្វីទេ គឺគ្រាន់តែបានរៀនអក្ខរកម្ម១ឬ២ខែពេលទំនេរពីការធ្វើស្រែចម្ការ ដែលជាហេតុធ្វើឲ្យខ្ញុំមិនចេះអក្សរ។ នៅឆ្នាំ១៩៦៩ ខ្ញុំបានរៀបការជាមួយបុរសម្នាក់ដែលមានឈ្មោះថា ម៉ៅ ភូ និងចាប់ផ្តើមរកស៊ីធ្វើស្រែចម្ការចិញ្ចឹមជីវិត។ នៅឆ្នាំ១៩៧០ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ហើយនៅក្នុងភូមិបេងចាប់ផ្តើមមានការប្រយុទ្ធគ្នា និងទម្លាក់គ្រាប់បែកជាច្រើនដូចជា គ្រាប់ណាប៉ាំ និងគ្រាប់បូម។ ការទម្លាក់គ្រាប់បែក ធ្វើឲ្យភូមិបេងមានរណ្តៅជម្រៅប្រមាណ១០ម៉ែត្រ និងមានបណ្តោយ-ទទឹងប្រមាណ១០ទៅ១៥ម៉ែត្រ ខូចខាតផ្ទះប្រជាជន ខូចផលដំណាំ និងងាប់សត្វចិញ្ចឹមអស់ជាច្រើន។ ជាញឹកញាប់គ្រួសាររបស់ខ្ញុំបានជម្លៀសទៅឃុំកន្សោមអក ខាងជើងផ្លូវជាតិលេខ១១ ឬក៏ទៅផ្ទះបងថ្លៃ ដើម្បីសុំកន្លែងស្នាក់អាស្រ័យបណ្តោះអាសន្ន។ រឿងមួយដែលខ្ញុំចាំមិនភ្លេចពេលជម្លៀសគឺខ្ញុំបានឈឺពោះឆ្លងទន្លេកូនដំបូងនៅផ្ទះបងថ្លៃរបស់ខ្ញុំ ហើយក៏មានទាហានធីវគី ចុះទៅឆែកឆេររកទាហានវៀតកុង។ ទាហានធីវគីពី៤ទៅ៥នាក់ ចូលក្នុងរោងស្រូវ ដែលជាកន្លែងខ្ញុំឆ្លងទន្លេ បម្រុងចាប់ប្តីរបស់ខ្ញុំ ប៉ុន្តែពេលឃើញប្តីរបស់ខ្ញុំកាន់កូនខ្ចីទើបតែកើតរួច វាក៏ដើរចេញទៅវិញ។ នៅយប់ដដែលនោះ ទាហានធីវគី បានបាញ់ប្លោងគ្រាប់ជាច្រើនចូលក្នុងភូមិ ដែលជាហេតុធ្វើឲ្យខ្ញុំមិនបានអាំងភ្លើងនៅលើគ្រែ ហើយត្រូវរត់ចូលក្នុងត្រង់សេ។ លុះស្អែកឡើង គ្រួសាររបស់ខ្ញុំបានធ្វើដំណើរបន្តទៅមុខទៀត ដើម្បីសុំផ្ទះឪពុកក្មេករបស់ខ្ញុំស្នាក់នៅ និងគេចពីការធ្វើបាបរបស់ទាហានធីវគី។ គ្រួសាររបស់ខ្ញុំជម្លៀសពីមួយកន្លែងទៅមួយកន្លែងទៀត ដោយសុំផ្ទះអ្នកស្រុកស្នាក់នៅ និងជួយធ្វើការងារផ្សេងៗរបស់ម្ចាស់ផ្ទះ ដើម្បីបានអង្ករទុកហូបប្រចាំថ្ងៃ។ ខ្ញុំចេះធ្វើបាវអំពីស្លឹកត្នោត សម្រាប់ដាក់ស្រូវបានប្រមាណ១០តៅ ១៥តៅ ឬក៏២០តៅ

តាមការចង់បានរបស់អ្នកស្រុកដើម្បីប្តូរយកស្បៀងអាហារ។ ឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំបានត្រឡប់មករស់នៅក្នុងភូមិបេងវិញ និងចាប់ផ្តើមធ្វើស្រែជាក្រុមប្រវាសដៃគ្នា។ ក្រោយមកទៀត អង្គការបានប្រមូលរបស់របរទាំងអស់ដាក់ធ្វើជារបស់រួម និងចាប់ផ្តើមធ្វើការងាររួមគ្នាទាំងអស់ដោយគ្រាន់តែបែកជាក្រុមៗតាមកង។ ក្នុងឆ្នាំ១៩៧៧ នៅពេលដែលខ្ញុំពរពោះកូនទីពីររបស់ខ្ញុំបាន៥ខែ អង្គការនៅតែប្រើខ្ញុំឲ្យរែកដីបាតត្រពាំង១ថ្ងៃឲ្យបានមួយគោនយកមកទុកធ្វើដីដាក់ស្រែ។ អំឡុងពេលនោះ ដោយសារតែខ្ញុំធ្វើការងារធ្ងន់ៗពេក ទើបធ្វើឲ្យខ្ញុំធ្លាក់ឈាមជាបន្តបន្ទាប់ៗ។ ឃើញស្ថានភាពដូច្នេះ ខ្ញុំដាច់ចិត្តស្នើសុំប្រធានសហករណ៍ឈប់ធ្វើការងារដើម្បីឲ្យបាត់ធ្លាក់ឈាមសិន។ ប្រធានសហករណ៍ឈ្មោះ ផុនបានប្តូរការងារឲ្យខ្ញុំដើរប្រមូលស្លឹកឈើនៅក្នុងភូមិយកទៅដាក់ក្នុងរណ្តៅដីវិញម្តង ព្រោះជាការងារស្រាល។ នៅពេលដែលខ្ញុំពរពោះបានជិត៨ខែ ខ្ញុំធ្លាក់ឈាមកាន់តែខ្លាំងជាងមុនៗ។ នៅយប់នោះ ដោយសារប្តីរបស់ខ្ញុំមិននៅ គឺគាត់ត្រូវបានអង្គការប្រើឲ្យទៅធ្វើត្រីប្រហុកនៅកោះទៃ (ស្រុកព្រះស្តេច) ទើបខ្ញុំដាស់កូនរបស់ខ្ញុំឲ្យទៅហៅបងស្រីរបស់ខ្ញុំឈ្មោះ ជៀវ ដែលនៅផ្ទះជាប់គ្នា ឲ្យមកមើលខ្ញុំ។ ពេលបងរបស់ខ្ញុំមកដល់ គាត់មិនមានដំណោះស្រាយអ្វីទាំងអស់ គឺគាត់ឲ្យខ្ញុំទ្រាំនៅធ្លាក់ឈាមពេញមួយយប់ៗ រហូតដល់ស្អែកឡើងបានបងរបស់ខ្ញុំម្នាក់ទៀតមកពីខាងភូមិដីអក ប្រាប់ឲ្យខ្ញុំទៅសុំប្រធានសហករណ៍ទៅពេទ្យ។ ពេលទៅដល់ពេទ្យ ខ្ញុំធ្លាក់ឈាមកាន់តែខ្លាំង ដែលជាហេតុធ្វើឲ្យខ្ញុំឈឺពោះកាន់តែខ្លាំងៗ ដោយមើលឃើញថា ខ្ញុំឈឺខ្លាំងពេក បង ជៀវ បានទៅសុំប្រធានពេទ្យក្នុងវត្តបេងឈ្មោះ ហេង ទៅហៅយាយម៉បឈ្មោះ ទូច នៅក្នុងភូមិបេងឲ្យមកមើលខ្ញុំ។ ពេលដែលយាយម៉បមកដល់ គាត់បានយកដៃរុញកូនក្នុងពោះខ្ញុំឲ្យធ្លាក់ចុះមកក្រោម ទើបខ្ញុំបាត់ឈឺចុកចាប់ និងសម្រាលកូននៅថ្ងៃនោះតែម្តង។ បន្ទាប់ពីកូនខ្ញុំកើតបាន១ថ្ងៃក៏ត្រូវស្លាប់ ព្រោះមិនមានថ្នាំព្យាបាលត្រឹមត្រូវ ហើយខ្ញុំឈប់សម្រាកពីការងារបានតែ ១០ថ្ងៃក៏ត្រូវបានអង្គការប្រើឲ្យដើរប្រមូលសំរាមនៅក្នុងភូមិបន្តទៀត។ នៅក្នុងសម័យខ្មែរក្រហម ខ្ញុំធ្វើការងារធ្ងន់ៗ ហើយមិនសូវហ៊ានសម្រាកឡើយ ព្រោះចង់យកចិត្តអង្គការ ដើម្បីកុំឲ្យគេយកទៅសម្លាប់ចោល។ ក្នុងឆ្នាំ១៩៧៩ បន្ទាប់ពីប្រជាជនត្រឡប់មកដល់ផ្ទះវិញ ប្រជាជននៅក្នុងភូមិបេងរួមទាំងឈ្មោះ សុខ វ៉ិន កាន់កាំបិតទៅកាប់អតីតប្រធានសហករណ៍ឈ្មោះ ផុន ដាច់ក្បាលស្លាប់ ព្រោះគាត់បានយកប្តី ឬក៏ប្រពន្ធរបស់អ្នកភូមិបេងដែលជាជនជាតិវៀតណាម ឬជនជាតិចិន ទៅសម្លាប់ចោលនៅទួលវែង។ ឈ្មោះ សុខ វ៉ិន មានកំហឹងខ្លាំងជាងគេ ព្រោះប្រពន្ធរបស់គាត់ជាជនជាតិវៀតណាម ត្រូវបានឈ្មោះ ផុន យកទៅសម្លាប់ទាំងកំពុងពរពោះ។ ចំណែកប្រពន្ធរបស់ ផុន ឈ្មោះ មាយ ហេត បន្ទាប់ពីឃើញគេកាប់ប្តីខ្លួនស្លាប់នៅក្នុងផ្ទះដូច្នេះ ក៏រត់ឡើងផ្ទះអ្នកជិតខាងចងកសម្លាប់ខ្លួន។ បន្ទាប់ពីបែកខ្មែរក្រហម ខ្ញុំចាប់ផ្តើមរកស៊ីធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិតបន្តរហូតមកដល់សព្វថ្ងៃ។

## ២. ប៉ុល ហាន

ប៉ុល ហាន ហៅ សុត ហាន អាយុ៧០ឆ្នាំ រស់នៅភូមិបេង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង បានរៀបរាប់ថា «ស្រុកកំណើតរបស់ខ្ញុំនៅភូមិចំបក់ ឃុំជ្រៃ ស្រុកកំពង់ត្របែក។ ប៉ុន្តែខ្ញុំមករស់នៅជាមួយម្តាយចិញ្ចឹមឈ្មោះ ទី ក្នុងភូមិព្រែកសំរោង ឃុំព្រៃពោន ព្រោះម្តាយបង្កើតខ្ញុំរវល់ខ្លាំង មិនអាចមើលថែខ្ញុំបាន។ ម្តាយបង្កើតខ្ញុំឈ្មោះ វង ផាន់ ធ្វើការនៅក្នុងវាំងបម្រើឲ្យសម្តេចព្រះមហាក្សត្រិយានី។ គាត់ចេះចាប់សរសៃរ។ ថ្ងៃមួយនៅពេលដែលសម្តេចព្រះមហាក្សត្រិយានីទ្រង់ព្រះប្រឈួន រាជការមកហៅម្តាយខ្ញុំឲ្យទៅចាប់សរសៃរឲ្យសម្តេចព្រះមហាក្សត្រិយានី។ ម្តាយខ្ញុំបានចាប់សរសៃរ និងអាចធ្វើឲ្យសម្តេចព្រះមហាក្សត្រិយានីជាសះស្បើយអាចយាងទៅណាមកណាបាន។ តាំងពីពេលនោះមក ម្តាយខ្ញុំត្រូវនៅបម្រើព្រះអង្គរហូត។ ខ្ញុំបានទៅរស់នៅជាមួយម្តាយ



ប៉ុល ហន ហៅ សុត ហន អាយុ៧០ឆ្នាំ រស់នៅភូមិបេង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ផ្តល់បទសម្ភាសន៍ដល់ ដេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។
(ភារស្មី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំនៅផ្ទះខាងមុខវត្តបុទុមចំនួនបីឆ្នាំ ប៉ុន្តែគាត់មិនសូវបានមកផ្ទះទេ គឺស្នាក់នៅតែក្នុងវាំង បុចេញទៅណាមកណាតែជាមួយព្រះអង្គរហូត។ ដោយសារតែម្តាយរវល់ច្រើននៅក្នុងវាំង ខ្ញុំភាគច្រើនរស់នៅតែជាមួយបងថ្លៃស្រីរបស់ខ្ញុំធ្វើជាប៉ូលីសនៅផ្ទះក្បែរវត្តបុទុមដដែល។ ក្រោយមក ខ្ញុំបានប្តូរទៅរស់នៅជាមួយបងបង្កើតរបស់ខ្ញុំនៅក្បែរពោធិ៍ចិនតុងវិញ មុនពេលដែលខ្ញុំត្រូវវិលត្រឡប់មកកាន់ស្រុកកំណើតខាងម្តាយចិញ្ចឹមខ្ញុំវិញ។ ខ្ញុំមានបងប្អូនប្រាំពីរនាក់។ ខ្ញុំជាកូនពៅក្នុងគ្រួសារ។ បងប្រុសច្បង ធ្វើប៉េអឹមពាក់សក្តិ៥។ បងប្រុសទី២ ធ្វើប៉េអឹមពាក់សក្តិ៤ និងបងទី៣ ពាក់សក្តិ៣។ ដោយសារតែខ្ញុំមានបងប្អូនធ្វើការនៅក្នុងជំនាន់សម្តេច និងជំនាន់ លន់ នល់ (ខ្មែរក្រហម) ដាក់ខ្ញុំនៅក្នុងប្រភេទប្រជាជន១៧ មេសា។

នៅឆ្នាំ១៩៧០ ម្តាយចិញ្ចឹមខ្ញុំបានរៀបចំខ្ញុំឲ្យមានប្តី។ កាលនោះខ្ញុំទើបតែមានអាយុ១៦ឆ្នាំប៉ុណ្ណោះ។ ខ្ញុំបានប្រកែកមិនព្រមយកប្តីទេ ប៉ុន្តែម្តាយចិញ្ចឹមខ្ញុំវាយខ្ញុំ និងបង្ខំខ្ញុំរហូតទាល់តែខ្ញុំយល់ព្រម។ បន្ទាប់ពីបានរៀបការរួច ខ្ញុំបានមករស់នៅភូមិនេះ (ភូមិបេង) ជាភូមិកំណើតរបស់ប្តីខ្ញុំ។ ពួកយើងគ្មានធ្វើអ្វីក្រៅពីធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិតឡើយ។ យើងធ្វើការនៅក្នុងស្រុកភូមិរហូតទាល់តែដល់ថ្ងៃជ័យជម្នះ ១៧ មេសា ១៩៧៥។ ក្នុងចំណោមកិច្ចការទាំងនោះ កិច្ចការដែលពិបាកជាងគេគឺសែងខ្មោចនិងអ្នករបួសចេញពីសមរភូមិ។ នៅឆ្នាំ១៩៧៤ ក្រៅពីធ្វើស្រែ ខ្ញុំនិងក្រុមនារីខ្លះទៀតនៅក្នុងភូមិបេងបានទទួលបញ្ជាឲ្យសែងទាហានរបួស និងអ្នកស្លាប់នៅក្នុងសមរភូមិត្រពាំងព្រាមជិតព្រំប្រទល់វៀតណាម មកដាក់ក្នុងបរិវេណវត្តព្រៃពោន នៅកអណ្តើក និងនៅទួលម្រេញ។ ក្នុងពេលធ្វើកិច្ចការនេះ ខ្ញុំមានកំហឹងជាខ្លាំងជាមួយកម្មាភិបាលមូលដ្ឋាន ព្រោះបានប្រើខ្ញុំគ្មានពេលសម្រាក។ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ខ្ញុំមានកូនបីនាក់។ ពួកយើងរស់នៅ និងហូបចុកធម្មតា។ ប៉ុន្តែបងប្រុសស្រីរបស់ខ្ញុំដែលធ្លាប់ធ្វើជាប៉ូលីសក្នុងរបបមុនៗ ត្រូវពួកខ្មែរក្រហមសម្លាប់ចោលគ្មានសល់ម្នាក់ទេ។ នៅថ្ងៃមួយ ខ្ញុំភ្លេចឆ្នាំ ឈ្លបបានមកចាប់ខ្ញុំយកទៅដាក់គុកមួយយប់មួយថ្ងៃ ដោយសារតែកូនប្រុសរបស់ខ្ញុំបានធ្វើឲ្យបែកចានបាយមួយ។ អាផុន និងបងប្អូនខាងប្តីខ្ញុំដែលជាប្រធានសហករណ៍ឈ្មោះអៀង និងភាព គឺជាអ្នកចាប់ខ្ញុំ និងបង្អត់បាយខ្ញុំមួយថ្ងៃមួយយប់។ អ្នកទាំងនោះក៏ជាអ្នកដែលបានធ្វើឲ្យបងប្អូនខ្ញុំស្លាប់ដែរ។ ខ្ញុំខឹងខ្លាំងណាស់ ខឹងរហូតដល់សព្វថ្ងៃ។ នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវជម្លៀសទៅកាន់ខេត្តពោធិ៍សាត់។ នៅទីនោះ ខ្ញុំវេទនាណាស់។ មិនដែលបានហូបឆ្អែតឡើយ។ ថ្ងៃមួយ ខ្ញុំដើរទៅដល់កន្លែងមួយឈ្មោះ បុស្ស១០០គុម្ព ស្ថិតក្នុងឃុំអន្លង់វិល ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ដើម្បីបេះអំពិលទឹកហូប។ ខ្ញុំបេះបានមួយបង្វិច ក៏ត្រឡប់មកវិញ។ ពេលត្រឡប់មកវិញ ខ្ញុំដើរផ្លូវវៀង ហើយក៏បានប្រទះឃើញសាកសពគរលើគ្នាយ៉ាងច្រើន មានទាំងចាស់ទាំងក្មេង។ ខ្ញុំឃើញដើមអំពិលទឹកធំមួយដែលខ្មែរក្រហមប្រើប្រាស់ជាកន្លែងបោកក្មេងតូចៗឲ្យស្លាប់។ ខ្ញុំបោះចោលផ្លែអំពិលទឹកដែលខ្ញុំបេះបានទាំងអស់ចោលវិញ ហើយខ្ញុំលែងហ៊ានបេះផ្លែឈើអ្វីទៀតហូបចាប់តាំងពីពេលនោះមក។ ក្រៅពីនេះ ខ្ញុំធ្លាប់បានឃើញជនជាតិចិនរាប់រយនាក់មកប្រជុំនិងជប់លៀង

នៅក្នុងឃុំអន្លង់វិល។ ខ្ញុំត្រូវអង្គការឲ្យនៅហាន់សាច់គោធ្វើម្ហូបសម្រាប់កម្មវិធីជប់លៀងពួកចិនៗទាំងនោះ ហើយត្រូវនៅចាំលាងចានក្រោយពេលពួកចិនៗទាំងនោះចាកចេញទៅ។ ខ្ញុំឃើញច្បាស់នឹងភ្នែកខ្ញុំៗ អ្នកទាំងនោះនិយាយភាសាចិន មិនដឹងថានិយាយពីអ្វីទេ។ ក្រោយពីជប់លៀងរួច ចិនៗទាំងនោះត្រឡប់ទៅវិញអស់។ ខ្ញុំមិនដឹងថាជនជាតិចិនហ្នឹងទៅណាទេ គ្រាន់តែដឹងថាចេញពីឃុំអន្លង់វិលទៅដោយថ្មើរជើង។ ដើមឆ្នាំ១៩៧៩ ខ្ញុំ ប្តីខ្ញុំ និងកូនខ្ញុំបីនាក់ បានវិលត្រឡប់មកកាន់ស្រុកកំណើតវិញ។ ក្រោយពីមកដល់ស្រុកកំណើតនៅឆ្នាំ១៩៧៩ភ្លាម ខ្ញុំស្នើសុំរដ្ឋអំណាចចូលធ្វើទាហាន ដើម្បីបានមកសងសឹកចំពោះអ្នកដែលបានចាប់ខ្ញុំយកទៅដាក់គុក និងបានសម្លាប់បងប្អូនរបស់ខ្ញុំ ប៉ុន្តែម្តាយខ្ញុំឃាត់មិនឲ្យទៅ។ អាផុន ត្រូវប្រជាជនបាញ់សម្លាប់ចោលនៅខាងជើងឃុំព្រៃពោន។ ចំណែកបងប្អូនខាងប្តីខ្ញុំ នៅរស់ដល់សព្វថ្ងៃ ហើយស្ថិតនៅក្នុងភូមិជាមួយគ្នាទៀត។ ខ្ញុំមិនអាចធ្វើអ្វីគេបានទេ។ ក្រោយមក ខ្ញុំមិនចាំឆ្នាំ ម្តាយបង្កើតរបស់ខ្ញុំបានស្លាប់ដោយសារចាស់ជរា។ ប្តី និងបងប្រុសរបស់ខ្ញុំម្នាក់ទៀត បានស្លាប់ដោយសារជំងឺក្នុងឆ្នាំតែមួយ។ ខ្ញុំត្រូវនៅមើលថែ និងរកស៊ីចិញ្ចឹមកូនបង្កើតទាំង៩នាក់តែម្នាក់ឯង។ ខ្ញុំបានដើរសុំទានគេដើម្បីរកប្រាក់ចិញ្ចឹមគ្រួសារ រហូតដល់ខ្ញុំអាចសន្សំបានប្រាក់ខ្លះៗដើម្បីធ្វើផ្ទះនាពេលបច្ចុប្បន្ននេះ។ ខ្ញុំខស្រាហ៍ឈឺណាស់ ហើយខ្ញុំចង់ទៅពិនិត្យសុខភាព ដើម្បីខ្ញុំបានដឹងថា តើខ្ញុំមានជំងឺអ្វីខ្លះ» ។

---

## ៣. មុំ ណាំ

មុំ ណាំ អាយុ៦៣ឆ្នាំ រស់នៅភូមិបេង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ណាំ មិនបានរៀនសូត្រឡើយ។ គាត់ស៊ីឈ្នួលដកសំណាប ស្ទូង និងច្រូតស្រូវឲ្យអ្នកភូមិជាមួយគ្នា ដើម្បីរកចំណូលខ្លះចិញ្ចឹមឪពុកម្តាយ។ ណាំ មានបងប្អូន៥នាក់។ បងប្រុសទាំង៤របស់ ណាំ បានស្ម័គ្រចិត្តចូលបម្រើក្នុងកងកម្លាំងបដិវត្តន៍ និងបានចាកចេញពីផ្ទះសម្បែងទៅរស់នៅជាមួយកងកម្លាំងខ្មែរក្រហមនៅក្នុងព្រៃ។ ក្រោយថ្ងៃជ័យជម្នះរបស់ខ្មែរក្រហមក្នុងខែមេសា ឆ្នាំ១៩៧៥ ណាំ ត្រូវកម្មាភិបាលខ្មែរក្រហមថ្នាក់ប្រធានកងពល នាំយកទៅកាន់ខេត្តស្ទឹងត្រែងដើម្បីដាំដំណាំ និងដាំកប្បាស។ នៅទីនោះបានប្រហែលមួយឆ្នាំ ណាំ ត្រូវអង្គការផ្លាស់ប្តូរឲ្យមកកាន់ខេត្តកំពង់ចាម។ ប៉ុន្មានខែក្រោយមក គាត់ក៏ត្រូវបានចាត់តាំងឲ្យមកធ្វើជាកម្មករស្រែអំបិលនៅខេត្តកំពត ជាកន្លែងដែលគាត់ធ្វើការ និងស្នាក់នៅយូរជាងពេលមុនៗ និងជាកន្លែងចុងក្រោយដែលគាត់បានរត់គេចខ្លួនទៅកាន់ខេត្តកំពង់ស្ពឺ និងពោធិ៍សាត់ នៅចុងឆ្នាំ១៩៧៨។ ណាំ មានអនុស្សាវរីយ៍ជូរចត់ច្រើនក្នុងពេលដែលគាត់ធ្វើការនៅស្រែអំបិល រួមទាំងការធ្វើការហួសកម្លាំង ការស្នាក់នៅ ការបែកបាក់ក្រុមគ្រួសារ និងការបំបិទសិទ្ធិសេរីភាព។ ភ្លាមៗបន្ទាប់ការដួលរលំរបបខ្មែរក្រហម ណាំ និងកម្មករស្រែអំបិលដែលសុទ្ធតែស្រីៗ បានរត់គេចខ្លួនតាមការនាំផ្លូវពីកម្មាភិបាលខ្មែរក្រហមដែលមានតួនាទីជា ប្រធាន «ឃ» ម្នាក់ គាត់តាមភ្នំប្រមុះជ្រូក និងភ្នំឱរ៉ាល់ ខេត្តកំពង់ស្ពឺ រហូតដល់ខេត្តពោធិ៍សាត់។



មុំ ណាំ អាយុ៦៣ឆ្នាំ រស់នៅភូមិបេង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
(ដេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ណាំ បានចំណាយពេលជាងពីរខែក្នុងការរត់ភៀសខ្លួន និងការវិលត្រឡប់មកកាន់ស្រុកកំណើតវិញនៅដើមឆ្នាំ១៩៧៩។ មកដល់ស្រុកកំណើត ណាំ ត្រូវឪពុកម្ដាយឲ្យរៀបការជាមួយបងប្អូនជីដូនមួយរបស់គាត់ ហើយបានរួមរស់ជាមួយគ្នារហូតដល់សព្វថ្ងៃ។ ណាំមិនមានកូនទេ។ គាត់រស់នៅជាមួយប្ដីរបស់គាត់តែពីរនាក់ នៅក្នុងផ្ទះតូចល្មមមួយក្នុងភូមិបេង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ប្ដីរបស់ ណាំ បានធ្លាក់ខ្លួនឈឺ និងថ្លង់រហូតដល់សព្វថ្ងៃ។ ការរស់នៅរបស់ ណាំ និងប្ដី គឺត្រូវពឹងពាក់លើកម្លាំងផ្ទាល់ខ្លួន និងអំណោយពីបងប្អូននិងអ្នកជិតខាង។ សូមស្ដាប់សម្ដីរបស់ ណាំ ដូចខាងក្រោម៖

«ឪពុកម្ដាយខ្ញុំស្លាប់អស់ហើយ គឺស្លាប់នៅជំនាន់នេះទេ។ ម្ដាយស្លាប់ដោយសារខ្យល់គរ ហើយឪពុកស្លាប់ដោយចាស់ជរា។ ខ្ញុំគ្មានកូននឹងគេទេ។ ខ្ញុំមានបងប្អូន៥នាក់។ បងប្រុសច្បងនិងបងប្រុសបន្ទាប់របស់ខ្ញុំ ស្លាប់ក្នុងពេលប្រយុទ្ធគ្នានៅសមរភូមិត្រពាំងព្រាមកាលពីជំនាន់ប៉ុលពត។ បងប្រុសម្នាក់ទៀតស្លាប់ក្នុងជំនាន់នេះទេ គឺកាលពី៩ឆ្នាំមុន។ ខ្ញុំមិនដែលបានរៀនសូត្រនឹងគេទេ។ នៅពីតូច ខ្ញុំដើរស៊ីឈ្នួលដកកណ្ដាប់ និងស្ទូងឲ្យគេ។ នៅអាយុ១២ឆ្នាំ ផ្ទះរបស់ខ្ញុំត្រូវបំផ្លាញដោយការទម្លាក់គ្រាប់បែក។ យើងក្រណាស់ យើងស្នាក់នៅក្នុងកូនខ្ទមមួយ ទំហំប៉ុនរោងបាយខ្ញុំសព្វថ្ងៃនេះ។ នៅអាយុ១៥ឆ្នាំ ខ្មែរក្រហមមកយកខ្ញុំចេញពីផ្ទះទៅ។ ពេលនោះគឺបន្ទាប់ពីខែមេសា ១៩៧៥ ខ្ញុំត្រូវមេៗដែលជាកម្មាភិបាលពេទ្យ និងប្រធានកងពល មកស្នើសុំខ្ញុំយកទៅធ្វើការនៅស្ទឹងត្រែង។ ខ្ញុំដាំពោត សណ្ដែក ធ្វើដី និងដាំកប្បាស។ ខ្ញុំបានហូបឆ្អែតរាល់ថ្ងៃ។ ខ្ញុំត្រូវបានកម្មាភិបាលធំៗឲ្យធ្វើប្រវត្តិរូប។ ខ្ញុំធ្វើប្រវត្តិរូបលើកទីមួយ ហើយសម្រាប់ជីវិតខ្ញុំ។ ខ្មែរក្រហមសួរខ្ញុំថា មានបងប្អូនប៉ុន្មាននាក់ និងធ្វើអ្វីខ្លះ? ខ្ញុំប្រាប់ថា បងប្អូនខ្ញុំប្រាំនាក់ធ្វើការក្នុងរបបខ្មែរក្រហមទាំងអស់។ បងគេបង្អស់ ធ្វើជាមេបញ្ជាការកងទ័ពខ្មែរក្រហម។ បងបន្ទាប់ ធ្វើជាប្រធាន «យ» ហើយបងទី៣ ធ្វើជាអនុប្រធាន «យ»។ ខ្ញុំនៅស្ទឹងត្រែងអស់រយៈពេលជាងមួយឆ្នាំ ទើបត្រូវអង្គការផ្លាស់ប្ដូរឲ្យមកធ្វើការនៅកំពង់ចាម មុនពេលដែលអង្គការផ្លាស់ប្ដូរខ្ញុំម្ដងទៀត មកកាន់ភ្នំពេញ។ ខ្ញុំមកភ្នំពេញជាមួយនារីៗប្រហែល២០០នាក់។ មកដល់ភ្នំពេញភ្លាម អង្គការចាត់តាំងខ្ញុំឲ្យធ្វើពេទ្យនៅមន្ទីរពេទ្យមួយស្ថិតនៅភាគខាងជើងវត្តភ្នំ។ នៅទីនោះ ខ្ញុំបានធ្វើឲ្យបុរសម្នាក់ស្លាប់ដោយសារតែការចាក់ថ្នាំរបស់ខ្ញុំ។ គាត់មានជំងឺគ្រុនចាញ់។ ខ្ញុំមិនមានការតក់ស្លុតអ្វីបន្តិចទេ ទោះបីជាដឹងថាបុរសម្នាក់នោះបានស្លាប់ដោយសារតែការធ្វេសប្រហែសរបស់ខ្ញុំក៏ដោយ។ ខ្ញុំបានទម្លាក់កំហុសគ្រប់យ៉ាងទៅលើប្រធានរបស់ខ្ញុំឈ្មោះ ដារ៉ា ដែលគាត់បានបណ្ដោយឲ្យខ្ញុំចាក់ថ្នាំឲ្យបុរសម្នាក់នោះ។ ខ្ញុំនៅធ្វើការនៅក្នុងមន្ទីរពេទ្យនៅភ្នំពេញបានតែមួយខែប៉ុណ្ណោះ ក៏ត្រូវអង្គការបញ្ជូនខ្ញុំឲ្យមកធ្វើជាកម្មករស្រែអំបិលនៅខេត្តកំពតបន្តទៀត។

ខ្ញុំគិតថា ប្រហែលជាខ្ញុំបានប្រព្រឹត្តកំហុសហើយ បានជាអង្គការបញ្ជូនខ្ញុំមកឆ្ងាយយ៉ាងដូច្នេះ។ ខ្ញុំ និងយុវនារីជាច្រើននាក់ទៀត បានជិះរថភ្លើងចេញពីភ្នំពេញ ឆ្ពោះមកកាន់ខេត្តកំពត។ ទៅដល់ស្រែអំបិលខេត្តកំពត ខ្ញុំត្រូវអង្គការឲ្យធ្វើប្រវត្តិរូបម្ដងទៀត។ អង្គការសួរសំណួរខ្ញុំដដែលដូចកាលពីនៅស្ទឹងត្រែងអ៊ីចឹង ហើយខ្ញុំនៅតែឆ្លើយប្រាប់អង្គការដូចដែលខ្ញុំបានប្រាប់កាលពីខ្ញុំនៅធ្វើការឯខេត្តស្ទឹងត្រែងដែរ។ កម្មករស្រែអំបិលទាំងអស់មានអាយុមិនដូចគ្នាទេ។ អ្នកខ្លះចាស់ជាងខ្ញុំ ខ្លះក្មេងជាងខ្ញុំ។ នៅទីនោះ យើងបានហូបចុកគ្រប់គ្រាន់ តែយើងពិបាករឿងធ្វើការហួសកម្លាំង។ ជារៀងរាល់ល្ងាច តែងតែមានការប្រជុំកើតឡើងដើម្បីទិតៀនគ្នាពីរឿងធ្វើការងារ។ ខ្ញុំត្រូវប្រធានកងស្ដីបន្ទោសរាល់ថ្ងៃ ព្រោះខ្ញុំតូចជាងគេ ហើយខ្ជិលថែមទៀត។ ក្រៅពីខ្ញុំក៏មានអ្នកផ្សេងទៀតដែរដែលត្រូវស្ដីបន្ទោស។ ដោយសារតែការស្ដីបន្ទោសនេះ នារីម្នាក់បានចងករសម្លាប់ខ្លួននៅក្នុងឃ្លាំងអំបិល។ នារីនោះមានស្រុកកំណើតនៅខេត្តកំពង់ស្ពឺ។ ជារៀងរាល់ថ្ងៃ ខ្ញុំសង្កេតឃើញមានឡានធំៗចំនួនពីរគ្រឿង

តែងតែចូលមកដឹកអំបិលចេញទៅ ប៉ុន្តែខ្ញុំមិនដឹងថា ឡាននោះដឹកអំបិលចេញទៅណាឡើយ។ កម្មករស្រែអំបិលទាំងអស់សុទ្ធតែនារីៗ នៅពេលបានឃើញអ្នកបើកឡានចូលមកដឹកអំបិលគឺជាបុរស យើងនាំគ្នាឈរមើលគ្រប់គ្នា។ ខ្ញុំស្នាក់នៅជាមួយកម្មករម្នាក់ទៀតក្នុងបន្ទប់មួយ។ យើងគ្មានមុងភួយដណ្តប់ទេ។ ស្ទើរតែរាល់យប់ យើងតែងតែងើបពីម៉ោង១យប់ទៅចាប់ត្រីដើម្បីទុកធ្វើម្ហូបប្រចាំថ្ងៃ ហើយត្រឡប់មកដេកវិញនៅម៉ោងប្រហែលបីទៀបភ្លឺ។ នៅម៉ោង៦ព្រឹក យើងងើបឡើងតាមសំឡេងជួង ទៅធ្វើការនៅក្នុងស្រែអំបិល រហូតដល់ម៉ោង១១កន្លះ ទើបសម្រាកហូបបាយ។ ម៉ោង១២ថ្ងៃត្រង់ យើងចាប់ផ្តើមការងារទៀតរហូតដល់៤រសៀល ទើបឈប់សម្រាកអាហារពេលល្ងាច។ បន្ទាប់ពីបាយល្ងាចរួច យើងបានសម្រាកតែប្រមាណ២ម៉ោងប៉ុណ្ណោះ ក៏ត្រូវចេញទៅធ្វើការនៅពេលយប់ទៀត តាមសំឡេងជួងដែលបានបន្លឺឡើង។ នៅវេលាម៉ោង៨យប់ ទើបយើងទាំងអស់គ្នាបានឈប់សម្រាក។ តាំងពីខ្ញុំចូលធ្វើការនៅស្រែអំបិលមក ខ្ញុំមិនដែលឃើញនរណាមកទស្សនកិច្ចនៅស្រែអំបិលឡើយ ហើយក៏មិនដែលឃើញមានការចាប់ខ្លួននារីស្រែអំបិលណាម្នាក់យកទៅកសាងបុសម្ពាប់ដែរ។ ខ្ញុំធ្វើការនៅស្រែអំបិល បានតែរយៈពេលជិតមួយឆ្នាំប៉ុណ្ណោះ ក៏ត្រូវរត់ភៀសខ្លួនទៅកាន់ខេត្តកំពង់ស្ពឺ និងខេត្តពោធិ៍សាត់ តាមការនាំផ្លូវរបស់កម្មាភិបាលខ្មែរក្រហមម្នាក់ដែលជាប្រធាន«យ»។ ដំបូងឡើង ខ្ញុំភៀសខ្លួនទៅកាន់ភ្នំប្រមុះជ្រូក រួចបន្តទៅភ្នំឱរ៉ាល់។ ការធ្វើដំណើររបស់ខ្ញុំគឺចំណាយពេលអស់រយៈពេល១៥ថ្ងៃ។ ពូប្រធាន«យ» ម្នាក់ដែលខ្ញុំមិនស្គាល់ឈ្មោះ បាននាំផ្លូវយើងឡើងភ្នំ និងចុះភ្នំមកកាន់ស្រុកកំណើត។ គាត់មានត្រីវិស័យមួយដែលអាចមើលទិសដៅដឹង ហើយនាំយើងមកផ្ទះ។ មកដល់ស្រុកកំណើត ខ្ញុំបានជួបជុំគ្រួសារ និងបានរៀបការជាមួយប្តីរបស់ខ្ញុំដែលត្រូវជាបងប្អូនខាងម្តាយខ្ញុំ។ យើងបានរស់នៅជាមួយគ្នារហូតដល់សព្វថ្ងៃនេះ តែយើងគ្មានកូនទេ។ សព្វថ្ងៃ យើងរស់នៅដោយមានបងប្អូននិងអ្នកជិតខាងជួយខ្លះៗ។

## ៤. អ៊ុយ អង

អ៊ុយ អង អាយុ៦២ឆ្នាំ សព្វថ្ងៃរស់នៅភូមិបេង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ឪពុកម្តាយរបស់ អង ប្រកបរបរធ្វើស្រែចម្ការ និងធ្វើនំលក់ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ ក្នុងសម័យលន់ នល់ អង មិនបានចូលរៀនដូចបងប្រុសរបស់ខ្លួននោះទេ ដោយសារតែជីវភាពខ្វះខាត និងមានសង្គ្រាម។ នៅពេលដែលអាយុ១៥ឆ្នាំ អង ចាប់ផ្តើមចូលរៀនជាមួយក្មេងៗផ្សេងទៀតនៅក្នុងភូមិ ក្រោមការគ្រប់គ្រងរបស់អង្គការ។ ក្មេងៗអាយុដំណាល អង ទាំងអស់តម្រូវឲ្យចូលរៀននៅពេលព្រឹក ចំណែកពេលរសៀលតម្រូវឲ្យធ្វើការងារផ្សេងៗ ដូចជាស្ទូងដកប្រូតកាត់ ប្រមូលជី រែកដីដំបូកឬក៏ ជីបាតស្រះ ទៅតាមរដូវកាល។ ក្រៅពីការសិក្សា និងធ្វើការ អង ត្រូវបានគ្រូបង្រៀនជ្រើសរើសឲ្យចូលក្នុងសិល្បៈកុមារ និងមានច្រៀងចម្រៀងបដិវត្តន៍។ ក្រុមរបស់ អង ដែលមានសមាជិក១០នាក់(ស្រី៥នាក់) ច្រៀងចម្រៀងបដិវត្តន៍ តាមការបង្ហាត់បង្ហាញពីឈ្មោះ ស៊ុំ នួន ដែលជាគ្រូបង្រៀនសិល្បៈរបស់ក្មេងៗ។ អង បានបន្ថែមទៀតថា អ្នកគ្រូ ស៊ុំនួន បង្រៀនចម្រៀង



អ៊ុយ អង អាយុ៦២ឆ្នាំ សព្វថ្ងៃរស់នៅភូមិបេង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
(ផេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ម្តង១ឬក៏២បទដល់ក្មេង បន្ទាប់ពីចេះច្រៀងទាំងអស់គ្នា ទើបលើកយកពីរបទមកទៀត។ នៅក្នុងភូមិបេង ប្រធានសិល្បៈឈ្មោះ ខែម និងអនុប្រធានឈ្មោះ យឿន គឺជាអ្នកមើលការខុសត្រូវ នឹងរៀបចំឲ្យមានការសម្តែងម្តងៗ។ នៅអាយុ១៦ឆ្នាំ អង្គការបានបញ្ជូនឲ្យក្រុមរបស់ អង ចូលទៅធ្វើជាយោធានារីព្រំដែនប៉ុន្តែ អង មិនបានទៅជាមួយគេទេ ដោយសារមូលហេតុម្តាយឈឺ។ បន្ទាប់មកទៀត អង ត្រូវបានអង្គការបញ្ជូនឲ្យចូលទៅធ្វើការនៅក្នុងកងចល័តឃុំព្រៃពោន និងចេញធ្វើការឆ្ងាយៗពីភូមិ។ ការងារនៅក្នុងក្រុមចល័តតែងតែផ្លាស់ប្តូរពីមួយទៅមួយ គឺលើកទំនប់ ជីកប្រឡាយប្រព័ន្ធភ្លឺស្រែ ជីកសណ្តរផ្សេងៗ។ ចំណែកនៅរដូវវស្សា គឺធ្វើការងារដូចជាស្ទូងដក ប្រូតស្រូវ និងមានការផ្លាស់ប្តូរវេនគ្នាធ្វើចុងភៅ។ បន្ទាប់ពី អង ធ្វើការនៅក្នុងកងចល័តអស់រយៈពេល៣ឆ្នាំ ក៏មានកងទ័ពវៀតណាមចូលមកដេញខ្មែរក្រហមឲ្យចេញពីស្រុកកំពង់ត្របែក។ នៅក្នុងឆ្នាំ១៩៧៩ ខ្មែរក្រហមបានចាញ់សង្គ្រាមហើយ អង ក៏បានត្រឡប់មករស់នៅជាមួយម្តាយរបស់ខ្លួនវិញ និងបានរៀបការមានកូនរហូតដល់សព្វថ្ងៃ។ បច្ចុប្បន្នចម្រៀងដែល អង នៅចាំជាងគេគឺមានពីរបទគឺ ឈាមក្រហមឆ្អៅ និងបទគ្រាប់បែកៗផ្សេងពេញភូមិ ហើយជាញឹកញាប់ អង បានច្រៀងចម្រៀងទាំងពីរបទនេះឲ្យទៅចៅៗរបស់ខ្លួនស្តាប់។

## ៥. សូ ពោន



សូ ពោន អាយុ៨៥ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិជីអក ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
(ភារស្មី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

សូ ពោន អាយុ៨៥ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិជីអក ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ពោន គឺជាអ្នកចេះដឹងមួយរូបនៅក្នុងភូមិ។ គាត់បានធ្វើជាមេស្វាយត្រាន គ្រប់គ្រងភូមិឃុំព្រៃពោនទាំងមូលនៅក្នុងស្រុកកំពង់ត្របែក។ ពោន បានបញ្ជាក់ទៀតដែរថា គាត់បានធ្វើកិច្ចការងារនេះរហូតដល់ថ្ងៃដែលសម្តេចព្រះ នរោត្តម សីហនុ ត្រូវបានសេនាប្រមុខ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់នៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ទើបគាត់ឈប់ធ្វើ ហើយត្រឡប់មកធ្វើស្រែធម្មតាវិញ។ ចូលមកដល់របបកម្ពុជាប្រជាធិបតេយ្យ ពោន បានរៀបរាប់ឲ្យដឹងថា ខ្មែរក្រហមបានប្រើឲ្យគាត់ និងមនុស្សជាច្រើននាក់ទៀត ធ្វើការទាំងថ្ងៃទាំងយប់ ហើយមិនមានបាយសម្រាប់ឲ្យគាត់និងអ្នកឯទៀតដែរ គឺហូបតែបបររាវរាល់ថ្ងៃ។ រីឯដំណាំហូបផ្លែដែលគាត់បានដាំនៅផ្ទះរបស់គាត់ ក៏គាត់គ្មានសិទ្ធិនឹងបេះយកមកហូបដែរ។ នៅក្នុងសម័យខ្មែរក្រហម ការងារដំបូងដែលខ្មែរក្រហមបានប្រើឲ្យគាត់ធ្វើនោះ គឺកាន់នង្គ័លចំនួន៣សម្រាប់រាស់ដីធ្វើស្រែនៅបឹងក្រទឹប។ ក្រៅពីការងាររាស់ដី ខ្មែរក្រហមបានប្រើឲ្យពោន ស្ទូងស្រូវ ឃ្វាលក្របី ជីកប្រឡាយ និងធ្វើទំនប់។ មានថ្ងៃមួយខណៈពេលដែលកំពុងតែជីកទំនប់ ពោន បានឃើញនារីម្នាក់កំពុងតែសែងដី ស្រាប់តែរអិលជើងធ្លាក់ចុះមកក្រោម ហើយបានស្លាប់នៅទីនោះតែម្តង ដោយសារទំនប់ខ្ពស់ពេកឡើងពុំរួច។ ពោនបានបន្ថែមទៀតដែរថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មនុស្សគ្រប់គ្នាត្រូវតែធ្វើការងារជារៀងរាល់ថ្ងៃ ដោយមិនមាននរណាទំនេរឡើយ (លើកលែងតែឈឺធ្វើការមិនកើត) បើមិនធ្វើការទេ គឺនឹងត្រូវបានបង្អត់បាយ ហើយ ជាក់ស្តែងគាត់ផ្ទាល់ក៏ត្រូវបានខ្មែរក្រហមបង្អត់បាយមួយពេលដែរ ដោយសារតែគាត់មិនបានទៅធ្វើការនៅពេល

ព្រឹកដោយអាងថាខ្លួនបានធ្វើការពីល្ងាចរួចរាល់អស់ហើយ។ នៅក្នុងរបបខ្មែរក្រហម ពោនទសប្រាហ៍ត្រូវបានប្រធានកង់ទិតៀនណាស់ទៅលើរឿងការងារ និងរឿងហូបចុករបស់គាត់ខុសទៅនឹងគោលការណ៍របស់ខ្មែរក្រហម។ នៅចុងឆ្នាំ១៩៧៨ ក្រុមគ្រួសាររបស់ ពោន ត្រូវបានខ្មែរក្រហមជម្លៀសទៅ ខាងពោធិ៍សាត់។ កូនរបស់ ពោន ២នាក់ បានស្លាប់នៅទីនោះដោយសារកើតជំងឺកញ្ជ្រឹល ។ ក្នុងរយៈពេលដែលនៅពោធិ៍សាត់ ពោន ខិតខំធ្វើការងារណាស់ ដើម្បីឲ្យប្រធានសហករណ៍មើលឃើញថា ខ្លួនអាចធ្វើការងារបានយ៉ាងច្រើនតាមការបញ្ជារបស់ប្រធានសហករណ៍ហើយ នឹងមិនបញ្ជូនខ្លួននិងគ្រួសារឲ្យបន្តទៅមុខទៀតដើម្បីយកទៅសម្លាប់។ ពោន និងគ្រួសារបានត្រឡប់មកផ្ទះវិញ នៅពេលដែល កងទ័ពវៀតណាមបានចូលទៅដល់តំបន់ដែលគាត់ត្រូវបានគេជម្លៀសនោះ នៅខែមករា ឆ្នាំ១៩៧៩ (មិនចាំថ្ងៃ)។ ក្រោយថ្ងៃខ្មែរក្រហមដួលរលំ នៅក្នុងភូមិឃុំរបស់ ពោន ក៏បានចាប់ផ្តើមរៀបចំរចនាសម្ព័ន្ធ ភូមិឃុំឡើងវិញ ដោយផ្តល់អត្ថិភាពឲ្យប្រជាជនមានសិទ្ធបោះឆ្នោតជ្រើសរើសតំណាង ដែលខ្លួនពេញចិត្ត ហើយ ពោន ក៏ត្រូវប្រជាជនបោះឆ្នោតឲ្យជាប់ធ្វើជាអនុប្រធានឃុំដែរនៅពេលនោះ។ ពោន បានធ្វើជាអនុប្រធានឃុំដល់ឆ្នាំ១៩៩៣ ទើបគាត់លាលែងពីការងារ ហើយមកធ្វើជាកសិករធ្វើស្រែតាំងពីពេលនោះមក។ សព្វថ្ងៃ ពោន រស់នៅក្រោមការមើលថែយ៉ាងដិតដល់ពីកូនស្រីពៅរបស់គាត់។

## ៦. ទិត្យ ហាក់

ទិត្យ ហាក់ អាយុ៦៧ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិជីអក ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ កាលពីដើមឡើយ ទិត្យ ហាក់ រស់នៅភូមិជីពាយ។ គាត់បានផ្លាស់មករស់នៅ ភូមិជីអក ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង នៅពេលដែលគាត់បានរៀបការជាមួយនឹងភរិយារបស់គាត់នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៧៧។ សព្វថ្ងៃ ទិត្យ ហាក់ ពិការមួយចំហៀងខ្លួន។ មូលហេតុដែលធ្វើឲ្យគាត់ពិការមួយចំហៀងខ្លួន គឺដោយសារតែ កាលពី១០ឆ្នាំមុននោះ គាត់បានលើសឈាម ហើយខ្យល់គរ ទើបធ្វើឲ្យគាត់ស្ថិតនៅក្នុងសភាពយ៉ាប់យ៉ឺនបែបនេះ។ ជារៀងរាល់ថ្ងៃ ហាក់ ពិបាកក្នុងការដើរ និងធ្វើដំណើរណាស់ គាត់កាន់ឈើច្រត់មួយសម្រាប់ទប់លំនឹងខ្លួនរបស់គាត់។ កាលនៅពីតូច ក្នុងចំណោមបងប្អូនទាំង៦នាក់របស់គាត់ស្លាប់អស់ម្នាក់ហើយ ហាក់ គឺជាកូនដែលរៀនបានខ្ពង់ខ្ពស់ជាងគេ។ ហាក់ បានចូលរៀនដំបូងនៅឆ្នាំ១៩៦៣ នៅអាយុ៦ឆ្នាំ នៅសាលាវត្តបេង ពីថ្នាក់ទី១២ ដល់ ថ្នាក់ទី៩ និង នៅសាលាវត្តព្រៃពោន ពីទីថ្នាក់៨ ដល់ទី៧។ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ មក ហាក់ ក៏លែងបានរៀនតទៅទៀត ដោយសារស្រុកកើតមានសង្គ្រាម រីឯសាលាក៏ត្រូវបានបិទទាំងអស់ដែរ។ ស្ថិតនៅក្នុងសភាពការណ៍ពេលនោះ ហាក់ និងគ្រួសារ ព្រមទាំងអ្នកផ្សេងទៀតនាំគ្នាចាកចេញពីផ្ទះ គេចពីសង្គ្រាម និងគេចពីទាហានធីវគី ដើម្បីទៅរកកន្លែងតំបន់សុវត្ថិភាពនៅឃុំពាមមន្ទារ និងទីកន្លែងសុវត្ថិភាពផ្សេងៗទៀត។ ដោយសារ ហាក់ នៅតែមានចិត្តចង់រៀនសូត្របន្តនោះ គាត់ក៏បានសម្រេចចិត្តរត់ទៅរស់នៅទីក្រុងភ្នំពេញមួយរយៈ ដើម្បីបានរៀនសូត្រ និងដើម្បីរត់ចេញពីសង្គ្រាមនៅឆ្នាំ១៩៧២។ ហាក់បាននិយាយថា នៅទីក្រុងភ្នំពេញ



ទិត្យ ហាក់ អាយុ៦៧ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិជីអក ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

គឺមានសភាពស្ងប់ស្ងាត់គួរឲ្យចង់រស់នៅ មិនដូចជានៅស្រុកកំណើតឡើយ។ ហាក់បានទៅស្នាក់នៅជាមួយអ៊ំប្រុសរបស់គាត់ឈ្មោះ ញែម ឯក ដែលដែលធ្វើការនៅទូតបារាំង។ ដោយមិនចង់ក្លាយជាបន្ទុករបស់អ៊ំប្រុសរបស់ខ្លួនតទៅទៀត មួយឆ្នាំក្រោយមក ហាក់ក៏បានចេញរកស៊ីធាក់ស៊ីក្លូ ដើម្បីយកប្រាក់មកចិញ្ចឹមខ្លួន និងបង់ថ្លៃសាលា។ ហាក់ បានទៅរៀននៅសាលាវិទ្យាល័យស្រោចស្រង់ជាតិថ្នាក់ទី១ទំនើប។ ទៅរៀននៅភ្នំពេញបានរយៈពេល២ឆ្នាំជាង ក៏ចាប់ផ្តើមកើតមានសង្គ្រាមនៅទីក្រុងភ្នំពេញ រវាងខ្មែររំដោះ និងខាង លន់ នល់។ សង្គ្រាមលើកនេះបានធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងធំ ក្រោយខ្មែរក្រហមទទួលជ័យជម្នះ ពោលគឺបានធ្វើឲ្យកើតមាននូវព្រឹត្តិការណ៍មួយ គឺការជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញយ៉ាងឆាប់រហ័សក្នុងរយៈពេល៣ថ្ងៃ។ ហាក់ក៏ដូចជាប្រជាជនឯទៀតដែរ ខ្មែរក្រហមបានជម្លៀសគាត់ចេញពីទីក្រុងភ្នំពេញដែរ ដើម្បីវិលមកស្រុកកំណើតវិញ។ តាមផ្លូវត្រឡប់មកផ្ទះវិញ ហាក់ បានឃើញមនុស្សស្លាប់គរលើគ្នា និងបានឃើញទិដ្ឋភាពដែលទាហានខ្មែរក្រហមបានបរឡានកិនមនុស្សស្លាប់ជាច្រើននាក់ យ៉ាងអនោចអាណោចអាធ៌មជាទីបំផុតនៅលើស្ពាន (មិនចាំឈ្មោះស្ពាន)។ ហាក់ មកដល់ស្រុកកំណើតវិញដោយថ្មើរជើងក្នុងរយៈពេល២០ថ្ងៃ។ ដោយសារគាត់ជាប្រជាជនដែលត្រូវបានជម្លៀសពីទីក្រុងភ្នំពេញ ប្រធានភូមិជីពាយបានមកសួរនាំគាត់ដែរ ទាក់ទងទៅនឹងជីវប្រវត្តិរបស់គាត់ថាតើ ពីមុនមកគាត់ធ្លាប់ធ្វើការងារអ្វី? ធ្វើនៅកន្លែងណាខ្លះ? ហាក់ បញ្ជាក់ទៅវិញថា គាត់គ្រាន់តែជាសិស្សសាលា និងជាអ្នកធាក់ស៊ីក្លូតែប៉ុណ្ណោះមិនមានអ្វីលើសពីនេះទេ។ បន្ទាប់មកប្រធានភូមិឲ្យ ហាក់ ដឹកនាំក្មេងៗធ្វើបង្គន់អនាម័យ។ ក្រោយមក ហាក់ ក៏បានធ្វើជាកងចល័តដើរទៅធ្វើការនៅតាមតំបន់ផ្សេងៗ ដូចជាការធ្វើប្រព័ន្ធប្រឡាយនៅក្នុងភូមិព្រៃពោន តាមការបញ្ជារបស់ខ្មែរក្រហម។ នៅខែមករា ឆ្នាំ១៩៧៩ ហាក់ បានផ្លាស់ប្តូរពីកងចល័ត មកធ្វើជាអ្នកបញ្ជូនស្រូវ និងបុកស្រូវរហូតដល់ថ្ងៃដែលរបបខ្មែរក្រហមដួលរលំ។ ក្រោយឆ្នាំ១៩៧៩ គាត់ក៏បានធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សា នៅវត្តបេងបូរី។ នៅឆ្នាំ១៩៨២ ហាក់ បានឡើងជានាយករងសាលាវិទ្យាល័យព្រៃពោនរហូតដល់ថ្ងៃចូលនិវត្តន៍របស់គាត់នៅឆ្នាំ២០១៥។ សព្វថ្ងៃ ហាក់ រស់នៅដោយពឹងផ្អែកទៅលើប្រាក់ចំណូលចូលនិវត្តន៍របស់ខ្លួន។

## ៧. កែវ វន្ថា

កែវ វន្ថា ហៅ កែវ ឈន ភេទប្រុស កើតនៅឆ្នាំ១៩៤៥ នៅភូមិចាម ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ សព្វថ្ងៃ វន្ថា គឺជាមេឃុំព្រៃពោន និងរស់នៅភូមិតាប្រុញ ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ កាលពីអាយុ៧ឆ្នាំ វន្ថា បានមករស់នៅជាមួយឪពុកធំរបស់គាត់ក្នុងភូមិតាប្រុញ ឃុំព្រៃពោន ដើម្បីសិក្សារៀនសូត្រនៅក្នុងវត្តព្រៃពោន។ នៅឆ្នាំ១៩៦៧ វន្ថា បានមកបន្តការសិក្សានៅវិទ្យាល័យព្រះអង្គឌួង ទីរួមខេត្តព្រៃវែង។ បីឆ្នាំក្រោយមក វន្ថា បានត្រឡប់មកកាន់ស្រុកកំណើតវិញ បន្ទាប់ពីមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ គាត់បាន



កែវ វន្ថា ហៅ កែវ ឈន ភេទប្រុស កើតនៅឆ្នាំ១៩៤៥ នៅភូមិចាម ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ដេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

រៀបការជាមួយ ឡុង អ៊ឹម ដែលត្រូវជាកូនឪពុកធំរបស់គាត់។ នៅឆ្នាំ១៩៧២ វន្ធា ត្រូវកម្មាភិបាលសន្តិសុខស្រុកកំពង់ត្របែក ឈ្មោះ ទុំ ប៊ិច ចាប់យកទៅដាក់ឃុំឃាំងនៅព្រៃដេង និងបញ្ជូនបន្តទៅសួរចម្លើយនៅទួលម្រេញ។ ដំបូង ប៊ិច ចោទវន្ធា ថាជាប់សន្តិសម្ព័ន្ធ និងបានធ្វើទារុណកម្មទៅលើគាត់។ នៅថ្ងៃបន្ទាប់ វន្ធា ត្រូវបានបញ្ជូនបន្តទៅដាក់ឃុំឃាំងនៅក្នុងវត្តហប់ចំនួនមួយយប់ ដែលមាន គឹម ជាប្រធានសន្តិសុខ មុនពេលដែលគាត់ត្រូវបានបញ្ជូនបន្តទៅកាន់ទួលម្រេញ។ គាត់ជាប់ឃុំឃាំងនៅទួលម្រេញអស់រយៈពេលមួយឆ្នាំកន្លះ។ វន្ធា ត្រូវបានដោះលែងឲ្យមកផ្ទះវិញ បន្ទាប់ពីថ្ងៃរំដោះ ទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ស្ថិតក្នុងរបបខ្មែរក្រហម វន្ធា ត្រូវកម្មាភិបាលមូលដ្ឋានខ្មែរក្រហមប្រើឲ្យធ្វើការងារដូចអ្នកឯទៀតដែរ គឺការងាររកសិកម្ម។ គាត់ពុំសូវទទួលរងការលំបាកប៉ុន្មានទេ ព្រោះគាត់ជាមនុស្សឧស្សាហ៍ និងពូកែអែបអបកម្មាភិបាលខ្មែរក្រហម។ នៅឆ្នាំ២០០២ វន្ធា ធ្វើជាក្រុមប្រឹក្សាឃុំព្រៃពោន។ ពីឆ្នាំ២០០៧រហូតដល់សព្វថ្ងៃ គាត់បានទទួលតំណែងជាមេឃុំព្រៃពោន តាមរយៈការបោះឆ្នោត។



យ៉េ យ៉ន អាយុ៦៩ឆ្នាំ ជាប្រជាពលរដ្ឋរស់នៅភូមិចាម ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ៨. យ៉េ យ៉ន

យ៉េ យ៉ន អាយុ៦៩ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិចាម ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ យ៉េ យ៉ន កើតនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៥៣។ យ៉េ យ៉ន ចាប់ផ្តើមចូលរៀនដំបូង នៅអាយុ៧ ឆ្នាំ នៅវត្តសេរីឧត្តម ថ្នាក់ទី១២ និងក្រោយមក យ៉ន បានទៅរៀននៅផ្ទះពូរបស់គាត់ចំនួន ២ឆ្នាំទៀតនៅឆ្នាំង ឆ្នាំ១៩៧៣ ដល់ ១៩៧៤។ យ៉ន មានបងប្អូន ៧នាក់ ប្រុស៣ ស្រី ៤ ដែលបងប្រុសរបស់ យ៉ន ២នាក់ត្រូវបានខ្មែរក្រហមសម្លាប់ ដោយសារតែគាត់ជាអតីតទាហាន លន់ នល់។ យ៉ន បានរៀបរាប់ឲ្យដឹងថា មុននឹងខ្មែរក្រហមយកបងប្រុសរបស់គាត់២នាក់យកទៅសម្លាប់ ខ្មែរក្រហមបានប្រើបងប្រុសរបស់គាត់ឲ្យអូសរទេះដឹកឈើពីកំពង់ត្របែកទៅព្រៃពោន ព្រមទាំងបង្អត់អាហារទៀត។ យ៉ន បានស្រក់ទឹកភ្នែកដោយសារនឹកអាណិតដល់បងប្រុសជាពន់ពេក។ ក្រោយមកបងប្រុស ២នាក់របស់ យ៉ន ក៏បានបាត់ដំណឹង ហើយគាត់បានសន្និដ្ឋានថា បងប្រុសទាំងពីរនាក់របស់ខ្លួនត្រូវបានខ្មែរក្រហមយកទៅសម្លាប់ហើយ តាំងពីឆ្នាំ១៩៧៦។ យ៉ន បានរំឭកថា គាត់ក៏មានការលំបាកខ្លាំងណាស់ គាត់បានរត់គេចពីគ្រាប់ផ្លោង និងការទម្លាក់គ្រាប់បែកស្ទើរតែរាល់ថ្ងៃ ពេលខ្លះមិនបានដេកពួនទៀត។ យ៉ន បាននិយាយទៀតថា ការរស់នៅក្នុងភូមិជាប់ជាមួយនឹងព្រំដែនវៀតណាម គឺមានសង្គ្រាម និងគ្រាប់ផ្លោងកើតមានជាញឹកញាប់ ចាប់ តាំងពីឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៩ បើទោះជាខ្មែរក្រហមបានទទួល ជ័យជម្នះរួចទៅហើយក៏ដោយ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បន្លែហូបចុក ដែល យ៉ន ដាំក៏មិនអាចមានសិទ្ធិបេះយកមកហូបដែរ លុះត្រាតែបេះដាក់ចូល ទៅក្នុងសហករណ៍ពេងបាយរួម ប៉ុន្តែប្រសិនបើ យ៉ន ហ៊ានបេះយកមកហូបតែម្នាក់ឯងហើយមានអ្នកដឹងនោះ

ច្បាស់ណាស់ នឹងត្រូវប្រធានកងទិតៀន និងត្រូវយកទៅអប់រំជាពុំខានៗ សម្រាប់ការងាររបស់យ៉ន វិញ គឺ យ៉ន មិនដែល ហ៊ាននិយាយ ឬប្រកែកត្អូញត្អែរទេ។ គាត់គិតតែពីខំប្រឹងប្រែងធ្វើការជារៀងរាល់ថ្ងៃ ក៏ព្រោះតែខ្លាច មិនចង់ឲ្យនរណាមកទិតៀនខ្លួន និងខ្លាចខ្មែរក្រហមយកទៅកសាង ឬសម្លាប់។ ដូច្នេះ ហើយទើបបានជាគាត់សុខចិត្តធ្វើតាមការបញ្ជារបស់ខ្មែរក្រហមបែបនេះ។ ការធ្វើការក៏មានការប្រជុំដែរ គឺមួយខែត្រូវប្រជុំម្តង ដែលមានប្រធានបទនិយាយពីការធ្វើស្រែ ការទិតៀនគ្នាទៅវិញទៅមក និយាយពីការឲ្យប្រជាជនខំប្រឹងធ្វើការ និងណែនាំឲ្យប្រជាជនមិនឲ្យស្តាប់វិទ្យុនាំឲ្យបែកអារម្មណ៍ជាដើម។

ក្រោយថ្ងៃជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានរៀបចំបង្កើតរចនាសម្ព័ន្ធការងារដាក់ឲ្យប្រជាជនធ្វើជាបណ្តើរៗ។ រហូតដល់ឆ្នាំ១៩៧៦ ទើបមានការបង្កើតជាសហករណ៍ពេញលេញ គឺការធ្វើការរួម ការចាប់ផ្តើមហូបបាយរួម និងប្រមូលរបស់របរទាំងអស់ដាក់ជារបស់រួមដូចជាស្រូវអង្ករ ចានឆ្នាំងជាដើម រីឯគ្រឿងអលង្ការ មាស ប្រាក់ ពេជ្រ កែវកង ក៏ត្រូវបានប្រមូលយកទៅដែរ នៅក្នុងឆ្នាំ១៩៧៨។ យ៉ន មិនហ៊ានប្រកែកទៅនឹងអង្គការឡើយ គាត់ក៏បានប្រគល់មាសចំនួន៥ជីទៅឲ្យខ្មែរក្រហមដែរ។ បើនិយាយពីការងារប្រចាំថ្ងៃរបស់ យ៉ន កាលពីសម័យខ្មែរក្រហមជាទូទៅដោយសារតែគាត់ស្ថិតនៅក្នុងវ័យដែលមានកម្លាំងពេញ ខ្មែរក្រហមបានបញ្ចូលគាត់ចូលទៅក្នុងកងនារី ដែលក្រុមនេះ គឺជាអ្នកធ្វើប្រព័ន្ធភ្លឺស្រែ លើកដី និងដីប្រឡាយពីកំពង់ត្របែក ទៅឆ្កាង និង ពីបឹងក្រទឹប ទៅថ្កូវ។ សម្រាប់ការងារទាំងអស់នេះ យ៉ន ត្រូវចាប់ផ្តើមធ្វើការពីម៉ោង៧ ព្រឹក ដល់ម៉ោង១១ថ្ងៃត្រង់ទើបមកសម្រាកហូបបាយ។ ពេលរសៀលចូលធ្វើការវិញនៅម៉ោង ២ រហូតទាល់តែហើយតាមផែនការដែលបានកំណត់ក្នុងម្នាក់ជីកដីឲ្យបានប្រវែង ១៥ម៉ែត្រក្នុងមួយថ្ងៃ ទើបអាចមកសម្រាកបាន ប៉ុន្តែបើមិនហើយ ត្រូវបន្តធ្វើដល់ថ្ងៃស្អែកទៀត។ យ៉ន បានចងចាំច្បាស់ណាស់អំពីថ្ងៃខែដែលគាត់បានរៀបការជាមួយស្វាមី គឺថ្ងៃទី១៥ឧសភា ឆ្នាំ១៩៧៦។ ការរៀបការនៅពេលនោះ គឺមានសរុបទាំងអស់ចំនួន៦គូដែលរៀបការក្នុងពេលតែមួយជាមួយ យ៉ន ដែរ។ យ៉នបានរៀបរាប់ថា នៅក្នុងពិធីមង្គលការ គឺមានតែសាម៉ីខ្លួនដែលជាអ្នករៀបការតែប៉ុណ្ណោះដែលមានវត្តមាននៅក្នុងពិធីនោះ ចំណែកឯឪពុកម្តាយត្រូវរង់ចាំនៅខាងក្រៅក្នុងនាមជាភ្ញៀវ។ ពិធីរៀបការនេះបានប្រព្រឹត្តទៅក្នុងរយៈពេលតែមួយព្រឹកប៉ុណ្ណោះ ដោយឲ្យយុវជនយុវនារីអង្គុយទល់មុខរួចប្រកាសគូស្រករ និងទទួលស្គាល់គ្នាជាប្តីប្រពន្ធ ហើយប្តេជ្ញាថានឹងស្រឡាញ់គ្នាអស់មួយជីវិត។ ការរៀបការនេះ ក៏មានការថតរូបផងដែរ ពីសំណាក់កម្មាភិបាលខ្មែរក្រហម។ បន្ទាប់ពីពិធីរៀបការបានចប់សព្វគ្រប់ មុននឹងត្រឡប់ទៅផ្ទះវិញ ខាងអង្គការក៏មានជាការអញ្ជើញឲ្យហូបចុកអាហារតិចតួចដែរ គឺមានសម្លម្ជូរ និងសម្លការី សម្រាប់ជប់លៀងពិធីរៀបមង្គលការ។ នៅឆ្នាំ១៩៧៨ យ៉ន សម្រាលបានកូនម្នាក់នៅប្រប្រត់។ អង្គការបានឲ្យ យ៉ន សម្រាកនៅផ្ទះចំនួន ១០ថ្ងៃ។ យ៉ន ត្រូវមើលថែកូនខ្លួនឯងផង និងត្រូវមើលថែក្មេង ២នាក់ទៀត ដោយសារតែម្តាយរបស់ក្មេងទាំងពីរនាក់ត្រូវបានអង្គការប្រើឲ្យទៅធ្វើស្រែ។ ក្រៅពីនេះ យ៉ន នៅមានការងារផ្សេងទៀតគឺបុកស្រូវ និងលើកដី។ នៅថ្ងៃទី ៥ ខែមករា ឆ្នាំ១៩៧៩ ពេលវៀតណាម បររថក្រោះចូលដល់ស្រុកកំពង់ត្របែកធ្វើឲ្យប្រជាជនមានការជ្រួលច្របល់។ ប្រធានសហករណ៍ឈ្មោះ គុច បានកៀរប្រជាជនទាំងអស់ទៅស្រុកព្រះស្តេច ក្នុងគោលបំណងគេចពីវៀតណាម។ ទៅដល់ស្រុកព្រះស្តេច កម្មាភិបាល និងប្រធានសហករណ៍បង្ខំឲ្យប្រជាជនរត់ចូលទៅក្នុងព្រៃ។ ដោយមើលទៅដូចជាមិនស្រួល យ៉ន ក៏បានពិភាក្សាជាមួយនឹងស្វាមី ហើយប្រមូលគ្នីគ្នាមួយចំនួនដែលនៅជិតនោះដើរត្រឡប់ថយក្រោយវិញ។

មកដល់វត្តក្រចាប់ក៏បានជួបជាមួយ នឹងវៀតណាម ហើយវៀតណាមក៏បានស្រែកប្រាប់ឲ្យត្រឡប់ទៅផ្ទះវិញ។ ថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៩ ទើបយ៉ែនមកដល់ស្រុកកំណើតវិញ ហើយដើរប្រមូលស្រូវអង្ករបាន ឆ្នាំងមួយចំនួនយកទៅប្រើប្រាស់ផងដែរ។ ចាប់តាំងថ្ងៃដែលខ្មែរក្រហម ដួលរលំមក ស្រុកទេសក៏ចាប់ផ្តើមមានសុខសន្តិភាពឡើងវិញ ហើយ យ៉ែន ក៏អាចចាប់ផ្តើមប្រកបរបររកស៊ីដោយខ្លួនឯងបានដែរ ដោយទិញជ្រូកពីក្បាលយកទៅលក់ឲ្យជនជាតិវៀតណាម និងទិញអំបិលពីវៀតណាមយកមកដូរជាអង្ករ។ ក្រោយពីនេះ យ៉ែន បានយក បេក យកល្ហុង ទៅដូរជាអង្ករ។ ក្រោយពីការលក់ដូរ យ៉ែន នៅធ្វើស្រែដែលរដ្ឋាភិបាលបានចែកឲ្យដោយខ្លួនឯងដែរ ប៉ុន្តែសព្វថ្ងៃ យ៉ែន ធ្វើស្រែលែងរួចហើយដោយសារតែមានវ័យកាន់តែចាស់ និងពឹងផ្អែកទៅលើប្រាក់ចំណូលដែលកូនជូនតិចតួចប៉ុណ្ណោះ។



ប្រឡាយទឹកនៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវរបស់ប្រជាជនដែលឆ្លងកាត់របបខ្មែរក្រហម នៅភូមិថ្នល់កែង ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

*ស្លូត វិចិត្រ, មេក ទិន និង ហ៊ាន ពិសី*

## ១. ញាក់ ធឿង

ពាត់ ធឿង ភេទប្រុស អាយុ៧៧ឆ្នាំ មានស្រុកកំណើតនៅក្នុងភូមិជីមៀត ស្រុកកោះញែក ខេត្តមណ្ឌលគិរី។ ធឿង សព្វថ្ងៃរស់នៅក្នុងភូមិថ្នល់កែង (ឬភូមិ១០៥) ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ធឿង បាននិយាយរៀបរាប់អំពីបទពិសោធការតស៊ូរបស់ខ្លួននៅសម័យខ្មែរក្រហមដូចខាងក្រោម៖

កាលពីកុមារភាពខ្ញុំមិនបានរៀនសូត្រទេដោយសារតែជីវភាពគ្រួសាររបស់ខ្ញុំមានការខ្វះខាត។ នៅមុនឆ្នាំ១០៧០ គ្រួសាររបស់ខ្ញុំប្រកបមុខរបរធ្វើចម្ការដាំស្រូវ និងដាំដំណាំបន្តិចបន្តួចសម្រាប់ចិញ្ចឹមជីវិត។ ជំនាន់នោះប្រជាជនដែលរស់នៅក្នុងស្រុកកោះញែកភាគច្រើនធ្វើស្រែចម្ការ ដាំដំណាំ និងចិញ្ចឹមសត្វ។ ទោះបីជានៅក្នុងជំនាន់សម្តេចនរោត្តសីហនុមិនសូវមានរបស់របរប្រើប្រាស់ទំនើបៗក៏ដោយប៉ុន្តែប្រជាជនរស់នៅសុខសប្បាយជួបជុំគ្រួសារយ៉ាងសុខសាន្ត។ លុះចូលដល់ឆ្នាំ១៩៦៨ នៅក្នុងភូមិស្រុករបស់ខ្ញុំក៏ចាប់ផ្តើមមានភាពចលាចលដោយសារមានយន្តហោះមកទម្លាក់គ្រាប់បែកនៅក្នុងភូមិ។ នៅក្នុងឆ្នាំ១៩៦៨ ដដែល ខ្ញុំបានចូលបម្រើកងទ័ពរំដោះខ្មែរក្រហមដោយរស់នៅក្នុងព្រៃ។ ចាប់តាំងពីពេលដែលខ្ញុំចេញពីផ្ទះមកខ្ញុំមិនដែលមានទំនាក់ទំនងជាមួយគ្រួសារទេ។ កងកម្លាំងដែលខ្មែរក្រហមប្រមូលបានពីភូមិស្រុក ត្រូវបានបញ្ជូនឲ្យទៅហ្វឹកហាត់បណ្តើរ និងចាត់តាំងឲ្យទៅវាយនៅលើសមរភូមិបណ្តើរ។

ខ្ញុំត្រូវបានចាត់តាំងឲ្យនៅសមរភូមិក្នុងខេត្តមណ្ឌលគិរី ខេត្តក្រចេះ និងវាយចូលទីក្រុងភ្នំពេញ។ រហូតដល់ឆ្នាំ១៩៧៤ ខ្ញុំបានរៀបការ។ កាលនោះឪពុកម្តាយរបស់ខ្ញុំគឺជាអ្នករៀបចំការឲ្យខ្ញុំ និងមានការហូបអាហារ ការជួបជុំបងប្អូន ប៉ុន្តែមិនមានធ្វើពិធីធំដុំទេ។ នៅពេលដែលខ្ញុំចេញទៅវាយនៅតាមសមរភូមិម្តងៗ គឺមានរយៈពេលពី ១ខែ ទៅ ៨ខែទើបបានត្រឡប់មកជួបប្រពន្ធកូនម្តង។ ចំណែកឯស្បៀងអាហារដែលខ្ញុំដាក់តាមខ្លួនមានត្រីងៀត ត្រីខកំប៉ុង និងសាច់កំប៉ុងជាដើម ប៉ុន្តែអាហារទាំងអស់នេះមិនអាចទ្រទ្រង់ជីវភាពកងទ័ពឲ្យហូបគ្រប់គ្រាន់ទេ។



ញាក់ ធឿង ភេទប្រុស អាយុ៧៧ឆ្នាំ រស់នៅក្នុងភូមិថ្នល់កែង ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (ស្លូត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ថ្ងៃមួយកងកម្លាំងរបស់ខ្ញុំអស់ស្បៀង ដូច្នេះខ្ញុំក៏សម្រេចចិត្តធ្វើដំណើរមកភូមិដើម្បីសុំស្បៀងពីប្រជាជន។ បន្ទាប់ពីខ្ញុំធ្វើដំណើរបានពាក់កណ្តាលផ្លូវ ខ្ញុំបានជួបជាមួយមេដឹកនាំខ្មែរក្រហមឈ្មោះ នួន ជា ប៉ុន្តែកាលណោះខ្ញុំមិនបានស្គាល់គាត់ទេ។ ខ្ញុំបានសួរ

ទៅកាន់ នួន ជា ថាតើឯងមកពីណា? នួន ជា ឆ្លើយថា គាត់មកពីកោះញែកៗ ខ្ញុំក៏សួរបន្តថាតើឯងឈ្មោះអ្វី និងទៅណា? គាត់ឆ្លើយថាខ្ញុំឈ្មោះ នួន ជា ហើយខ្ញុំត្រូវទៅឯណោះ ដោយមិនបានប្រាប់ឈ្មោះតំបន់ដែលគាត់ត្រូវទៅទេ។ ខណៈពេលនោះ នួន ជា បានសួរបកមកខ្ញុំវិញថា តើឯងធ្វើដំណើរមកទីនេះមិនខ្លាចមនុស្សទេ? ខ្ញុំបានតបទៅវិញថា មនុស្សមិនចេះស៊ីមនុស្សទេតែបើមនុស្សកេះកៃកាំភ្លើងនោះទើបកាំភ្លើងចេះស៊ីមនុស្ស។ បន្ទាប់ពី ខ្ញុំ និង នួន ជា បាននិយាយសួរនាំគ្នារួចហើយ យើងក៏បែកផ្លូវគ្នាធ្វើដំណើរទៅមុខបន្តទៀត។ ដល់ឆ្នាំ១៩៧៩ វៀតណាមវាយចូលមកដល់ខ្ញុំក៏បានត្រឡប់មកស្រុកកំណើតរកប្រពន្ធកូនរបស់ខ្ញុំវិញ។

## ២. ថាំ សែម

ថាំ សែម ភេទប្រុស អាយុ៧២ឆ្នាំ មានស្រុកកំណើតនៅភូមិមួយ ឃុំញ៉ាង ស្រុកអណ្ដូងមាស ខេត្តរតនគិរី។ សព្វថ្ងៃ សែម រស់នៅក្នុងភូមិថ្នល់កែង (ឬភូមិ១០៥) ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ សែម បាននិយាយរៀបរាប់ពីជីវិតតស៊ូរបស់ខ្លួនដែលបានឆ្លងកាត់ពីរបបខ្មែរក្រហមដូចខាងក្រោម៖

ខ្ញុំរស់នៅក្នុងគ្រួសារមួយដែលមានឪពុកធ្វើការជំទប់ទី២ឃុំ និងម្ដាយគឺជាស្ត្រីមេផ្ទះ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៩នាក់ ហើយគ្រួសារខ្ញុំគឺជាជនជាតិចារាយ។ កាលពីខ្ញុំនៅក្មេងខ្ញុំមិនបានរៀនសូត្រទេដោយសារតែស្រុកទេសកើតមានសង្គ្រាម។ ជំនាន់មុនសង្គ្រាម ជនជាតិចារាយមានប្រពៃណីស្លៀកពាក់មិនដូចសព្វថ្ងៃនេះទេ។ ជនជាតិចារាយស្លៀកពាក់ជាពីងដូចនឹងការស្លៀកក្បិនរបស់ខ្មែរដែរ ចំណែកឯស្រីៗក្រមុំមានតែខោសំពតត្រឹមជង្គង់ស្លៀកតែប៉ុណ្ណោះដោយមិនមានអាវសម្រាប់គ្របដណ្ដប់ខ្លួនទេ។ ជនជាតិចារាយធ្វើចម្ការ ចំណែកការហូបចុកមិនមានការខ្វះខាតឡើយ ដូច្នេះប្រជាជនរស់នៅដោយរីករាយ



ថាំ សែម ភេទប្រុស អាយុ៧២ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិថ្នល់កែង ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

និងសប្បាយណាស់។ នៅក្នុងការហូបចុកប្រចាំថ្ងៃជនជាតិចារាយទិញតែអំបិលពីខាងក្រៅ។ នៅពេលចេញទៅទិញអំបិលម្ដងៗ ជនជាតិចារាយបានជិះដំរីទៅ ដោយក្នុងមួយគ្រួសារជិះដំរីមួយ គឺស្រុះស្រួលគ្នាខ្លាំងណាស់។ ពេលមានពិធីបុណ្យទានម្ដងៗ សម្ដេចព្រះ នរោត្តម សីហនុ តែងតែមកចែកក្រណាត់ឲ្យប្រជាជនទុកសម្រាប់កាត់សម្លៀកបំពាក់។

នៅឆ្នាំ១៩៦៨ ខ្ញុំបានចូលបម្រើចលនាតស៊ូក្នុងព្រៃជាមួយខ្មែរក្រហម។ រហូតដល់មានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅឆ្នាំ១៩៧០ ទើបសម្ដេចព្រះ នរោត្តម សីហនុ អំពាវនាវឲ្យប្រជាជនចូលព្រៃម៉ាគីតស៊ូ ដូច្នេះខ្មែរក្រហមក៏ឆ្លៀតឱកាសប្រមូលកម្លាំងបានច្រើនទៅវាយជាមួយលន់ នល់។ កងកម្លាំងខ្មែរក្រហមទាំងអស់ត្រូវរៀនបណ្ដើរ និងឡើងទៅវាយនៅសមរភូមិបណ្ដើរដោយមិនមានពេលឈប់សម្រាកឡើយ។ ខ្ញុំរួមជាមួយអង្គភាពទ័ពទាំងអស់បានវាយដណ្ដើមយកខេត្តមណ្ឌលគិរី, រតនគិរី, ក្រចេះ ស្ទឹងត្រែង និងព្រះវិហារ និងបន្តវាយយកខេត្តកំពង់ចាម និងកំពង់ធំ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពរបស់ខ្ញុំបានទទួលជ័យជម្នះ។ បន្ទាប់មក ខ្ញុំនៅធ្វើជានីរសារឲ្យយ៉ា គឺជាលេខាភូមិភាគឦសាន។ យ៉ា អាច

និយាយភាសា ចិន, អង់គ្លេស, បារាំង, ថៃ និង ឡាវ ព្រោះ គាត់ធ្លាប់ធ្វើជាគ្រូនៅសម័យសង្គមរាស្ត្រនិយម។ នៅពេលយ៉ា ទៅជួបជាមួយមេដឹកនាំខ្មែរក្រហមធំៗ ដូចជា ប៉ុល ពត, អៀង សារី, នួន ជា និង សុន សេន គាត់តែងតែយកខ្ញុំទៅជាមួយ។ រហូតដល់ឆ្នាំ១៩៧៦ យ៉ា បានរៀបចំឲ្យខ្ញុំមានគ្រួសារ។ នៅចុងឆ្នាំ១៩៧៦ យ៉ា ត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់ចោល ដោយចោទថា គឺជាជនក្បត់ ហើយបញ្ជូនកម្មាភិបាល និងកងទ័ពមកពីភូមិភាគនិរតីមកគ្រប់គ្រងជំនួសវិញ។ កាលនោះ តា០៥ គឺជាអ្នកគ្រប់គ្រងជំនួស យ៉ា។ ចំណែកខ្ញុំរួមទាំងកងទ័ពជាច្រើននាក់ទៀតដែលបានជាប់និន្នាការក្បត់ ស្ថិតនៅក្រោមការឃ្លាំមើលរបស់កងឈ្លប។

នៅដើមឆ្នាំ១៩៧៩ កងទ័ពស្ម័គ្រចិត្តវៀតណាមបានវាយចូលមកដល់ ហើយខ្ញុំក៏រត់មករកកូននិងប្រពន្ធដើម្បីភៀសខ្លួនទៅច្រក១០០១។ នៅទីនោះ ខ្មែរក្រហមចាត់ឲ្យខ្ញុំនៅខាងសេដ្ឋកិច្ចបើកស្បៀងអាហារឲ្យប្រជាជន។ ខ្ញុំរួមទាំងគ្រួសារបានរស់នៅទីនោះរហូតដល់ឆ្នាំ១៩៨៥ ក៏ធ្វើដំណើរមកកាន់ច្រក១០០៣វិញ។ ការហូបចុកនៅទីនោះមិនមានការខ្វះខាតទេ។ ខ្ញុំរស់នៅលើភ្នំដងរែករហូតដល់ធ្វើសមាហរណកម្មនៅក្នុងស្រុកអន្លង់វែងទើបខ្ញុំចុះមករស់នៅក្នុងភូមិថ្នល់កែង (ឬហៅភូមិ១០៥) រហូតមកដល់សព្វថ្ងៃ។

## ៣. គត់ ផាន់

គត់ ផាន់ ភេទប្រុស អាយុ៥៦ឆ្នាំ មានស្រុកកំណើតនៅភូមិអរបួន ឃុំអរបួនលើ ស្រុកកោះញែក ខេត្តមណ្ឌលគិរី។ ផាន់ សព្វថ្ងៃរស់នៅក្នុងភូមិថ្នល់កែង (ឬហៅថា១០៥) ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ផាន់ បាននិយាយរៀបរាប់ពីដំណើរតស៊ូរបស់ខ្លួនក្នុងរបបខ្មែរក្រហមដូចខាងក្រោម៖

ខ្ញុំគឺជាកូនកាត់ជនជាតិ ឡាវ និងព្នង។ ឪពុករបស់ខ្ញុំគឺជាជនជាតិ ឡាវ ចំណែកម្ដាយរបស់ខ្ញុំគឺជាជនជាតិ



គត់ ផាន់ ភេទប្រុស អាយុ៥៦ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិថ្នល់កែងហៅ១០៥, ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្នង។ គ្រួសាររបស់ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ ខ្ញុំមានបងប្អូនបង្កើតចំនួន ៤នាក់។ កាលពីកុមារភាពខ្ញុំមិនបានរៀនសូត្រទេ ព្រោះប្រទេសជាតិកើតមានសង្គ្រាម។ នៅក្នុងឆ្នាំ ១៩៧៧ ខ្ញុំត្រូវបានខ្មែរក្រហមជ្រើសរើសឲ្យចូលធ្វើជាទាហាន ប៉ុន្តែកាលនោះដោយសារខ្ញុំនៅតូចពេកម្ដាយរបស់ខ្ញុំបានឲ្យខ្ញុំធ្វើពុតជាឈឺទើបរួចខ្លួន។ ខ្ញុំរស់នៅជាមួយម្ដាយខ្ញុំបានមួយឆ្នាំ គឺឆ្នាំ១៩៧៨ ខ្មែរក្រហមបញ្ជូនខ្ញុំឲ្យទៅធ្វើជាកងទ័ព ដោយកាលនោះមេរបស់ខ្ញុំឈ្មោះ តាដោម។ ខ្ញុំធ្វើជានីរសាររបស់ តាដោម ដូច្នេះខ្ញុំមិនបានចេញទៅវាយនៅសមរភូមិទេ។

នៅក្នុងឆ្នាំ១៩៧៩ យោធាខ្មែរក្រហមបានបំផុសបំផុលថា កងទ័ពវៀតណាមចាប់ប្រជាជនដែលរត់ត្រឡប់ទៅស្រុកកំណើតវិញវះពោះច្រកស្មៅ និងវាយធ្វើបាប។ បន្ទាប់ពីបានឮការឃោសនាទាំងនេះ ខ្ញុំរួមទាំងប្រជាជនជាច្រើននាក់ទៀតមិនហ៊ានត្រឡប់ចូលភូមិវិញទេ។ យើងសម្រេចចិត្តនាំគ្នារត់ចូលព្រៃក្នុងស្រុកកែវសីមា ខេត្តមណ្ឌលគិរី។ ខ្ញុំរស់នៅក្នុងព្រៃមួយរយៈ ទើបខ្ញុំរួមទាំងប្រជាជនជា និងយោធាខ្មែរក្រហមជាច្រើននាក់ទៀតបន្តដំណើរទៅមុខដោយមិនមានគោលដៅច្បាស់លាស់។ រហូតដល់ឆ្នាំ១៩៩០ ទើបខ្ញុំរួមទាំងប្រជាជន និងយោធាខ្មែរក្រហមធ្វើដំណើរមកដល់ភ្នំដងរែក។

## ៤. ស្រ៊ីវ បូណា

ឈ្មោះ ស្រ៊ីវ បូណា ភេទស្រី អាយុ៦៧ឆ្នាំ គឺជនជាតិព្នង មានទីកន្លែងកំណើតនៅភូមិរយ៉ៃ ឃុំរយ៉ៃ ស្រុកកោះញែក ខេត្តមណ្ឌលគិរី។ បច្ចុប្បន្ន បូណា រស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ បានចែករំលែករឿងរ៉ាវរបស់គាត់ដូចខាងក្រោម៖

ខ្ញុំគឺជាកូនស្រីនៃគ្រួសារកសិករនៅក្នុងភូមិរយ៉ៃ។ ខ្ញុំមានបងប្អូន១៣នាក់ ប៉ុន្តែស្លាប់បាត់បង់ជីវិតអស់១០នាក់ ដោយសារតែជំងឺអុចក្តាម។ អុតក្តាម គឺជាជំងឺឆ្លងមួយប្រភេទតាមរយៈការប៉ះពាល់គ្នា ឬការរស់នៅក្បែរគ្នា។ នៅជំនាន់នោះ ប្រសិនបើនរណាម្នាក់ឆ្លងជំងឺនេះហើយ កម្រនឹងមានជីវិតរស់ណាស់។ ដូច្នេះប្រសិនបើនរណាម្នាក់ដែលស្លាប់ដោយសារជំងឺនេះ គឺត្រូវដុតចោលតែម្តង។ នៅឆ្នាំ១៩៧០ ខ្ញុំបានរៀនត្រឹមថ្នាក់ទី១០ពីសង្គម ក្រោយមកក៏មានរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ។ បន្ទាប់មកខ្មែរក្រហមក៏ចាប់ផ្តើមកេណ្ឌប្រមូលក្មេងៗនៅតាមភូមិឲ្យចូលធ្វើការនៅកងកុមារ នៅក្នុងមន្ទីរមួយដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីភូមិ។ ខ្ញុំត្រូវបានដាក់ឲ្យរស់នៅរួមនិងហូបចុករួម ជាមួយក្រុមកុមារផ្សេងទៀតនៅក្នុងភូមិ។ ការហូបចុកជំនាន់នោះពិតជាពិបាកណាស់សម្រាប់ខ្ញុំ ដោយសារម្ហូប និងបាយត្រូវបានច្របល់ចូល។ ដូច្នេះដល់ពេលម៉ោងហូបបាយម្តងៗខ្ញុំតែងតែយំ រួចហើយលួចរត់ទៅផ្ទះរកម្តាយ។ ខ្ញុំហូបបាយជាមួយម្តាយរួចហើយ ទើបខ្ញុំត្រឡប់មកកងវិញ។ បន្ទាប់មកទៀត ខ្ញុំត្រូវបានប្រធានកងកុមារចាត់តាំងឲ្យដឹកនាំកុមារដើរដកមើមក្តួច។ ខ្ញុំអត់ស្គាល់មើមក្តួចរូបរាងយ៉ាងណាទេ ប៉ុន្តែខ្ញុំធ្វើទៅតាមមេកងគឺចូលព្រៃដើម្បីដកមើមក្តួច។ នៅពេលនោះខ្ញុំគិតថាខ្ញុំស្លាប់ក្នុងព្រៃហើយ ព្រោះខ្ញុំវង្វេងផ្លូវត្រឡប់មកផ្ទះវិញ។ ក្រោយមក ខ្ញុំក៏អាចរកផ្លូវត្រឡប់មកផ្ទះវិញ ប៉ុន្តែខ្ញុំមិនអាចរកមើមក្តួចបានទេ។ នៅពេលយប់ ប្រធានសហករណ៍បានប្រជុំទិតៀនខ្ញុំ។



ស្រ៊ីវ បូណា ភេទស្រី អាយុ៦៧ឆ្នាំ ជនជាតិព្នង រស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (ស្ងួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំ១៩៧៣ឪពុកម្តាយរបស់ខ្ញុំបានលើកខ្ញុំអោយទៅបុរសម្នាក់។ ខ្ញុំនិងគ្រួសារក៏យល់ព្រមចាំដល់គូរដណ្តឹងរបស់ខ្ញុំប្រឡងជាប់ធ្វើជាគ្រូទើបរៀបការ។ ក្នុងអំឡុងពេលខ្ញុំរង់ចាំគឺយូរណាស់ រហូតដល់អ្នកជិតខាងនិយាយថាសូមឲ្យខ្ញុំឈប់ចាំទៅ ហើយរៀបការជាមួយបុរសនៅជិតៗផ្ទះទើបល្អ។ ប៉ុន្តែខ្ញុំបានបដិសេធ ហើយពឹងពាក់អ្នកដែលស្គាល់ខ្ញុំជិតស្និទ្ធជួយសរសេរសំបុត្រផ្ញើរទៅគូដណ្តឹងខ្ញុំជារឿយៗ។ លុះខ្ញុំមានអាយុ២០ឆ្នាំ ទើបខ្ញុំទាំងពីរនាក់បានរៀបការជាមួយនឹងគ្នា។ ពិធីរៀបការរបស់ខ្ញុំនៅសម័យនោះ មិនមានរៀបចំអ្វីច្រើនទេ គឺកូនក្រមុំនិងកូនកំលោះមានតែខោអាវម្នាក់មួយសម្រាប់ និងមានធូប ទៀន ព្រមទាំងគ្រឿងសម្រាប់សែនដូនតាប៉ុណ្ណោះ។

នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបញ្ជូនខ្ញុំឲ្យទៅរៀនពេទ្យនៅមន្ទីរ ៣-៧ ចំនួនបីខែ។ លុះដល់ឆ្នាំ១៩៧៩ ពេលដែលកងទ័ពស្ម័គ្រចិត្តវៀតណាមចូលដល់ទីក្រុងភ្នំពេញ ខ្ញុំភៀសខ្លួនចេញពីភ្នំពេញជាមួយនិងក្រុមគ្រូពេទ្យ៦០នាក់ទៀត។ អំឡុងពេលនោះ ខ្ញុំកំពុងមានផ្ទៃពោះជិតគ្រប់ខែហើយ។ ខ្ញុំសម្រាលកូនតែម្នាក់ឯងនៅតាមផ្លូវ ព្រោះប្តីរបស់ខ្ញុំមិនបានមកជាមួយនៅពេលនោះ។ បន្ទាប់ពីខ្ញុំសម្រាលកូនបានបីថ្ងៃ ខ្ញុំបន្តដំណើរទៅខេត្តបាត់ដំបង។ ខ្ញុំទៅរស់នៅស្រុកគាស់ក្រឡរយៈពេលពីរឆ្នាំ ទើបខ្ញុំបានជួបប្តីរបស់ខ្ញុំវិញ។ បន្ទាប់មកខ្ញុំនិងគ្រួសារក៏បានភៀសខ្លួនទៅនៅស្ទឹងចន្ទក្នុងទឹកដីថៃអស់រយៈពេល២ឆ្នាំទៀត។ រហូតដល់ឆ្នាំ១៩៩០ ទើបខ្ញុំមករស់នៅភូមិថ្មល់កែង ឬភូមិ១០៥ រហូតមកដល់បច្ចុប្បន្ននេះ។



ដាំង ស ភេទ ស្រី អាយុ៦២ឆ្នាំ ជនជាតិព្នង បច្ចុប្បន្នរស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តមានជ័យ។ (ស្ទូត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ៥. ដាំង ស

ដាំង ស ភេទស្រី អាយុ៦២ឆ្នាំ គឺជាជនជាតិព្នង មានទីកន្លែងកំណើតនៅភូមិកោះម៉ាយើល ឃុំពាមជីមៀត ស្រុកកោះញែក ខេត្តមណ្ឌលគិរី។ បច្ចុប្បន្ន ស រស់នៅស្រុកត្រពាំងប្រាសាទបាននិយាយរៀបរាប់ថា ខ្ញុំមានបងប្អូនពីរនាក់។ ឪពុករបស់ខ្ញុំគឺជាជនជាតិលាវ រីឯម្ដាយខ្ញុំគឺជាជនជាតិព្នងនៅក្នុងខេត្តមណ្ឌលគិរី។ ជំនាន់នោះ ទោះបីយើងជាជនជាតិភាគតិចក៏ពិតមែន ប៉ុន្តែការរស់នៅក៏មិនខុសពីប្រជាជនខ្មែរប៉ុន្មានដែរ។ យើងរស់នៅដោយគោរពប្រណិប័តតាមព្រះពុទ្ធសាសនា ប្រពៃណីទំនៀមទម្លាប់ផ្សេងៗដូចប្រជាជនខ្មែរដែរ។ ខ្ញុំពុំសូវចងចាំរឿងរ៉ាវប៉ុន្មានទេដោយសារខ្ញុំនៅក្មេង។ ខ្ញុំគ្រាន់តែដឹងថាភូមិរបស់ខ្ញុំមានការទម្លាក់គ្រាប់បែក បណ្ដាលឲ្យខ្ញុំនិងគ្រួសាររួមជាមួយអ្នកភូមិជាច្រើនគ្រួសារទៀត ភៀសខ្លួនទៅរស់នៅក្នុងព្រៃ។ យើងនាំគ្នាធ្វើខ្ទមរស់នៅជាបណ្ដោះអាសន្ន។ បន្ទាប់ពីស្ងប់ស្ងាត់សង្គ្រាមហើយ ទើបយើងនាំគ្នាវិលត្រឡប់មកភូមិវិញ។ ប៉ុន្តែមិនប៉ុន្មានយើងក៏ត្រូវភៀសខ្លួនទៅក្នុងព្រៃម្ដងទៀត ដោយសារសង្គ្រាមរវាងខ្មែរ និងវៀតណាម។ យើងបានចិញ្ចឹមជីវិតនៅក្នុងព្រៃដោយការជីកក្ដួច ហូបនិងបរបាញ់សត្វអស់រយៈពេលបីឆ្នាំ។ កាលនោះខ្មែរក្រហមបែកស្រ្តីឲ្យរស់នៅមួយឡែក ចំណែកបុរសៗធ្វើជាកងទ័ពប្រយុទ្ធនៅលើសមរភូមិមុខ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមទទួលបានជ័យជម្នះនៅទីក្រុងភ្នំពេញ។ ចាប់តាំងពីពេលនោះមកប្រជាជនទាំងអស់ត្រូវបានជម្លៀសឲ្យរស់នៅក្នុងសហករណ៍ដែលស្ថិតនៅឆ្ងាយពីភូមិកោះម៉ាយើល។ យើងត្រូវធ្វើដំណើររយៈពេលមួយថ្ងៃទើបទៅដល់សហករណ៍នោះ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំបានប្ដូរឈ្មោះ ស មកឈ្មោះ រ៉ែត វិញ។ បន្ទាប់មក ខ្មែរក្រហមបានជ្រើសរើសខ្ញុំឲ្យទៅធ្វើជាអ្នកស្ងោរថ្នាំបុរាណ។ ថ្នាំបុរាណទាំងនោះមានធាតុផ្សំច្រើនមុខពីឫសឈើ ដែលចាស់ៗច្រើនហៅថ្នាំនោះថា ថ្នាំអាចម៍ទន្សាយ។ យើងចាប់ផ្ដើមធ្វើការស្ងោរថ្នាំចាប់ពីម៉ោង៧ព្រឹកដល់ម៉ោង១១ថ្ងៃត្រង់ និងពេលថ្ងៃពីម៉ោង១ ដល់ម៉ោង៥ល្ងាច។ ចំណែកការហូបចុកគឺពេលខ្លះខ្វះខាត និងពេលខ្លះទៀតបានហូបគ្រប់គ្រាន់។ នៅក្នុងមន្ទីរស្ងោរថ្នាំមានសមាជិក៦នាក់និងមានគ្រូបង្រៀនស្ងោរថ្នាំម្នាក់ឈ្មោះ ដាក់ គឺជនជាតិព្នង។ ប្រធានកងស្ងោរថ្នាំ បានចាត់ឲ្យសមាជិកពីរនាក់ ទៅរកធាតុផ្សំ ចំណែកនៅសល់គឺស្ងោរថ្នាំនៅមន្ទីរ។ ក្រោយមកអង្គការរៀបចំឲ្យខ្ញុំមានគ្រួសារ ដោយការចាប់គូ។ ពិធីរៀបការនោះមិនមានអ្វីច្រើនទេ គឺគ្រាន់តែឲ្យយើងឈរទល់មុខគ្នារួចប្ដេជ្ញាថាស្រឡាញ់គ្នាចំពោះមុខអង្គការ។

នៅឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមចូលមក ខ្ញុំភៀសខ្លួនទៅនៅច្រក១០០១។ នៅឆ្នាំ១៩៨១ ខ្ញុំបានទៅរស់នៅទឹកដីឡាវ។ ក្រោយមកនៅឆ្នាំ១៩៩៨ ទើបខ្ញុំមករស់ក្នុងភូមិថ្នល់កែងបុ១០៥។

## ៦. សុន សុខា

ឈ្មោះ សុន សុខា ភេទស្រី អាយុ៦០ឆ្នាំ មានទីកន្លែងនៅភូមិទួលតាហោ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ បច្ចុប្បន្នសុខារស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ បានរៀបរាប់ថា ខ្ញុំរស់នៅជាមួយឪពុក ចំណែកម្ដាយខ្ញុំមិនដែលបានជួបមុខទេ។ បន្ទាប់មក ឪពុករបស់ខ្ញុំមានប្រពន្ធថ្មី និងមានកូន

ទៀត។ នៅឆ្នាំ ១៩៧០ ក៏មានការទម្លាក់គ្រាប់បែក នៅក្នុងភូមិ។ ពេលនោះ ខ្ញុំនិងប្រជាជននាំគ្នាលាក់ខ្លួន នៅក្នុងលេណដ្ឋាន។ នៅឆ្នាំ១៩៧៥ ខ្ញុំនិងគ្រួសារ បានមករស់នៅស្រុកកោះញែក ខេត្តមណ្ឌលគិរីវិញ។ នៅពេលដែលទៅដល់ស្រុកកោះញែកដំបូង គឺយើងធ្វើការនៅសហករណ៍ ប៉ុន្តែយើងស្នាក់នៅផ្ទះរៀងៗខ្លួន។ ឪពុកម្តាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមឲ្យទៅធ្វើស្រែចម្ការ។ ចំណែកខ្ញុំ ខ្មែរក្រហមឲ្យធ្វើការនៅរោងបាយ គឺជួយចិតបន្លែ និងដាំបាយ។ ក្រោយទើបខ្មែរក្រហមប្តូរខ្ញុំឲ្យមកជួយមើលថែក្មេងៗវិញ។ កុមារទាំងនោះសុទ្ធតែជាកូនរបស់ប្រជាជនដែលរស់នៅក្នុងសហករណ៍។ កងមីងៗតែងតែយកកូនតូចៗមកផ្ញើរនឹងខ្ញុំមុនពេលចេញទៅធ្វើការជារៀងរាល់ព្រឹក។ ចំពោះការហូបចុករបស់ខ្ញុំ គឺមិនសូវខ្វះខាតប៉ុន្មានទេ ហើយយូរៗម្តងទើបមានបន្ថែមហូប។ នៅអំឡុងឆ្នាំ១៩៧៥ ខ្ញុំបានរៀបការ ដោយនៅពេលនោះមានចំនួន៦គូ និងមិនកម្មពិធីធំដុំឡើយ។



សុន សុខា ភេទស្រី អាយុ៦០ឆ្នាំ រស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (ស្គូត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំ១៩៧៩ ពេលកងទ័ពស្ម័គ្រវៀតណាមបានវាយចូលប្រទេសកម្ពុជា ខ្ញុំបានភៀសខ្លួនទៅតាមគ្រួសាររបស់ខ្ញុំទៅរស់នៅក្នុងព្រៃ ហើយបានបែកពីឪពុកម្តាយចាប់តាំងពីពេលនោះមក។ នៅកំឡុងពេលនោះ ខ្ញុំទើបសម្រាលបានកូនស្រីម្នាក់ ប៉ុន្តែបីថ្ងៃក្រោយមកកូនស្រីរបស់ខ្ញុំក៏ស្លាប់នៅក្នុងព្រៃ។ បន្ទាប់មក ខ្ញុំបានទៅរស់នៅស្ទឹងចន្ទ ក្នុងទឹកដីថៃ។ រយៈពេលពីរឆ្នាំក្រោយមក ខ្ញុំភៀសផ្លាស់ទៅរស់នៅជំរំភូណយ។ ការរស់នៅទីនោះមិនសូវជួបការលំបាកទេ ព្រោះខ្ញុំទទួលបានស្បៀងអាហារពីកាកបាទក្រហមអន្តរជាតិ។

រូបខាងស្តាំ៖ សុន សុខា អាយុ៦០ឆ្នាំ រស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម ដល់ ហ៊ាន ពិសី អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (ស្គូត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



# វេទិកាប្រវត្តិសាស្ត្រគ្រួសារនៅភូមិមង់ ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ

ឡុង ដានី, គាត ស្រីឡែន និង ឈុំ រ៉ា

ចន្លោះពីថ្ងៃទី២៣ ដល់ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២២ ក្រុមការងារមជ្ឈមណ្ឌលឯកកោះថ្ម រួមមាន៖ ឡុង ដានី, គាត ស្រីឡែន និង ឈុំ រ៉ា បានចុះជួប និងសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតនៅក្នុងភូមិមង់, ឃុំជាំ, ស្រុកមេមត់, ខេត្តត្បូងឃ្មុំ ចំនួន ៦គ្រួសារអំពីបទពិសោធន៍របស់គាត់នៅក្នុងសម័យសង្គ្រាម និងសម័យខ្មែរក្រហម (១៩៧៥-១៩៧៩)។ ភូមិមង់ស្ថិតនៅជាប់ព្រំដែនកម្ពុជា-វៀតណាម និងមានចម្ងាយប្រហែល៣៥គីឡូម៉ែត្រពីផ្លូវជាតិលេខ៧ ប៉ែកខាងកើត។ ភូមិមង់ជាភូមិដំបូងគេដែលបានធ្លាក់ចូលក្នុងសង្គ្រាមវៀតណាម ដោយសារមានកងទ័ពវៀតកុងបានឆ្លងចូលមកក្នុងទឹកដីកម្ពុជាជាហេតុនាំឲ្យទាហានអាមេរិកបានទម្លាក់គ្រាប់បែកមកលើភូមិមង់តាំងពីឆ្នាំ១៩៦៣។ ការទម្លាក់គ្រាប់បែកនេះបានបណ្ដាលឲ្យអ្នកភូមិមង់ចំនួន៥នាក់បានស្លាប់បាត់បង់ជីវិត (ស្រី៣នាក់ និងក្មេង២នាក់) និងមានផ្ទះសម្បែង គោក្របីមួយចំនួនទៀតបានឆេះខូចខាត។ បន្ទាប់ពីមានការទម្លាក់គ្រាប់បែក លោកឧត្តមសេនីយ៍ លន់ នល់ បានដឹកនាំគណៈប្រតិភូរដ្ឋាភិបាលសង្គមរាស្ត្រនិយម និងមន្ត្រីស្ថានទូតសហរដ្ឋអាមេរិក ចុះមកទស្សនកិច្ចសួរសុខទុក្ខប្រជាពលរដ្ឋនៅក្នុងភូមិមង់។ គណៈប្រតិភូបានសាងសង់ផ្ទះថ្មីចំនួន១៥ខ្នង ជូនដល់ប្រជាពលរដ្ឋ និងផ្ដល់សំណងជាលុយដល់ក្រុមគ្រួសាររងគ្រោះរួមទាំង ក្រណាត់ ខោ អាវ និងស្បៀងអាហារដល់ប្រជាពលរដ្ឋរងគ្រោះ ទាំងនោះរយៈពេលមួយឆ្នាំ។ រាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមក៏បានសាងសង់ស្តូបនៃការចងចាំចំពោះការទម្លាក់គ្រាប់បែកនៅភូមិមង់នៅក្នុងឆ្នាំ១៩៦៤ហើយស្តូបនៃការចងចាំនេះនៅសេសសល់រហូតមកដល់សព្វថ្ងៃ។ នៅក្នុងរបបខ្មែរក្រហម (១៩៧៥ដល់១៩៧៩) ប្រជាជននៅភូមិមង់ត្រូវបានខ្មែរក្រហមបង្ខំឲ្យរស់នៅក្នុងសហករណ៍ធ្វើការរួម និងហូបរួមដូចប្រជាជនរស់នៅតាមភូមិឃុំផ្សេងៗទៀតនៅទូទាំងប្រទេសកម្ពុជាដែរ។ អ្នកភូមិមង់ត្រូវបានបង្ខំឲ្យធ្វើការងារធ្ងន់ធ្ងរ ប៉ុន្តែឲ្យហូបបបរតែពីរពេលក្នុងមួយថ្ងៃគឺពេលថ្ងៃត្រង់ និងពេលល្ងាចៗ នៅពេលខ្មែរក្រហមធ្វើសង្គ្រាមនៅតាមព្រំដែនជាមួយប្រទេសវៀតណាម អ្នកភូមិមង់ទាំងអស់ត្រូវបានជម្លៀសដោយបង្ខំឲ្យទៅរស់នៅឃុំជាំតាម៉ៅ និងបន្តជម្លៀសទៅកាន់ស្រុកស្នួលខេត្តក្រចេះ។ នៅចុងក្រោយ អ្នកភូមិមង់ត្រូវបានខ្មែរក្រហមដឹកតាមកាណូតពីខេត្តក្រចេះទៅភូមិកណ្ដាល, ស្រុកស្ទឹងត្រង់ និងបន្តឲ្យទៅរស់នៅក្នុងស្រុកចំការលើ និងស្រុកបារាយណ៍រហូតដល់កងទ័ពវៀតណាមចូលដល់ប្រទេសកម្ពុជានៅថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩។ នៅអំឡុងពេលជម្លៀសដោយបង្ខំនេះ អ្នកភូមិមង់ដែលមានវ័យចំណាស់ជាច្រើននាក់បានស្លាប់ដោយសារអត់អាហារ។ ខាងក្រោមនេះគឺជាសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានផ្ដល់បទសម្ភាសន៍មកកាន់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម៖

## ១. ហ៊ាន ជន

ហ៊ាន ជន ភេទប្រុស អាយុ ៦២ឆ្នាំ ស្រុកកំណើតនៅភូមិតាម៉ៅ, ឃុំជាំតាម៉ៅ, ស្រុកមេមត់, ខេត្តកំពង់ចាម បានរៀបរាប់ថា ខ្ញុំមានឪពុកឈ្មោះ ញ៉ឹង ហ៊ាន ស្លាប់ឆ្នាំ២០០៨។ ចំណែកម្ដាយរបស់ខ្ញុំឈ្មោះ

ហ៊ុន សុភី ស្លាប់តាំងពីប្អូនខ្ញុំអាយុបានបីខែ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៤នាក់ក្នុងនោះស្រី២នាក់ និងប្រុស២នាក់។ ខ្ញុំមានប្រពន្ធឈ្មោះ យិត សារឿន អាយុ៦៨ឆ្នាំ និងមានកូនចំនួន៥នាក់ក្នុងនោះស្រី១នាក់ និងប្រុស៤នាក់។ ខ្ញុំធ្វើជាប្រធានភូមិមង់តាំងពីឆ្នាំ១៩៩២ រហូតដល់បច្ចុប្បន្ន។ កាលពីកុមារភាព ខ្ញុំមិនបានរៀនសូត្រច្រើនទេ ពីព្រោះមិនមានសាលារៀន។ ភាគច្រើនក្មេងប្រុសៗត្រូវទៅរៀននៅតាមវត្តអារាម។ នៅក្នុងឆ្នាំ១៩៦៤ ពេលប្អូនខ្ញុំកើតបានរយៈពេល៣ខែ ម្តាយខ្ញុំក៏បានស្លាប់ ហើយឪពុកខ្ញុំបាននាំខ្ញុំមករស់នៅភូមិមង់តែម្តង។ កាលពីដើមនៅក្នុងភូមិមង់មិនសូវមានប្រជាជនរស់នៅច្រើននោះទេ គឺមានផ្ទះតែ ១៥ខ្នងប៉ុណ្ណោះ។ កាលពីមុននៅក្នុងផ្ទះមួយខ្នងមានតែសមាជិក៥នាក់ទៅ៦នាក់តែប៉ុណ្ណោះ។ ចំណែកគ្រួសារខ្ញុំ និងអ្នកភូមិដទៃទៀតភាគច្រើនធ្វើស្រែចម្ការ និងដាំស្រូវ ដោយកាប់ឆ្ការព្រៃ។ ពេលណាដីត្រង់កន្លែងយើងដាំស្រូវអស់ជីវជាតិ យើងត្រូវទៅកាប់ឆ្ការដីនៅកន្លែងផ្សេងទៀត ព្រោះកាលនោះការដាំដុះស្រូវត្រូវផ្លាស់ប្តូរទីកន្លែងរហូត។ ម្តាយរបស់ខ្ញុំមិនមែនជាជនជាតិស្មៀងទេ គឺគាត់ជាមួយជនជាតិខ្មែរ។ ចំណែកឪពុករបស់ខ្ញុំគឺជាជនជាតិខ្មែររស់នៅវៀតណាម។ ខ្ញុំធ្លាប់ឮឪពុករបស់ខ្ញុំនិយាយថា កាលពីសង្គមចាស់គាត់មានជីវភាពធូរធារ ហើយគាត់បានប្រគេនផ្ទះ ៣ខ្នងដល់វត្តកន្ទួត ដើម្បីរុះយកឈើធ្វើសាលារៀន។ ក្រោយពេលដែលម្តាយរបស់ខ្ញុំស្លាប់ ឪពុករបស់ខ្ញុំបាននាំខ្ញុំមករស់នៅភូមិមង់ជាមួយបងប្អូនវិញ។ ខ្ញុំរស់នៅភូមិមង់បានជិតមួយឆ្នាំ ក៏រត់ចេញពីភូមិម្តងទៀតដោយសារតែមានការទម្លាក់គ្រាប់បែក។ បងជីដូនមួយរបស់ខ្ញុំបានរងរបួសដោយសារអំបែងគ្រាប់។ ក្រៅពីភូមិមង់ក៏មានការទម្លាក់គ្រាប់បែកនៅភូមិចន្ទ្រា និងត្រឡោកបែកជាដើម។ អំឡុងពេលនោះសង្គ្រាមក៏កើតមាននៅវៀតណាម ហើយវៀតកុងបានចូលមកក្នុងទឹកដីខ្មែរ។ នៅឆ្នាំ១៩៧៤ ខ្ញុំបានត្រឡប់មករស់នៅក្នុងភូមិមង់វិញ។ នៅពេលនោះខ្មែរក្រហមចាប់ផ្តើមឲ្យប្រជាជនធ្វើការប្រវាស់ដៃ។



ហ៊ិន ដន ភេទប្រុស អាយុ៦២ឆ្នាំ រស់នៅភូមិមង់ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ ខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំចេញពីភូមិមង់មុនគេបង្អស់។ ដំបូងខ្មែរក្រហមជម្លៀសខ្ញុំនិងក្រុមគ្រួសារឲ្យទៅនៅភូមិជ័យសម្បត្តិ, ឃុំតំបែរ, ស្រុកតំបែរ។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើការងារនៅកងចល័តដោយត្រូវបានបង្ខំឲ្យកាប់ដីនិងជីកប្រឡាយ។ បន្ទាប់ពីធ្វើការងារនៅទីនោះបានជិតមួយឆ្នាំ ខ្មែរក្រហមជម្លៀសខ្ញុំចេញពីស្រុកតំបែរឲ្យមករស់នៅភូមិទឹកជ្រៅ ស្រុកទឹកជ្រៅ ដោយធ្វើការងារជីកប្រឡាយ ទឹកដដែល។ ចំពោះការហូបចុកនៅក្នុងភូមិទឹកជ្រៅ ឃុំទឹកជ្រៅ ស្រុកទឹកជ្រៅ (បច្ចុប្បន្ន ក្នុងស្រុកតំបែរ ខេត្តត្បូងឃ្មុំ) គឺមិនបានគ្រប់គ្រាន់នោះទេ។ មួយថ្ងៃ យើងហូបតែពីរពេល គឺពេលព្រឹក និងពេលល្ងាច ហើយភាគច្រើនគឺបបររាវ ហើយក្នុងមួយនាក់ទទួលបានបន្តិចបន្តួចប៉ុណ្ណោះ។ នៅស្រុកទឹកជ្រៅ ខ្មែរក្រហមចាត់តាំងឲ្យខ្ញុំធ្វើការជាមួយគណៈស្រុក។ ខ្ញុំមិនបានធ្វើការងារអ្វីធំដុំនោះទេ គ្រាន់តែដើរតាមគណៈស្រុកតែប៉ុណ្ណោះ។ កាលនោះក្រុមរបស់ខ្ញុំមានសមាជិក៤នាក់ដើរតាមគណៈស្រុករយៈពេល១ខែ គឺមានខ្ញុំ, តាំង, ខេន និង ប៊ូ ប៉ុន្តែយើង



ប៉ុន ចាន់ថុល ភេទស្រី អាយុ៦២ឆ្នាំ រស់នៅភូមិចម្ការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

គ្មានកាំភ្លើងទេ។ ថ្ងៃមួយ តាំង និង ប៉ូ ត្រូវបានយោធាខ្មែរក្រហមហៅទៅកសាង។ ក្រោយពេល យោធាខ្មែរក្រហមយកតាំង និង ប៉ូ ទៅកសាងរួច ក្រុម០៩ (កងទ័ពវៀតណាម) និងយោធាខ្មែរក្រហមមកពីមជ្ឈិមបានវាយប្រយុទ្ធគ្នា។ ពេលនោះ ខ្ញុំបានរត់ទៅនៅភូមិប្រវាក់ដែក, ឃុំឈូក, ស្រុកក្រូចឆ្មារ។ ក្រោយមក ខ្ញុំទៅដល់ស្ទឹងសែន ខេត្តកំពង់ធំ។ ខ្ញុំធ្វើការងារស្រែចម្ការនៅទីនោះ។

នៅដើមឆ្នាំ១៩៧៩ ខ្ញុំបានត្រឡប់មកខេត្តកំពង់ចាមដោយថ្មើរជើង។ ខ្ញុំដេកនៅតាម ចំណែកម្ហូបអាហារ ខ្ញុំដាក់មកតាមខ្លួន។ ខ្ញុំដើររយៈពេល៥ទៅ៦ថ្ងៃទើបដល់ខេត្តកំពង់ចាម។ ពេលដល់ខេត្តកំពង់ចាម ខ្ញុំបានជួបបងប្អូនដែលបែកគ្នាតាំងពេលជម្លៀសចេញពីភូមិមង់។ បន្ទាប់មក ខ្ញុំជិះទូកឆ្លងមកទន្លេបិទបន្តទៀត។ ពេលចេញពីមេមត់មកភូមិមង់វិញ គឺយើងមិនបានមកទាំងអស់គ្នាទេ។ យើងចូលមកភូមិមង់ម្តង៥គ្រួសារ ដើម្បីស៊ើបការណ៍នៅក្នុងភូមិថាតើមានខ្មែរក្រហមនៅឬទេ។ ខ្ញុំដើរដល់ភូមិភ្លាមឃើញមានសុទ្ធតែព្រៃឈើ និងព្រៃចេក។ ខ្ញុំកាប់ឈើសង់ផ្ទះ ព្រោះផ្ទះរបស់ខ្ញុំបែកបាក់និងខូចខាតអស់ហើយ។ មកដល់ភូមិដំបូងខ្ញុំគ្មានស្រូវអង្ករទេ ដូច្នេះត្រូវដើរជីកដំឡូង ក្តួច មកហូបជំនួស។ ក្រោយមកទៀត យើងទៅស៊ីឈ្នួលឲ្យវៀតណាមដើម្បីយកលុយទិញពូជស្រូវពីវៀតណាម និងធ្វើការងារដូរយកពូជស្រូវ។ ខ្ញុំបានរៀបការជាមួយប្រពន្ធខ្ញុំនៅឆ្នាំ១៩៨១។ ពេលនោះដោយសារតែខ្ញុំចេះអក្សរបន្តិចបន្តួច ទើបខាងអាជ្ញាធរឲ្យខ្ញុំសរសេរអក្សរជំនួសមេភូមិ។ កាលពីឆ្នាំ១៩៧៩ មេភូមិមានឈ្មោះ ព្រឹក ឈាង បន្ទាប់មកឈ្មោះ ម៉ុក។ តមកទៀតមានឈ្មោះ អ៊ួច ទើបមកដល់ខ្ញុំ។ អំឡុងពេលនោះនៅក្នុងភូមិមង់មានប្រជាជនរស់នៅត្រឹមតែ៣០គ្រួសារប៉ុណ្ណោះ។ បច្ចុប្បន្នភូមិមង់, ឃុំជាំ, ស្រុកមេមត់, ខេត្តត្បូងឃ្មុំ ដែលខ្ញុំរស់នៅ មាន៦៦គ្រួសារ និងមានប្រជាជនសរុបចំនួន២២៩ នាក់។

## ២. អំ មេក

អំ មេក ភេទស្រី អាយុ៦៣ឆ្នាំ មានស្រុកកំណើតនៅភូមិមង់ ឃុំជាំ ស្រុកមេមត់ ខេត្តកំពង់ចាម (បច្ចុប្បន្ន ខេត្តត្បូងឃ្មុំ) បានរៀបរាប់អំពីបទពិសោធន៍ជីវិតរបស់ខ្លួនថា សព្វថ្ងៃខ្ញុំរស់ភូមិមង់ ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឪពុករបស់ខ្ញុំឈ្មោះ អំ និងម្តាយឈ្មោះ នោរ។ ខ្ញុំមានបងប្អូន ៥នាក់ គឺស្រី២នាក់ និងប្រុស៣នាក់។ ប្តីរបស់ខ្ញុំឈ្មោះ ឯម សឿន ហើយយើងខ្ញុំមានកូនចំនួន៤នាក់ គឺស្រី២នាក់ ប្រុស២នាក់។ កាលពីកុមារភាព ខ្ញុំមិនបានរៀនសូត្រទេ ព្រោះគ្មានសាលារៀន និងមានសង្គ្រាម។ ខ្ញុំនៅជួយការងារឪពុកម្តាយ និងធ្វើស្រែ។ នៅពេលខ្ញុំមានអាយុ៥ឆ្នាំ នៅក្នុងភូមិរបស់ខ្ញុំក៏កើតមានសង្គ្រាម។ យន្តហោះបានទម្លាក់គ្រាប់បែកនៅក្នុងភូមិរបស់ខ្ញុំ ហើយអ្នកភូមិនាំគ្នារត់ចូលពួននៅក្នុងរណ្តៅដែលបានជីកទុកព្រោះខ្លាចត្រូវគ្រាប់ផ្លោង។ ពេលនោះ ម្តាយរបស់ខ្ញុំឱបប្អូនរបស់ខ្ញុំដែលទើបតែមានអាយុ១ខែ បានត្រូវគ្រាប់ផ្លោងបណ្តាលឲ្យស្លាប់ ចំណែកប្អូនរបស់ខ្ញុំបានរងរបួស។ នៅក្នុងហេតុការណ៍ទម្លាក់គ្រាប់នោះ អ្នកភូមិ៥នាក់ទៀតក៏បានស្លាប់ដែរ។ កាលពីសម័យនោះ នៅក្នុងភូមិរបស់ខ្ញុំមិនសូវមានប្រជាជនរស់នៅច្រើនប៉ុន្មានទេ គឺមានប្រហែលជា១៥ទៅ១៧គ្រួសារតែប៉ុណ្ណោះ។ បន្ទាប់ពីមានទម្លាក់គ្រាប់បែករួច ភូមិរបស់ខ្ញុំទទួលរងនូវការខូចខាតបាត់បង់ផ្ទះសំបែង

អស់គ្មានសល់។ រដ្ឋាភិបាលសង្គមរាស្ត្រនិយម និងស្ថានទូតអាមេរិកបានផ្តល់សំណាងដោយសាងសង់ផ្ទះជូនប្រជាជន, សាងសង់ស្តូបគោរពវិញ្ញាណក្ខន្ធ, ផ្តល់សំណាងជាក្រណាត់ និងលុយ ចំនួន១៥រៀលដល់គ្រួសារដែលបានបង់បង់ជីវិត។

នៅឆ្នាំ១៩៧០ ខ្ញុំបានទៅស៊ីឈ្នួលនៅជាំទ្រៀក។ មួយរយៈក្រោយមក ក៏មានសង្គ្រាមនៅក្នុងភូមិ ទើបខ្ញុំត្រឡប់ទៅមេមត់វិញ។ ក្រោយមក ខ្ញុំផ្លាស់ទៅដល់ភូមិព្រៃដោយយកក្របីទៅដូរយកអង្ករហូប។ ខ្ញុំត្រឡប់មកភូមិមេមង់វិញនៅឆ្នាំ១៩៧៥។ ខ្មែរក្រហមបានឲ្យប្រជាជនធ្វើស្រែប្រវាស់ដៃគ្នា ហើយបន្ទាប់មកទៀតទើបចាប់ផ្តើមហូបរួម។ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើការនៅកងកងចល័ត ដូចជា ស្ទូងស្រូវ និងដកសំណាប។ ចាប់ពីឆ្នាំ១៩៧៥មក ប្រជាជនក្នុងភូមិពុំមានរបបអាហារហូបចុកគ្រាប់គ្រាន់ទេ។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសខ្ញុំទៅបឹងអាត ដោយនៅទីនោះខ្ញុំធ្វើការងារនៅកងចល័តដដែល។ បន្ទាប់មកទៀត ខ្មែរក្រហមបានចាត់ឲ្យខ្ញុំទៅធ្វើការងារ នៅក្រចាប។ នៅទីនោះខ្ញុំហូបមិនគ្រប់គ្រាន់ និងគ្មានកម្លាំងធ្វើការទេ។ ខ្មែរក្រហមតម្រូវឲ្យខ្ញុំធ្វើការរួចរាល់តាមផែនការទើបអាចសម្រាកបាន។ នៅឆ្នាំ១៩៧៨ ខ្មែរក្រហមជម្លៀសខ្ញុំឲ្យទៅបឹងប្រៃ នៅស្រុកទឹកជ្រៅ (បច្ចុប្បន្នស្រុកតំបែរ)។ បន្ទាប់មកទៀត ខ្មែរក្រហមជម្លៀសខ្ញុំទៅដល់ស្រុកសំបូរ ខេត្តក្រចេះ។ បងជីដូនមួយខ្ញុំម្នាក់បានស្លាប់នៅស្រុកសំបូរដោយសារទាស់សសៃខ្ទី ចំណែកបងប្រុសរបស់ខ្ញុំបានស្លាប់ដោយសារអត់អាហារ។ មួយរយៈក្រោយមកខ្មែរក្រហមជម្លៀសខ្ញុំបន្តតាមកាណូតពីឃុំថ្មក្រែឆ្ពោះទៅស្រុកស្ទឹងត្រង់ និងចំការលើ។ វេលាម៉ោង៤ល្ងាចទើបខ្ញុំទៅដល់ស្ទឹងត្រង់ និងបន្តទៅស្រុកចំការលើ។ ខ្ញុំចុះពីកាណូត ហើយបានឡើងឡានជាមួយវៀតណាម បន្ទាប់ពីទទួលបានសេចក្តីប្រកាសថាអ្នកណានៅស្រុកណាឲ្យត្រឡប់ទៅស្រុកនោះវិញ។ ក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩ ខ្ញុំបានជិះឡានជាមួយវៀតណាមមកដល់មេមត់ ហើយក៏ចុះដើរមកកាន់



អំ មេក ភេទស្រី អាយុ៦៣ឆ្នាំ រស់ភូមិមេមង់ ឃុំជាំ ស្រុកមេមត់ ខេត្តកត្បូងឃ្មុំ។ (ថត ស្រីឡែ ឡូន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ភូមិកំណើតវិញ។ ខ្ញុំកាប់ឆ្ការព្រៃសង់ផ្ទះថ្មីរួចហើយទៅស៊ីឈ្នួលនៅប្រទេសវៀតណាមដើម្បីដូរយកពូជស្រូវមកដាំ។ នៅឆ្នាំ១៩៨៣ ខ្ញុំបានរៀបការជាមួយប្តីខ្ញុំ។ សព្វថ្ងៃនេះប្តីរបស់ខ្ញុំបានស្លាប់ដោយសារជំងឺ។ ខ្ញុំរស់នៅជាមួយកូនដោយប្រកបមុខរបរធ្វើស្រែ, ដាំស្វាយ និងកៅស៊ូរហូតមកដល់សព្វថ្ងៃ។

## ៣. ញ៉ែម អេង

ញ៉ែម អេង ភេទស្រី អាយុ៨០ឆ្នាំ មានស្រុកកំណើតនៅភូមិមង់ ឃុំជាំ ស្រុកមេមត់ ខេត្តកំពង់ចាម បានរៀបរាប់បទពិសោធន៍ជីវិតដែលគាត់ធ្លាប់ឆ្លងកាត់ថា សព្វថ្ងៃខ្ញុំរស់នៅភូមិមង់ ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ញ៉ែម និងម្តាយឈ្មោះ ជូក។ ខ្ញុំមានបងប្អូន២នាក់ គឺស្រីទាំង២នាក់។ ខ្ញុំមានប្តីឈ្មោះ ឆ្នោ និងមានកូន៥នាក់ គឺស្រី៣នាក់ និងប្រុស២នាក់។ កាលពីខ្ញុំនៅក្មេង ខ្ញុំមិនបានរៀនសូត្រទេ ព្រោះគ្មានសាលារៀន និងរវល់ជួយម្តាយធ្វើចម្ការ។ ក្រោយមក ខ្ញុំនិងគ្រួសារបានផ្លាស់ប្តូរទៅរស់នៅភូមិទួលគ្រួស ស្ថិតនៅជាំតាម៉ៅវិញ ព្រោះមានសង្គ្រាមនៅភូមិមង់ ប៉ុន្តែនៅពេលដែលខ្ញុំទៅរស់នៅក្នុងភូមិទួលគ្រួសស្រាប់តែមានការទម្លាក់គ្រាប់បែកដែរ។ ឪពុករបស់ខ្ញុំបានស្លាប់




ញ៉ែម ហេង ភេទស្រី អាយុ ៨៥ឆ្នាំ រស់នៅភូមិមង់ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅភូមិទួលគ្រួស ដោយសារតែត្រូវគ្រាប់បែក។ ឪពុកខ្ញុំស្លាប់មិនទាន់បានប៉ុន្មានផង ម្ដាយរបស់ខ្ញុំបានស្លាប់ដោយសារជំងឺនៅដាំអំពិល ស្ថិតនៅឃុំដាំ។

ក្រោយឪពុកម្ដាយខ្ញុំស្លាប់អស់ ខ្ញុំក៏បានរៀបការ។ នៅឆ្នាំ១៩៧០ មានយន្តហោះចូលមកទម្លាក់គ្រាប់បែកនៅក្នុងភូមិរបស់ខ្ញុំ ដែលអំឡុងពេលនោះខ្ញុំមានកូនម្នាក់។ ដោយសារខ្លាចត្រូវគ្រាប់ផ្លោង ខ្ញុំបាននាំកូនរបស់ខ្ញុំរត់ចូលត្រង់សេដែលជីកទុក ហើយខ្ញុំបានផ្លាស់ប្ដូរទៅរស់នៅភូមិទួលគ្រួស។ សង្គ្រាមធ្វើឲ្យប្រជាជនក្នុងភូមិបាត់បង់ផ្ទះសម្បែងអស់គ្មានសល់។ រដ្ឋាភិបាលសង្គមរាស្ត្រនិយមបានសង់ផ្ទះថ្មីឲ្យប្រជាជន និងសងប្រាក់ដល់ប្រជាជននៅក្នុងភូមិក្នុងមួយគ្រួសារ១៥រៀល។ ក្រោយពីខ្ញុំរស់នៅភូមិទួលគ្រួសអស់រយៈពេល៣ឆ្នាំ ខ្ញុំក៏ត្រឡប់មកភូមិមង់វិញ ដោយពេលនោះខ្មែរក្រហមប្រមូលប្រជាជន និងរៀបចំឲ្យប្រជាជនធ្វើស្រែប្រវាស់ដៃ និងហូបបាយរួមគ្នាមួយថ្ងៃ២ពេល គឺពេលថ្ងៃត្រង់ និងល្ងាច។ ខ្ញុំត្រូវខ្មែរក្រហមឲ្យធ្វើស្រែនិងចម្ការ។ ក្រោយមកទើប ខ្មែរក្រហមជម្លៀសខ្ញុំនិងប្រជាជនក្នុងភូមិទៅកាន់ស្រុកផ្សេងៗ។ អំឡុងពេលដែលខ្មែរក្រហមជម្លៀសប្រជាជនមានមនុស្សស្លាប់ច្រើនណាស់ ព្រោះអត់អាហារហូបចុក គឺប្រជាជនហូបតែបបរមួយថ្ងៃ២ពេល។ ខ្មែរក្រហមជម្លៀសខ្ញុំដល់ខេត្តក្រចេះ។ កាលនោះខ្ញុំមានកូន២នាក់ ប៉ុន្តែមិនបានរស់នៅជុំគ្នាទេ។ ប្ដីរបស់ខ្ញុំត្រូវបានខ្មែរក្រហមឲ្យទៅធ្វើការកន្លែងផ្សេងៗ។ ចំណែកកូនខ្ញុំត្រូវទៅរស់នៅកងចល័តកុមារ។ បន្ទាប់ទៀត ខ្មែរក្រហមបន្តជម្លៀសខ្ញុំទៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ក្រោយមកពេលកងទ័ពស្ម័គ្រចិត្តវៀតណាមបានចូលមកដល់ប្រទេសកម្ពុជា នៅដើមឆ្នាំ១៩៧៩ វៀតណាមបានប្រកាសឲ្យប្រជាជនត្រឡប់ទៅស្រុកកំណើតវិញ។ ខ្ញុំនិងគ្រួសារបានជួបគ្នា និងបានធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ។ នៅពេលមកដល់ភូមិមង់វិញ ខ្ញុំនិងគ្រួសារនាំគ្នាទៅវៀតណាមដើម្បីរកពូជស្រូវយកមកដាំ។ ខ្ញុំបានសង់ផ្ទះ និងធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។

## ៤. ញ៉ែម ហេង

ញ៉ែម ហេង ភេទស្រី អាយុ៨៥ឆ្នាំ មានស្រុកកំណើតនៅភូមិមង់ ឃុំដាំ ស្រុកមេមត់ ខេត្តកំពង់ចាម បានចែករំលែកបទពិសោធន៍ជីវិតរបស់គាត់មកកាន់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាថា បច្ចុប្បន្នខ្ញុំរស់នៅភូមិមង់ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានម្ដាយឈ្មោះ ធក់ ស្លាប់នៅភូមិដាំអំពិល ក្នុងឃុំដាំ ក្នុងអំឡុងសម័យសង្គ្រាមវៀតណាម។ ចំណែកឪពុករបស់ខ្ញុំបានស្លាប់នៅក្នុងភូមិកន្ទួត នៅសម័យសង្គ្រាមវៀតណាមដែរ។ ប្ដីរបស់ខ្ញុំឈ្មោះ អំ ញ៉ែម ស្លាប់ប្រហែល៩ឆ្នាំហើយ ដោយសារមានជំងឺ។ ខ្ញុំមានកូនចំនួន៨នាក់គឺស្រីទាំងអស់។ សព្វថ្ងៃកូនរបស់ខ្ញុំនៅរស់តែពីរនាក់ប៉ុណ្ណោះ ក្រៅពីនោះបានស្លាប់

នៅក្នុងសម័យសង្គ្រាមអស់ហើយ។

កាលពីកុមារ ខ្ញុំមិនបានសិក្សារៀនសូត្រ ហើយក៏មិនចេះអក្សរដែរ។ ខ្ញុំរៀបការមុនសម័យសង្គ្រាមវៀតណាម។ សព្វថ្ងៃ ខ្ញុំរស់នៅជាមួយកូនស្រីម្នាក់ ចំណែកកូនស្រីម្នាក់ទៀតរស់នៅភូមិដង្កិត ស្ថិតនៅក្នុងឃុំក្រវៀន។ នៅចន្លោះឆ្នាំ១៩៦៣ ដល់១៩៦៤ មានការទម្លាក់គ្រាប់បែកយ៉ាងច្រើននៅក្នុងភូមិមង់។ ខ្ញុំមិនបានដឹងពីមូលហេតុនៃការទម្លាក់គ្រាប់បែកនោះទេ ប៉ុន្តែប្រជាជននិយាយកងទ័ពអាមេរិកទម្លាក់គ្រាប់លើកងទ័ពវៀតកុង។ ក្រោយពេល ទម្លាក់គ្រាប់បែករួច មានទាហានលន់ នល់ ជាច្រើនមកពីស្រុកមេមត់ចុះមកមើល និងសាងសង់ផ្ទះដែលខូចខាតជូនប្រជាជនវិញ។ នៅឆ្នាំ១៩៧០ ខ្ញុំនិងគ្រួសារបានទៅរស់នៅភូមិដូង និងទៅនៅប៉ុស្តិ៍មេមត់។ ខ្ញុំរស់នៅប៉ុស្តិ៍មេមត់មិនបានប៉ុន្មានក៏នាំគ្នាទៅនៅឃុំទ្រៀករយៈពេល៣ឆ្នាំទៀត។ ដោយសារតែនៅឃុំទ្រៀកមានការទម្លាក់គ្រាប់បែកខ្លាំងពេកបណ្ដាលឲ្យមនុស្សស្លាប់ ទើបខ្ញុំផ្លាស់ទៅរស់នៅភូមិបុស្សខ្នុររយៈពេលកន្លះខែ ទើបមកនៅឃុំទ្រៀក។ ក្រោយមកខ្ញុំត្រឡប់មករស់នៅភូមិមង់ ឃុំជាំវិញ។ ខ្មែរក្រហមបានចាប់ផ្ដើមប្រមូលប្រជាជនឲ្យធ្វើស្រែប្រវាស់ដៃ ហូបរួមគ្នា និងធ្វើការងាររួមគ្នា។ ក្រោយមកទៀត គ្រួសារខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើការនៅតាមកងចល័ត។ កូនស្រីរបស់ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យកាប់ដី និងរែកដី។ ដំបូងខ្មែរក្រហមឲ្យនារីធ្វើការងារនៅតាមកងចល័ត ចំណែកប្រុសៗចាត់ឲ្យធ្វើជាទាហាន។ ខ្ញុំរស់នៅក្នុងភូមិម៉ង់បានរយៈពេល២ឆ្នាំ ក្រោយមកទើបអង្គការជម្លៀសខ្ញុំចេញទៅនៅអាលូច ក្នុងស្រុកស្នួល ខេត្តក្រចេះវិញ។ ពេលទៅដល់អាលូច ខ្ញុំបានកាប់ឆ្ការព្រៃដើម្បីយកដីដាំដំណាំ។ ពេលនោះខ្មែរក្រហមបានជម្លៀសប្រជាជនជាច្រើនមកពីឃុំជាំ ឃុំជាំក្រវៀន ក្នុងមេមត់ទៅកាន់ស្រុកស្នួល ខេត្តក្រចេះដែរ។ ខ្មែរក្រហមបានបែងចែកការងារដល់ប្រជាជនដែលទើបជម្លៀសមកដល់ថ្មី។ ចំពោះរបបអាហារហូបចុកគឺមិនគ្រប់គ្រាន់នោះទេ។ ប្រសិនបើយើងហូបចុកលួចលាក់ ហើយ



ញ៉ែម ហេង ភេទស្រី អាយុ ៨៥ឆ្នាំ រស់នៅភូមិមង់ ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(គាត ស្រីឡែ ឡូន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

អង្គការដឹង នឹងយកទៅកសាង ឬសម្លាប់ចោល។ កាលនោះខ្ញុំឃើញមានមនុស្សចំនួន៣នាក់ត្រូវបានទាហានខ្មែរក្រហមចាប់យកទៅសម្លាប់ចោលមានឈ្មោះ ខាត់ ឈាម និង២នាក់ទៀតមកពីភូមិផៀវ ក្នុងឃុំជាំ ដែលខ្ញុំមិនចាំ។ ខ្ញុំរស់នៅទីនោះបាន២ខែ ទើបអង្គការជម្លៀសខ្ញុំចេញទៅដកស្ទូងនៅអូលីវ ក្នុងខេត្តក្រចេះដដែល។ ចំពោះរឿងស្នេហាអង្គការមិនអនុញ្ញាតមនុស្សប្រុសស្រីទាក់ទងគ្នាឡើយ។ ពេលនោះឈ្មោះ ញ៉ាញ់ មានប្រពន្ធឈ្មោះ សេង ត្រូវបានអង្គការវាយសម្លាប់ដោយសារលួចមានស្រីញី។ ក្រោយមកខ្មែរក្រហមជម្លៀសខ្ញុំទៅរស់នៅកំពង់ចាមបានរយៈពេល៣ថ្ងៃ កងទ័ពស្ម័គ្រចិត្តវៀតណាមបានចូលមក។ ខ្ញុំជិះទូកឆ្លងទន្លេបិទរួចធ្វើដំណើរមកដល់ឃុំក្រែក ស្រុកពញាក្រែក។ នៅទីនោះ កូនខ្ញុំ

ម្នាក់បានកើតជំងឺគ្រុនចាញ់ ក្រោយមកបានស្លាប់ដោយសារគ្មានថ្នាំសង្កូវព្យាបាល។ ពេលខ្ញុំរៀបចំបុណ្យសពកូនរួចហើយ ខ្ញុំធ្វើដំណើរត្រឡប់មកស្រុកវិញ។ ពេលមកដល់ដំបូង ផ្ទះរបស់ខ្ញុំគ្មានសល់អ្វីទេ គឺបាក់បែកអស់ហើយ។ យើងបាននាំគ្នាកាប់ឆ្ការព្រៃរៀបចំសង់ផ្ទះ ដោយប្រក់ស្បូវដើម្បីធ្វើជាជម្រក។ ក្រោយមកយើងបានធ្វើការដោះដូរយកពូជស្រូវពីវៀតណាមយកមកដាំ។

---

## ៥. ចូង សឿន

ចូង សឿន ភេទប្រុស អាយុ៧០ឆ្នាំ មានស្រុកកំណើតនៅភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិមង់ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ចូង និងមានម្ដាយឈ្មោះ ថូ។ ខ្ញុំមានបងប្អូន ៨នាក់ គឺប្រុស៣នាក់ និងស្រី១នាក់។ បងប្រុសរបស់ខ្ញុំម្នាក់បានស្លាប់នៅប្រទេសវៀតណាម។ ខ្ញុំមានប្រពន្ធឈ្មោះ វ៉ែន ផុន និងមានកូនចំនួន១០នាក់ គឺប្រុស៥នាក់ និងស្រី៥នាក់។

កាលពីក្មេង ខ្ញុំមិនបានរៀនសូត្រទេ ព្រោះគ្មានសាលារៀន ហើយប្រសិនបើខ្ញុំចង់រៀនគឺត្រូវទៅរៀននៅវត្ត។ នៅពេលខ្ញុំមានអាយុ១២ឆ្នាំ ឪពុកម្ដាយខ្ញុំបានផ្លាស់មករស់នៅភូមិមង់ ឃុំដាំក្រវៀន ស្រុកមេមត់ ព្រោះឪពុករបស់ខ្ញុំបានទិញដីនៅភូមិមង់។ ពេលនោះក្នុងភូមិមង់មាន១៦គ្រួសារ និងមានប្រជាជនប្រហែល១០០នាក់ប៉ុណ្ណោះ។ នៅក្នុងភូមិមានផ្លូវតូចៗ និងមិនមានមនុស្សដើរទេ ព្រោះខ្លាចសត្វខ្លា។ ខ្ញុំបានជួយឪពុកម្ដាយធ្វើស្រែ និងចម្ការ។ កាលពីមុនខ្ញុំឮឪពុកខ្ញុំប្រាប់ខ្ញុំថា ប្រជាជនបាននាំគ្នាហៅភូមិនេះថា «អូរមង់» ព្រោះមានអូរ។ ខ្ញុំរស់ភូមិមង់បានរយៈពេល៣ឆ្នាំ ស្រាប់តែយន្តហោះមកទម្លាក់គ្រាប់បែក។ ជារឿយៗនៅវេលាម៉ោង៥ល្ងាច គឺមានយន្តហោះ ហោះមកទម្លាក់គ្រាប់បែក។ ឪពុកខ្ញុំតែងតែស្រែកប្រាប់ថា "កូនរត់! គ្រាប់បែកមកហើយ» ហើយខ្ញុំនិងឪពុករបស់ខ្ញុំបានរត់ចូលពួនក្នុងព្រៃ។ ប្រធានភូមិឈ្មោះ តា ប៉ែន បានប្រាប់ឪពុកខ្ញុំថា កុំរត់បោលស្រុក ព្រោះនៅពេលទម្លាក់គ្រាប់បែកម្ដងៗ អ្នកភូមិបាននាំគ្នារត់ចេញពីភូមិអស់ហើយ។

នៅឆ្នាំ១៩៧៥ អ្នកភូមិបាននាំគ្នាត្រឡប់មកវិញ ប៉ុន្តែផ្ទះសម្បែងគឺបែកបាក់គ្មានសល់ឡើយ។ ក្រោយមក ខ្ញុំបានរៀបការជាមួយប្រពន្ធរបស់ខ្ញុំឈ្មោះ អ៊ីឈន។ ឪពុករបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅឆ្ងាយពីខ្ញុំ ព្រោះខ្មែរក្រហមដឹងថាឪពុករបស់ខ្ញុំធ្លាប់បានទៅរស់នៅប្រទេសវៀតណាម។ ចំណែកបងប្រុសរបស់ម្នាក់បានរត់ទៅប្រទេសវៀតណាម។ ខ្ញុំមិនពេញចិត្តដែលឪពុកខ្ញុំរបស់ត្រូវបានជម្លៀសទៅឆ្ងាយ ដោយតែគាត់ធ្លាប់ទៅវៀតណាម និងមិនព្រមបើកអង្ករឲ្យខ្ញុំ។ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦ ខ្ញុំបានភៀសខ្លួនទៅវៀតណាម ព្រោះបងខ្ញុំបានមកចាំទទួលខ្ញុំជាមួយកូនរបស់គាត់ម្នាក់ទៀត ចំណែកប្រពន្ធរបស់ខ្ញុំបានស្លាប់ដោយសារជំងឺ។ ក្រោយពេលទៅដល់វៀតណាម ខ្ញុំបានប្រើប្រាស់អត្តសញ្ញាណបណ្ណបងប្រុសរបស់ខ្ញុំដើម្បីបង្ហាញទៅទាហានវៀតណាម។ ខ្ញុំរកស៊ីរើសអេតចាយដែក ស្ពាន់ ដើម្បីលក់។ ក្រោយមកវៀតណាមបានធ្វើអត្តញ្ញាណបណ្ណវៀតណាមឲ្យខ្ញុំ។



ចូង សឿន ភេទប្រុស អាយុ៧០ឆ្នាំ រស់នៅភូមិមង់ ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឆ្នាំ១៩៧៩ ខ្ញុំត្រឡប់ទៅស្រុកកំណើតវិញ ព្រោះបងប្រុសរបស់ខ្ញុំបានស្លាប់នៅវៀតណាមដោយសារតែជំងឺ។ ពេលខ្ញុំមកដល់ផ្ទះឪពុកម្ដាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅក្រចេះអស់ទៅហើយ។ នៅក្នុងឆ្នាំ១៩៧៩ ក្នុងភូមិនៅមានយោធាខ្មែរក្រហមចូលមក ប៉ុន្តែត្រូវកងទ័ពវៀតណាមវាយបណ្ដេញចេញ។ ខ្ញុំត្រូវបានអ្នកភូមិជ្រើសរើសឲ្យធ្វើអនុប្រធានភូមិមង់ ប៉ុន្តែដោយសារខ្ញុំមិនបានរៀនសូត្រ និងមិនចេះអក្សរ ទើបមួយរយៈក្រោយមកខ្ញុំបានលាឈប់។ ខ្ញុំនិងគ្រួសារបានធ្វើស្រែចម្ការ ដាំស្រូវ ដាំកៅស៊ូ រហូតមកដល់សព្វថ្ងៃ។



ប៉ែន ផាត់ ភេទប្រុស អាយុ៧៣ឆ្នាំ រស់នៅភូមិអូរអន្លាម ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ៦. ប៉ែន ផាត់

ប៉ែន ផាត់ ភេទប្រុស អាយុ៧៣ឆ្នាំ កើតនៅថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៤៩ បានរៀបរាប់អំពីជីវិតរបស់គាត់ថា ខ្ញុំមានស្រុកកំណើតនៅភូមិមង់ ឃុំជាំ ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំមកនៅភូមិស៊ីងអន្លាម ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ អង់ ប៉ែន ស្លាប់នៅសម័យ ប៉ុល ពត ដោយសារអត់បាយ ចំណែកម្ដាយរបស់ខ្ញុំក៏ស្លាប់ក្នុងសម័យខ្មែរក្រហមដែរ។ ខ្ញុំមានកូនចំនួន៨នាក់ គឺស្រី៤នាក់ និងប្រុស៤នាក់ ប៉ុន្តែបានស្លាប់ម្នាក់។

កាលពីកុមារ ខ្ញុំបានសិក្សារៀនសូត្រតិចតួចព្រោះគ្មានសាលារៀន។ ខ្ញុំរៀននៅវត្តមេមត់បានប្រមាណ៣ឆ្នាំក្រោយមក ក៏ផ្លាស់មករៀននៅវត្តក្រវៀនវិញ។ កាលនោះដោយសារតែព្រះសង្ឃវាយខ្ញុំរាល់ថ្ងៃទើបខ្ញុំឈប់រៀន ព្រោះសម័យនោះព្រះសង្ឃ គឺជាគ្រូបង្រៀន។ ក្រោយពេលខ្ញុំឈប់រៀន ខ្ញុំក៏ត្រឡប់មកធ្វើស្រែចម្ការជាមួយឪពុកម្ដាយនៅភូមិមង់វិញ។ នៅពេលខ្ញុំមានអាយុ១៨ឆ្នាំ ក៏មានការទម្លាក់គ្រាប់បែកនៅក្នុងភូមិមង់ ឃុំជាំ ស្រុកមេមត់។ ពេលនោះខ្ញុំមិនដឹងថាហេតុអ្វីបានជាមានការទម្លាក់គ្រាប់បែកនៅក្នុងភូមិមង់ឡើយ។ ការទម្លាក់គ្រាប់បែកនៅក្នុងភូមិមង់នោះគឺនៅអំឡុងចូលឆ្នាំខ្មែរ។ មានក្មេងប្រុសៗចំនួនបួនទៅ ប្រាំនាក់បានគេវក្រមា និងកន្សែង ពេលដែលយន្តហោះកំពុងតែហោះចុះឡើង ហើយមិនយូរប៉ុន្មានក៏មានការទម្លាក់គ្រាប់បែកតែម្ដង គឺចាប់ពីម៉ោង១រសៀល រហូតដល់ ម៉ោង៥រសៀល ទើបឈប់។ ហេតុការណ៍ទម្លាក់គ្រាប់បែកនោះបានធ្វើឲ្យមានមនុស្សរងរបួសដោយសារអំបែងគ្រាប់ និងស្លាប់ចំនួន៥នាក់ ចំណែកផ្ទះសម្បែងបានរងការខូចខាត។ ពីមុនភូមិមង់មិនសូវមានមនុស្សច្រើនទេហើយផ្ទះសម្បែងក៏មិនសូវច្រើនដែរ។ ភាគច្រើនផ្ទះនៅក្នុងភូមិមង់ប្រក់ស្លឹក។ បន្ទាប់ពីមានមនុស្សស្លាប់ និងផ្ទះសម្បែងត្រូវបានខូចខាតដោយសារការទម្លាក់គ្រាប់បែករួចមក ឧត្តមសេនីយ៍ លន់ នល់ និងស្ថានទូតអាមេរិកបានចុះមកសាងសង់ផ្ទះឲ្យប្រជាជនវិញ។ លន់ នល់ បានជិះយន្តហោះមក ហើយមានឡាន និងមានទាហានជាច្រើននាក់ទៀតមកយាមការពារ។ រដ្ឋាភិបាលរបស់ លន់ នល់ បានសង់ផ្ទះឲ្យប្រជាជនចំនួន១៥ខ្នង មានផ្ទះគ្រួសារខ្ញុំ, ផ្ទះតាចុង, ផ្ទះផែ, អ៊ួច, ប៊ឹក និង គា ក្រៅពីនោះខ្ញុំមិនចាំទេ។ ចំពោះគ្រួសារដែលមានសមាជិកស្លាប់ដោយសារគ្រាប់បែក រដ្ឋាភិបាលបានចែកក្រណាត់ សម្លៀកបំពាក់

និងលុយ បន្ថែមទៀត។ បន្ទាប់ពីទទួលផ្ទះថ្មីរួច ប្រជាជននៅភូមិមង់មិនដែលបានដេកក្នុងផ្ទះនោះទេ។ គ្រួសារខ្ញុំភាគច្រើនដេកនៅក្នុងព្រៃ ព្រោះខ្លាចមានការទម្លាក់គ្រាប់បែក និងចោរប្លន់។ គ្រួសារខ្ញុំមកដាក់បាយឲ្យជ្រូក និងមាន់ ពេលល្ងាច ហើយពេលយប់ទៅដេកក្នុងព្រៃវិញ។ នៅឆ្នាំ១៩៧៣ ខ្ញុំចេញពីភូមិមង់ទៅរស់នៅភូមិផ្សេង។ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើជាសមាជិកគណៈកងតូច បែងចែកការងារឲ្យប្រជាជន ដូចជា ទៅស្ទូងប៉ុន្មាននាក់ ដកប៉ុន្មាននាក់ ធ្វើជីប៉ុន្មាននាក់ អ្នកដាំស្លប៉ុន្មាននាក់ ដាំបន្លែប៉ុន្មាននាក់ នៅមើលកូនក្មេងប៉ុន្មាននាក់ ដើម្បីធ្វើរបាយការណ៍ផ្ញើរទៅថ្នាក់លើរៀងរាល់ថ្ងៃ។ ប្រធានកងតូចមានបីនាក់គឺឈ្មោះ តា ហ៊ី និង តា សី ចំណែកខ្ញុំជាសមាជិក។ ពេលធ្វើរបាយការណ៍រួចហើយ យើងយកទៅឲ្យកម្មាភិបាលនៅឃុំដាំក្រវៀនដោយផ្ទាល់។ កាលនោះខ្មែរក្រហមបានបើកកង់មួយឲ្យខ្ញុំជិះយករបាយការណ៍ជូនខាងឃុំ ហើយពេលខ្លះក៏ខ្ញុំដើរដែរ។ នៅពេលប្រជុំម្តងៗ ខ្មែរក្រហមដាក់ផែនការការងារច្រើនណាស់។ ផែនការដែលខ្មែរក្រហមលើកឡើងនោះគឺការបង្កបង្កើនផល គឺធ្វើស្រែនៅក្នុង១ឆ្នាំឲ្យបានប៉ុន្មានតោន ហើយផលដែលទទួលបានគឺត្រូវយកទៅដាក់រួម។ ខ្មែរក្រហមប្រជុំក្នុងមួយខែបីទៅបួនដង ដើម្បីនិយាយអំពីការបែងចែកកម្លាំងការងារមិនឲ្យប្រជាជននៅទំនេរឡើយ។ ប្រធានអង្គប្រជុំលើកឡើងអំពីសកម្មភាពនៅក្នុងភូមិឃុំអំពីបញ្ហាហូបមិនឆ្អែតហូប ម្ហូបមិនឆ្ងាញ់មិនបានសម្រាក ហើយប្រសិនបើមានអ្នករាយការណ៍ប្រាប់ទៅប្រធានក្រុមអ្នកដែលរាយការណ៍ទាំងនោះត្រូវបានទាហានខ្មែរក្រហមចុះមកសួរនាំភ្លាមៗ។ នៅទីនោះមានជង្រុកដាក់ស្រូវធំៗណាស់ ប៉ុន្តែប្រជាជនមិនដែលបានហូបឆ្អែតឡើយ។ ចុងភៅដាំតែបបរឲ្យហូបប៉ុណ្ណោះ គឺមិនដែលដាំបាយឲ្យហូបឡើយ។ ចំណែកស្រូវទាំងនោះខ្មែរក្រហមយកទៅដូរយកថ្នាំជក់ ប្រហុក និងរបស់របរផ្សេងៗទៀត។ ក្រោយមក ខ្មែរក្រហមបានដកខ្ញុំចេញពីគណៈកងតូច ព្រោះដោយសារឃើញប្រពន្ធរបស់ខ្ញុំហូបចុកឆ្អែត ព្រោះខ្ញុំបានយកអង្ករ និងម្ហូបឲ្យប្រពន្ធខ្ញុំហូបពេលមានផ្ទៃពោះ។ ខ្មែរក្រហមចោទខ្ញុំថា ក្បត់ជាមួយអង្គការ។ ក្រោយមកខ្មែរក្រហមជម្លៀសខ្ញុំចេញទៅស្រុកស្នួល ខេត្តក្រចេះ ចំណែកម្តាយ និងឪពុករបស់ខ្ញុំបានស្លាប់អស់ហើយ។ ខ្ញុំមិនបាននៅទុកដាក់សពឪពុកខ្ញុំទេ ពីព្រោះអង្គការថាមានកម្លាំងគ្រប់គ្រាន់រៀបចំហើយ។ នៅទីនោះ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យលើកប្រព័ន្ធភ្លឺស្រែ។ បន្ទាប់មក ខ្ញុំត្រូវបានជម្លៀសទៅស្រុកស្នួលត្រង់បានរយៈពេលមួយខែ ទើបកងទ័ពស្ម័គ្រចិត្តវៀតណាមវាយចូលមក និងឲ្យត្រឡប់មកផ្ទះរៀងៗខ្លួនវិញ។ ខ្ញុំបានជិះឡានពីកំពង់ចាមរហូតមកដល់ស្រុកមេមត់។ ខ្ញុំធ្វើមេភូមិចាប់តាំងពីឆ្នាំ១៩៧៩រហូតមក។ ប៉ុន្តែនៅពេលបច្ចុប្បន្ន ខ្ញុំបានធ្លាក់មកធ្វើជាអនុប្រធានភូមិអូអង្គាម ឃុំដាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ បន្ទាប់ពីមានការបោះឆ្នោត។



ស្តូបគោរពវិញ្ញាណក្ខន្ធដែលត្រូវបានសាងសង់ឡើងតាំងពីសម័យសង្គ្រាមវៀតណាម ដើម្បីឧទ្ទិសដល់អ្នកដែលបានបាត់បង់ជីវិតដោយសារការទម្លាក់គ្រាប់បែក។
(ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវរបស់ ឯម ម៉ើ ក្នុងរបបខ្មែរក្រហម

*ឈុំ រ៉ា*




ឈ្មោះ ឯម ម៉ើ អាយុ៩១ឆ្នាំ និងភរិយាកំពុងផ្តល់បទសម្ភាសន៍ដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារ កោះថ្មៗ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឯម ម៉ើ ភេទប្រុស កើតនៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៣១បានរៀបរាប់ថា ខ្ញុំមានបងប្អូនចំនួន៧ នាក់ (ប្រុស៦នាក់ និងស្រី១នាក់) ហើយខ្ញុំគឺជាកូនច្បងៗ ខ្ញុំមានម្តាយឈ្មោះ ឡុ ឈុនបានស្លាប់ តាំងពីខ្ញុំមានអាយុ១២ឆ្នាំ ចំណែកឪពុកឈ្មោះ ឯមៗ ម្តាយឪពុករបស់ខ្ញុំគឺជាជនជាតិខ្មែរ មានស្រុកកំណើតនៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ (កាលពីមុនខេត្តកំពង់ចាម)ៗ កាលពីកុមារភាព ខ្ញុំមិនបានរៀនសូត្រច្រើនទេៗ បងប្រុសរបស់ខ្ញុំបានជំរុញឲ្យខ្ញុំចូលរៀនដែរ ប៉ុន្តែខ្ញុំមិនចង់បែកពីម្តាយៗ កាលពីតូចខ្ញុំគ្មានសម្លៀកបំពាក់ទេ ខ្ញុំបានយកសម្បកឈើមកដំឲ្យទក់ដើម្បីបាំងខ្លួនៗ នៅពេលខ្ញុំអាយុ១១ឆ្នាំ ខ្ញុំបានចូលរៀននៅវត្តក្រវៀនៗ ខ្ញុំរៀនបានរយៈពេលបួនឆ្នាំ ព្រះចៅអធិការវត្តឈ្មោះ វែង បានឲ្យខ្ញុំបួសៗ ខ្ញុំបានរៀនធម៌វិន័យ និងរៀនអក្សរសាស្ត្រ ពីគ្រូ អ៊ុង, គ្រូ វែង និង គ្រូជឹងៗ អំឡុងពេលដែលសិក្សានៅក្នុងវត្តគឺ មានសិស្សចំនួន៤០នាក់ នៅក្នុងនោះមានសិស្សស្រីចំនួន៥ នាក់តែប៉ុណ្ណោះៗ កាលពីសង្គមចាស់ ប្រជាជនមិនសូវឲ្យកូនស្រីសិក្សារៀនសូត្រទេ ព្រោះខ្លាចកាលណាកូនស្រីមានចំណេះដឹងច្រើន គឺចេះសរសេរសំបុត្រស្នេហាៗ ខ្ញុំបួសបានរយៈពេល៨វស្សា គឺបួសសាមណេរបានរយៈពេល៥ព្រះវស្សា និងបួសភិក្ខុបានរយៈពេល

៣វស្សា។ ក្រោយមក ខ្ញុំបានសឹកមកប្រកបរបរធ្វើស្រែចម្ការវិញ។ ក្រោយពីសឹករួច មេឃុំហៅខ្ញុំទៅឲ្យជួយសរសេររបាយការណ៍ជំនួសស្មៀន ព្រោះស្មៀនមិនសូវធ្វើការ ហើយផឹកស្រា។ ខ្ញុំបានធ្វើការជំនួសស្មៀនអស់រយៈពេលបីខែ ក៏សុំមេឃុំមកលេងផ្ទះ ព្រោះអត់មានអ្នកជួយធ្វើការងារជំនួសឪពុកម្ដាយ។ កាលពីសង្គមចាស់ នៅក្នុងភូមិសាទុំមានផ្លូវតែមួយខ្សែប៉ុណ្ណោះ។ ដំបូងបារាំងបានចូលមកដាំដើមកៅស៊ូនៅក្រឡុងសិទ្ធិ និងខ្លាយ ដែលមានកម្មករជាជនជាតិខ្មែរ និងជនជាតិវៀតណាម។ ឪពុករបស់ខ្ញុំមានចំណេះដឹង ដូច្នេះខាងរាជការឲ្យគាត់វាស់វែងដីធ្លីសម្រាប់ធ្វើផ្លូវ។ នៅសង្គមចាស់អ្នកចេះដឹង ជនជាតិបារាំងហៅឈ្មោះថា ជី។ បារាំងបានធ្វើផ្លូវពីស្រុក ឡុកនិញ ទៅព្រៃនគរ និងភ្ជាប់មកភូមិសាទុំ ភូមិប្រិយ៍, អូរអន្តាម, ក្រឡុងសិទ្ធិ រហូតទៅដល់មេមត់។ កាលពីដើមប្រជាជននៅក្នុងភូមិសាទុំមិនហ៊ានចូលព្រៃទេព្រោះខ្លាចសត្វខ្លា និងដំរី។ ខ្ញុំបានជួបសម្ដេចព្រះ នរោត្តម សីហនុ ម្ដង ពេលដែលទ្រង់ចុះមកដល់ស្រុកមេមត់។ កាលពីដើម នៅក្នុងភូមិសាទុំ មានផ្ទះចំនួន១៧ ខ្នងតែប៉ុណ្ណោះ។ ភូមិសាទុំក្លាយមកពីរឿងដំណាល «ស្រីយំ» ព្រោះមានស្រីម្នាក់ដើរមកពីខាងភូមិព្រៃ ប៉ុន្តែដោយសារចុកជើងខ្លាំងពេកក៏អង្គុយយំ។ ក្រោយមកដោយសារអ្នកស្រុកនិយាយមិនច្បាស់ ក៏បាននិយាយតៗគ្នាថា «សាទុំ» ។ ប្រជាជនខ្លះហៅភូមិនេះថា «ស្ទុំ»។ ចំណែកប្រជាជនខ្លះទៀតដំណាលថា ពីដើមមានសត្វបក្សីជាច្រើនហើរមកទុំលើដើមពោធិ៍ ហើយក៏ហើរត្រឡប់ទៅវិញ ទើបអ្នកភូមិនាំគ្នាហៅថា «ស្រទុំ» ជាប់មក ។

កាលពីសម័យបារាំង ប្រជាជននាំគ្នាវេចខោអាវត្រៀមរួចជាស្រេច ហើយពេលឮសំឡេងគ្រាប់កាំភ្លើងម្ដងៗក៏នាំគ្នាចូលរត់ពួននៅក្នុងព្រៃព្រោះខ្លាចចោរប្លន់។ ខ្ញុំដឹងថាចោរទាំងអស់នោះមានខ្មែរ និងវៀតណាមខ្លះ។ បារាំងបានយកជនជាតិវៀតណាមមកពីហាណូយមកចៀរជ័រកៅស៊ូ ជំនួសឲ្យជនជាតិខ្មែរ ព្រោះបារាំងប្រើខ្មែរមិនបាន។ នៅពេលដែលខ្ញុំពេញកំលោះ ខ្ញុំសុំម្ដាយរៀបការជាមួយនារីម្នាក់ដែលខ្ញុំស្រឡាញ់នៅក្នុងភូមិ ប៉ុន្តែដំបូងម្ដាយរបស់ខ្ញុំបដិសេធ។ ខ្ញុំនៅតែចចេសចង់រៀបការជាមួយនារីនោះដដែលដែលត្រូវជាកូនស្រីរបស់ប៉ូលីសឈ្មោះ ឡឹក និងប្រពន្ធឈ្មោះ យ៉ុង។ ក្រោយមក ខ្ញុំបានរៀបការជាមួយនារីនោះបានកូនពីរនាក់ ហើយកូនម្នាក់បានស្លាប់នៅក្នុងសម័យខ្មែរក្រហម។ ប្រពន្ធដើមរបស់ខ្ញុំ មិនសូវរវល់ជាមួយគ្រួសារ និងខ្វល់ខ្វាយចំពោះកូនៗទេ។ ដោយសារតែយើងរស់នៅមិនចុះសម្រុងនឹងគ្នា ខ្ញុំបាននិយាយជាមួយប្រពន្ធរបស់ខ្ញុំថា បើយើងមិនស្រឡាញ់គ្នាទេយើងលែងគ្នា។ ក្រោយពេលខ្ញុំបានលែងលះជាមួយប្រពន្ធដើមរួចរាល់ហើយ ខ្ញុំបានរៀបការជាមួយប្រពន្ធក្រោយឈ្មោះ ឆន និងមានកូនចំនួន៧ នាក់។ ក្រោយមក ប្រពន្ធក្រោយរបស់ខ្ញុំពិការដៃម្ខាងដោយសារពស់ចឹក ។

នៅពេលមានបាតុកម្មទម្លាក់សម្ដេចសីហនុ ខ្ញុំចាប់ផ្ដើមរកស៊ីលក់ដូរអង្ករ។ ខ្ញុំធាក់កង់ដឹកអង្ករពីមេមត់យកទៅលក់ឲ្យកងទ័ពវៀតណាម។ ខ្ញុំដឹកអង្ករម្ដងបាន២០គីឡូក្រាម ហើយក្នុងមួយគីឡូក្រាម ខ្ញុំចំណេញមួយរៀល។ នៅពេលយប់ខ្ញុំមិនសូវបានដេកទេ ព្រោះត្រូវចេញទៅដឹកអង្ករយកទៅលក់ឲ្យកងទ័ពវៀតកុង។ ខ្ញុំដឹកជញ្ជូនអង្ករឲ្យកងទ័ពវៀតកុងនៅម្ដុំត្រពាំងតាហត និងត្រពាំងឈើខ្ទីម។ កាលនោះមានអ្នកដឹកអង្ករលក់ច្រើននាក់ មកពីឃុំជាំក្រវៀន។ ខ្ញុំលក់អង្ករគិតជាលុយខ្មែរ ហើយមេការដែលរង់ចាំទិញអង្ករឈ្មោះ សៅ ភុក។ ដោយសារតែមានសង្គ្រាមរវាងអាមេរិកាំង និងកងទ័ពវៀតកុង ខ្ញុំមិនបានចាយលុយទេ ហើយក្របីញីរបស់ខ្ញុំមួយក្បាល និងក្របីឈ្មោលមួយក្បាល លក់បានត្រឹមតែ ១០០០ រៀលតែប៉ុណ្ណោះ។

កងទ័ពវៀតកុងបានសង់មន្ទីរពេទ្យនៅក្នុងព្រៃកាដូនម៉ាច និងព្រៃតាសឹង។ នៅមន្ទីរពេទ្យនោះគឺមានផ្នែកវះកាត់ដែលប្រើឧបករណ៍ទំនើបៗ។ កងទ័ពវៀតកុងបានជួលខ្មែរឲ្យជួយបកប្រែ ហើយកងទ័ពវៀតកុងខ្លះអាចនិយាយភាសាខ្មែរបានប៉ុន្តែមិនសូវច្បាស់។ ខ្ញុំបានយកម្ដាយក្មេករបស់ខ្ញុំទៅព្យាបាល

នៅមន្ទីរពេទ្យរបស់វៀតកុង ក្រោយមកម្តាយក្មេករបស់ខ្ញុំបានជាសះស្បើយឡើងវិញ។ ក្រោយពេលយោធាអាមេរិកស៊ើបដឹងថាមានកងទ័ពវៀតកុង ទើបមានការទម្លាក់គ្រាប់បែកដើម្បីសម្លាប់កងទ័ពវៀតកុង។ គ្រាប់បែកបេ-៥២ ជាច្រើនគ្រាប់បានផ្ទុះរង្គើរដល់ផ្ទះប្រជាជនដែលរស់នៅក្នុងភូមិសាទុំ និងផ្ទះខ្លះដែលប្រក់ស្លឹកទ្រាំងបានរបើកដំបូល។ នៅវេលាម៉ោង៩ល្ងាច មានការទម្លាក់គ្រាប់លើទីជម្រកកងទ័ពវៀតកុង បណ្តាលឲ្យកងទ័ពវៀតកុង និងប្រជាជនមួយចំនួនបានស្លាប់ ហើយប្រជាជននៅក្នុងភូមិសាទុំមួយចំនួនទៀតរងរបួស។ នៅអំឡុងពេលសង្គ្រាមរវាងអាមេរិក និងកងទ័ពវៀតកុងបានផ្ទុះឡើង ប្រជាជននៅក្នុងភូមិសាទុំ បានភៀសខ្លួនទៅរស់នៅភូមិដាំក្រវៀន និងភូមិដូង។ នៅពេលចប់សង្គ្រាម ទើបប្រជាជននាំគ្នាមករស់នៅក្នុងភូមិវិញ។

នៅសម័យខ្មែរក្រហម ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិសាទុំឲ្យទៅនៅភូមិខ្វរ។ ខ្មែរក្រហមចាត់តាំងឲ្យខ្ញុំនៅកងសិប្បកម្ម ធ្វើនង្គ័ល និងរនាស់។ ចំណែកប្រពន្ធកូនរបស់ខ្ញុំនៅក្នុងភូមិសាទុំដដែល។ មិនយូរប៉ុន្មាន ខ្មែរក្រហមបានជម្លៀសប្រពន្ធរបស់ខ្ញុំឲ្យមករស់នៅភូមិខ្វរជាមួយខ្ញុំដែរ។ ប្រធានកងបានចាត់តាំងខ្ញុំឲ្យទៅរកត្រី និងសាច់មកដាក់នៅក្នុងសហករណ៍ ចំណែកប្រពន្ធរបស់ខ្ញុំប្រធានកងចាត់តាំងឲ្យទៅស្ទូងស្រូវ និងធ្វើស្រែ។ មួយឆ្នាំក្រោយមក ខ្មែរក្រហមជម្លៀសគ្រួសារខ្ញុំឲ្យទៅនៅភូមិតាអឹម ឃុំដាំតាម៉ោ ស្រុកមេមត់វិញ។ នៅទីនោះ ខ្ញុំធ្វើស្រែ លើកប្រព័ន្ធភ្លឺស្រែ និងជីកប្រឡាយ។ តមក ខ្មែរក្រហមបានជម្លៀសខ្ញុំឲ្យទៅនៅសហករណ៍ ក្នុងស្រុកឆ្លូង ខេត្តក្រចេះ។ ប្រធានសហករណ៍បានចោទប្រកាន់ខ្ញុំថា លួចក្របី ហើយយកកាំភ្លើងមកភ្ជង់ក្បាលខ្ញុំ។ ប្រធានសហករណ៍យកខ្ញុំទៅឃុំរយៈពេលមួយយប់។ ខ្ញុំបាននិយាយថា ខ្ញុំមិនបានធ្វើអ្វីខុសនោះទេ ប្រសិនបើមិត្តសម្លាប់ខ្ញុំក៏ខ្ញុំមិនខ្លាចស្លាប់ដែរ។ ព្រឹកឡើងប្រធានសហករណ៍ដោះលែងឲ្យខ្ញុំត្រឡប់មកផ្ទះវិញ ហើយបន្ទាប់មកបានចាត់តាំងខ្ញុំឲ្យបររទេះដឹកសំណាប។ ចំណែកកូនរបស់ខ្ញុំប្រធានកងប្រើឲ្យរើសអាចម៍គោដើម្បីធ្វើជី។ ចំពោះម្ហូបអាហារ គឺមានតែបបរប៉ុណ្ណោះ ហើយខ្ញុំហូបមិនដែលឆ្អែតទេ។ ថ្ងៃមួយ ខ្ញុំបានបររទេះទៅដឹកសំណាបឲ្យអ្នកស្ទូង។ ខ្ញុំគិតក្នុងចិត្តថា ប្រសិនបើខ្ញុំមិនលួចច្បាស់ជាដាច់ពោះស្លាប់មិនខាន ដូច្នេះខ្ញុំបានយកផ្លែសន្ទូចលាក់ទុកនៅក្នុងហោប៉ៅខោ។ នៅពេលខ្ញុំទៅដល់បឹង ខ្ញុំយកផ្លែសន្ទូចចេញពីហោប៉ៅដើម្បីស្ទូចត្រី។ ក្រុមដឹកសំណាបរបស់ខ្ញុំមានគ្នាប្អូននាក់ ដូច្នេះខ្ញុំនិយាយប្រាប់អ្នកនៅក្នុងក្រុមថា ប្រសិនបើយើងចង់ហូបឆ្អែតយើងកុំរាយការណ៍ឲ្យអ្នកដទៃដឹង។ នៅថ្ងៃនោះយើងស្ទូចបានត្រី និងបានហូបឆ្អែត។ ខ្ញុំបានលួចខ្ចប់ត្រីយកទៅឲ្យប្រពន្ធនិងកូនរបស់ខ្ញុំនៅផ្ទះថែមទៀត។ នៅទីនោះ ឪពុកក្មេករបស់ខ្ញុំបានស្លាប់ដោយសារអត់អាហារ។ ក្រោយមកទៀត ខ្មែរក្រហមឲ្យខ្ញុំធ្វើជាជាងឈូសឈើ និងសសរផ្ទះ។ មេកងបានកំណត់ឲ្យខ្ញុំឈូសសសរផ្ទះឲ្យបាន ២ទៅ៣ដើម ក្នុងមួយថ្ងៃ។ ប្រសិនបើខ្ញុំឈូសមិនហើយ អង្គការនឹងយកខ្ញុំទៅរៀនសូត្រ។ ខ្ញុំរស់នៅក្នុងសហករណ៍ក្នុងស្រុកឆ្លូងរយៈពេលមួយឆ្នាំ ទើបខ្មែរក្រហមជ្រើសរើសខ្ញុំឲ្យទៅនៅស្រែរនាម ឃុំយ្សឹម ស្រុកឈ្លូល ខេត្តក្រចេះវិញ។ នៅថ្ងៃនោះ ខ្មែរក្រហមបានជជែកគ្នាថានឹងបើករថយន្តទៅក្រុងក្រចេះទាំងយប់។ ក្រោយពេលខ្ញុំស្តាប់ឮដំណឹងនេះ ខ្ញុំជាមួយកូនៗនិងប្រពន្ធខ្ញុំលួចឡើងជិះរថយន្តខ្មែរក្រហមនោះ។ ព្រឹកឡើងខ្ញុំនិងគ្រួសារបានចុះពីលើឡាន ឃើញដូច្នេះអ្នកបើករថយន្តបានសួរថាខ្ញុំ តើលោកពូឡើងជិះលើឡានតាំងពីពេលណា។ ខ្ញុំបានប្រាប់តាមត្រង់ថា លួចឡើងតាំងពីយប់មិញម្ល៉េះ បន្ទាប់មកខ្មែរក្រហមបានសួរខ្ញុំថា តើលោកពូចង់ទៅណា? ខ្ញុំបានឆ្លើយថា ខ្ញុំមិនដឹងទៅណាទេ។ ខ្មែរក្រហមបាននាំខ្ញុំទៅរកកន្លែងសម្រាក និងឲ្យអង្ករមកខ្ញុំដើម្បីដាំបាយហូប។ នៅថ្ងៃបន្ទាប់ ខ្ញុំនិងគ្រួសារបានដើររហូតទៅដល់ឃុំថ្មគ្រែ ស្រុកចិត្តបុរី ខេត្តក្រចេះ។ នៅទីនោះ ខ្ញុំឃើញយោធា និងត្រីងៀតជាច្រើន។ ដោយសារតែខ្ញុំឃ្លានខ្លាំងពេក ទើបខ្ញុំដាច់ចិត្តសុំត្រីងៀតពីយោធាយកមកហូប។ នៅខណៈនោះប្រធាន

សហករណ៍ថ្មគ្រែបានសួរខ្ញុំថា លោកពូមកពីណា? ខ្ញុំឆ្លើយថា ខ្ញុំមិនដឹងមកពីណាទេព្រោះជិះ ឡានពេលយប់។ ខ្ញុំនិយាយទៅកាន់ប្រធានសហករណ៍ថា បើមិត្តចង់សម្លាប់ខ្ញុំក៏សម្លាប់ចុះ។ ប៉ុន្តែប្រធានសហករណ៍មិនបានធ្វើបាបខ្ញុំទេ ហើយបានចាត់តាំងខ្ញុំទៅធ្វើសម្បុកមាន់។ ដោយសារតែឃ្លានខ្លាំងពេក ខ្ញុំបានលួចពងមាន់នៅក្នុងសម្បុកមួយគ្រាប់។ ពេលនោះខ្ញុំបេះដាងឈើ ដូច្នេះប្រធានសហករណ៍ឲ្យខ្ញុំធ្វើដាងសង់ផ្ទះ។ ថ្ងៃមួយ មានអ្នកឃ្វាលគោម្នាក់បានប្រាប់ខ្ញុំថា នៅផ្ទះដែលខ្ញុំរស់នៅមានមនុស្សស្លាប់ទាំងគ្រួសារ ឪពុកម្តាយ និងកូន គឺស្លាប់ដោយសារលេបថ្នាំព្រោះតែស្តាយទ្រព្យសម្បត្តិ។ អ្នកឃ្វាលគោបានសួរខ្ញុំថា ខ្លាចខ្មោចដែរឬទេ? ខ្ញុំឆ្លើយថា ស្លាប់ហើយគ្មានអ្វីត្រូវខ្លាចឡើយ។ មិនបានប៉ុន្មានថ្ងៃផង ខ្មែរក្រហមជម្លៀសខ្ញុំតាមការណូតទៅស្រុកស្ទឹងត្រង់ បន្ទាប់មកជិះឡានបន្តទៅភូមិតាអុង ឃុំតាអុង ស្រុកចំការលើ ដោយគ្មានបាយហូបឡើយ គឺយើងហូបបាយលាយចេក។ ខ្មែរក្រហមបានប្រើខ្ញុំឲ្យរែកទឹក ជីកដី ធ្វើជី ដើម្បីស្រោចស្តែ ប៉ុន្តែដោយសារតែខ្ញុំអត់បាយយូរថ្ងៃទើបខ្ញុំគ្មានកម្លាំងរែកទឹក។ ខ្ញុំរស់នៅទីនោះបានកន្លះខែ កងទ័ពវៀតណាមចូលមកដល់ ហើយយើងក៏ធ្វើដំណើរដោយថ្មើរជើងមកស្រុកកំណើតវិញ។ ពេលខ្ញុំមកក្រុងសួង ខ្ញុំដើររើសកួរស្រូវ រួចបន្តដំណើរមករស់នៅក្នុងភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ រហូតមកដល់សព្វថ្ងៃ។

សាលាឃុំដាំក្រវៀន ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវបុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖

truthchenda.s@dccam.org

សូមអរគុណ!



























# ទណ្ឌកម្មអ្នកទោសកុមារ មីត្នោត ដើមចារ ត្រពាំងតាទិត

ជំនោររដូវរំហើយពេលព្រឹកព្រលឹមៗ មេឃចុះអ័ព្ទបែកផ្សែងត្រជាក់ល្អណាស់ តែរូបខ្ញុំនៅខុសស្រឡះពីធម្មជាតិទាំងឡាយជុំវិញខ្លួន ដែលមានសេរីភាពជាងខ្ញុំ។

ខ្ញុំដឹកគោគ្មានអាវដណ្ដប់ ស្ពាយខ្សែនិងស្នែងយកដៃឱបជាប់នឹងដើមទ្រូង ដើម្បីឲ្យមានភាពកក់ក្ដៅ។ ខ្ញុំបណ្ដើរគោនឹងខ្សែឲ្យស៊ីស្មៅ មិនហ៊ានចងគោដើរចោលវាទេ។

អាកាសធាតុដ៏ត្រជាក់ក្រោមទឹកសន្សើមធ្លាក់មិនដាច់ៗ "ហេតុអ្វីព្រះអាទិត្យយឺតយូរក្របញ្ចេញរស្មីកម្ដៅម្ល៉េះ? មិនអាណិតដល់រូបខ្ញុំដែលកំពុងឈរឱបដៃរងាកណ្ដាលវាលស្រែល្វឹងល្វើយទេអ្វី?" ខ្ញុំស្ដាប់ទំនួញសោកសៅក្នុងចិត្ត។ កើតមកហើយជាកូនកំព្រាទើបនឹងដឹងក្ដី ព្រហ្មលិខិតឥតប្រណីវាយប្រហារទាំងក្មេងខ្ចីបែបនេះ។

ខ្ញុំចាប់ផ្ដើមនឹករលឹកឪពុកម្ដាយដែលបានឃ្លាតឆ្ងាយពីកូនថ្មីៗនេះគ្មានថ្ងៃត្រឡប់។ ខ្ញុំខំបំភ្លេចវាចោលតាមបណ្ដាំឪពុក មុនពេលគេយកទៅសម្លាប់ដោយនិយាយថា "បើមិនឃើញពុកម៉ែត្រឡប់មកវិញប្រគេសម្លាប់ចោល សូមកូនកុំនឹកពុកម៉ែអី"។ តើមានមនុស្សក្នុងលោកនេះណាម្នាក់ដែលអាចធ្វើបាននោះ។ ខ្ញុំចោទសំណួរហួសវិស័យនេះក្នុងចិត្ត។ ខ្ញុំងើយទៅលើមើលចក្រវាលមហាធំធេង តែវាតូចជាងទំហំនៃទុក្ខកម្មលោកិយរបស់ខ្ញុំទេ។ មើលទៅព្រះសុរិយាបញ្ចេញពន្លឺបំភ្លឺដល់សត្វនិករលើផែនពសុធានេះមែនតែវាមិនអាចបំភ្លឺជីវិត ងងឹតសូន្យសុងរបស់ខ្ញុំឡើយ។ ឱ! ជីវិតខ្ញុំពិតជាងងឹតខ្លាំងណាស់ ហ៊ឹម! ក្នុងភពអស់សង្ឃឹមហើយងាកមកមើលខ្លួនឯងសែនសង្វេគខ្លួនក្រៃនឹងវាសនាកម្សត់សោកាម្ដេចមិនប្រហារឲ្យក្ស័យ ទាំងអស់តែម្ដងទៅ។

កំពុងតែសញ្ជឹងគិតយ៉ាងក្រៀមក្រំសង្វេគក្ដុកក្ដួល ទឹកភ្នែកទាំងគូហូរចេញមកៗ ខ្ញុំសម្លឹងមើលទៅភូមិឃើញព្រះសុរិយាបណ្ដែតខ្លួនពីលើ និងមានហ្វូងគោចេញពីភូមិ ហុយដីទ្រលោមដេញដោយកុមារបួនប្រាំនាក់ និងមេកងកុមារនារីអឿនដើរពីក្រោយផង ឆ្ពោះមកកាន់វាលស្រែក្បែរខ្ញុំដែរ។

កុមារទាំងនោះបានព្រលែងគោនៅវាលស្រែឲ្យស៊ីស្មៅ និងគល់ជញ្ជ្រាំង រួចគេនាំគ្នាបង្កាត់ភ្លើងជាមួយនឹងកន្ទុយខសដែលគេកាន់ពីភូមិរួចនាំគ្នាអង្គុយជារង្វង់កង់រទេះជុំវិញភ្នក់ភ្លើងកុំឲ្យរងា។

ខ្ញុំឈរមើលគោតែម្នាក់ឯងមិនហ៊ានដើរឆ្ងាយពីមីត្នោតទេ។ បន្ទាប់មកមេកងកុមារនារីអឿននោះដើរសំដៅមករកខ្ញុំហើយនិយាយថា "តើមិត្តកុមារវង្សឯងមកចាំគោពីថ្មើរណា?" ខ្ញុំឆ្លើយថា "ខ្ញុំមកតាំងពីព្រលឹមស្រាងៗម្ល៉េះ" គាត់តបមកទៀត "ល្អហើយ! នៅចាំមើលវាបន្តទៀតចុះ មិនត្រូវទៅណាឆ្ងាយពីកន្លែងនេះទេ រង់ចាំទទួលបញ្ជាពីថ្នាក់លើ" ខ្ញុំឆ្លើយថា "បាទ សមមិត្តនារីមេកង" រួចក៏ដើរចេញពីខ្ញុំទៅកាន់កងកុមារកំពុងអង្គុយអាំងភ្លើង ហើយហៅកុមារទាំងនោះមកប្រជុំជីវភាព និងធ្វើស្វ័យទិតៀន។ ខ្ញុំមិនដឹងថាគេនិយាយយ៉ាងម៉េចទេ ព្រោះនៅឆ្ងាយពីគេរំលងមួយស្រែ ស្រាប់តែមិត្តកុមារទាំងនោះងាកមកមើលខ្ញុំព្រមៗគ្នា តែខ្ញុំគិតក្នុងចិត្តថាប្រហែលជាគេឲ្យកុមារមូលដ្ឋានទាំងនោះឃ្លាំមើលខ្ញុំ ខ្លាចគេចវេះពីពិន័យនេះ។ រៀបរាប់រួចមេកងនារីកុមារនោះក៏ដើរចេញទៅ។ បន្ទាប់មកកុមារទាំងនោះបានបំបែកហ្វូងគ្នា អ្នកខ្លះឡើងលេងដើមចារ ឯខ្លះទៀតនៅអាំងភ្លើងនិងដើរបេះផ្លែត្របែកព្រៃ។

ថ្ងៃជិតត្រង់ មេកងនារីនោះស្រែកប្រាប់កុមារមូលដ្ឋានទាំងនោះឲ្យដើរកៀងគោត្រឡប់ទៅភូមិវិញ។ មានកុមារម្នាក់ គឺអាប៉ោងដែលធ្លាប់បបួលខ្ញុំឡើងដើមចារលេង ដើរតាមភ្លឺស្រែក្បែរខ្ញុំ។ ខ្ញុំគិតថា ប្រហែលជាមេកងកុមារនោះឲ្យអាប៉ោងមកប្រាប់ខ្ញុំដឹកគោទៅភូមិដែរហើយមើលទៅ ព្រោះដល់ពេលបាយ តែមិនដូចការគិតទេ។ ខ្ញុំខំញញឹមដាក់អាប៉ោង តែគេដើរធ្វើព្រងើយរួចក៏ដើរហួសទៅ។ ខ្ញុំខកចិត្តខ្ញុំមើលពីក្រោយដោយមានការងឿងឆ្ងល់ ស្រាប់តែសមមិត្តកុមារប៉ោង

ទម្លាក់ផ្លែត្របែកព្រៃមួយមកក្នុងស្រែ។ ខ្ញុំយល់ពីអារម្មណ៍របស់វា គឺពិតជាមេកងនារីកុមារនោះមិនឲ្យកុមារមូលដ្ឋានទាំងនោះទាក់ទងជាមួយខ្ញុំ ព្រោះខ្ញុំជាកុមារមានទោស។ ក្នុងចិត្តត្រេកអរ ព្រោះបានត្របែកហូប។ រៀបស៊ុះទៅរើស ក៏ឮសំឡេងស្រែកក្រោយខ្នង។ ខ្ញុំភ័យស្ទើរបាត់ស្មារតី គិតថាគេដាក់កំហុសខ្ញុំទៀតហើយ។ មិត្តនារីមុខមាំប្រាប់ខ្ញុំថា "នែមិត្តកុមារថ្មី អង្គការមិនទាន់ឲ្យកុមារឯងដឹកគោទៅភូមិទេ ដូច្នេះរង់ចាំទទួលបញ្ជាពីអង្គការបន្តទៀត"។ ខ្ញុំតបទៅវិញថា "បាទសមមិត្តបងមេកង។"

ខ្ញុំគិតថា តើពេលណាគេឲ្យទៅភូមិ។ ទឹកក៏ស្រេកពោះក៏ឃ្លាន ថ្ងៃត្រង់បញ្ចេញកម្តៅក្តៅ នៅកណ្តាលវាលស្រែ។ ដើមឈើមិនឲ្យជ្រកមួយថ្ងៃៗ ឮតែពាក្យថា អង្គការបដិវត្តន៍ ថ្នាក់លើ ប្រជុំជីវភាព រៀនសូត្រ កសាងសមមិត្ត ធ្វើស្វ័យទិតៀន អាកុមារថ្មី អាអ្នក១៧មេសា អាអ្នកភ្នំពេញ តែអង្គការទាំងអស់នោះមិនដឹងនៅឯណាទេ។ (អង្គការ ជាពាក្យថ្លែងតៗគ្នា ដែលការពិត "អង្គការ" គ្រាន់តែជាឈ្មោះ គ្មានរូប គ្មានក្លិន គ្មានសំឡេង តែមានសិទ្ធិអំណាចខ្លាំងក្លាណាស់ ដែលអាចកម្ទេចយើងភ្លាមៗប្រសិនបើយើងនិយាយប៉ះពាល់ដល់កម្មាភិបាលអង្គការបដិវត្តន៍របស់គេ)។

មេកងនារីកុមារដើរបានឆ្ងាយបន្តិច ខ្ញុំក៏លួចរើសផ្លែត្របែកនោះមកហូបជំនួសបាយ។ ទោះជាផ្លែត្របែកព្រៃចត់យ៉ាងណាក៏ទៅជាផ្អែមដែរ។ ចាំបាត់ៗ មិនឃើញមនុស្សម្នាណាម្នាក់ទេ។ ស្ងាត់ឈឹង មានតែខ្ញុំនិងមីគ្នោត។

មេឃមីស្រទុំជ្រាលជ្រៅចាំងពន្លឺពណ៌មាសផ្ទេកៗលើត្រពាំងតាទិត។ ដល់ពេលវេលាមេគោត្រូវចូលក្រោល។ វាចាប់ផ្តើមទាញខ្ញុំសំដៅទៅភូមិ ខ្ញុំខំទាញវាបកក្បាលមកក្រោយវិញ ទាញទៅទាញមក ដូចមនុស្សទាញព្រ័ត្រជាមួយគោ។ ណាមួយខ្លួនខ្ញុំនៅតូចកម្លាំងខ្សោយជាងវា វាទាញទាំងខ្លួនខ្ញុំអូសលើជញ្ជ្រាំង ដួលត្រឡប់ត្រឡិន ខ្ញុំប្រញាប់យកខ្សែចំណងទៅពន្ធ័រុំដើមចារ។ ទៅមុខមិនរួចវាឈរជង្គក់ ខ្ញុំក៏ហត់មើលមុខគ្នាទៅវិញទៅមក។ វាជាសត្វមិនដឹងថាខ្ញុំកំពុងបៀមទុក្ខនិងមានទោសនឹងបដិវត្តន៍ ជាកុមារថ្មីមិនបដិវត្តន៍ពិតនោះទេ។

មិនយូរប៉ុន្មានខ្ញុំបានឃើញមនុស្សម្នាក់ស្លៀកពាក់ខោអាវខ្មៅជួតក្បាលក្រមាដើរពីចម្ងាយសំដៅមករកខ្ញុំ។ មកជិតបន្តិចខ្ញុំឃើញគាត់ច្បាស់ នោះជាសមមិត្តនារីមេកងកុមារ។ គាត់និយាយមកកាន់ខ្ញុំថា "អង្គការអនុញ្ញាតឲ្យសមមិត្តវង្សឯងដឹកគោចូលក្រោលវិញហើយ" ខ្ញុំតបយ៉ាងប្រញាប់ "បាទអរគុណសមមិត្តនារីមេកង" រួចចាប់ផ្តើមស្រាយចំណងមីគ្នោតពីដើមចារ។

មីគ្នោតវាទាញខ្ញុំរត់ផ្លើលដួលផើបៗ ដោយគ្មានកម្លាំងទាញវាតាមសម្រួលទេ។ វាបោលសំដៅចូលភូមិយ៉ាងលឿន។ បញ្ចូលគោក្នុងក្រោលរួចរាល់ហើយ ខ្ញុំក៏រូតរះដើរទៅរោងបាយរួមស្ថិតនៅកណ្តាលភូមិ ព្រោះមិនបានហូបបាយថ្ងៃត្រង់ ឥឡូវឃ្លានស្ទើរដាច់ពោះវៀន។



*រូបភាពឆ្នាំ២០១៩៖ ដើមចារត្រពាំងតាទិត ដែលមេកងនារីកុមារដាក់ទណ្ឌកម្មខ្ញុំឱ្យមកចាំមីគ្នោតនៅទីនេះ និងដើមចារដែលខ្ញុំចងមីគ្នោតត្រូវបានគេកាប់ទុកចោល។ (ឡុង វង្សសមិទ្ធ/សៀវភៅទូលពិឃាដ)*

# ចោរលួចបាយក្តាំង
# វែកឆាចបដីក មេចុងភៅបដិវត្តន៍

ពេលមកដល់រោងបាយ ចុងភៅប្រមូលរៀបចំចានឆ្នាំងទុកដាក់។ ខ្ញុំដើរទៅបើកខ្ទះបាយ ប៉ុន្តែបាយត្រូវបានអ្នកមកមុនហូបអស់។ ខ្ញុំក៏ដើរសំដៅទៅចង្ក្រានបាយ ហើយឃើញខ្ទះបាយមួយនៅក្បែរពាងទឹក។ ខ្ញុំឃើញបាយក្តាំងដែលគេត្រាំទឹក ខ្ញុំមានចិត្តត្រេកអរយ៉ាងខ្លាំង លូកដៃចាប់យកមួយដុំដាក់ចូលក្នុងមាត់។ ប៉ុន្តែមិនទាន់បានទំពាផង ក៏ឮសំឡេងស្រែកពីក្រោយថា "នែអាក្មេង ១៧ មេសា ហ្អែងមកលួចបាយក្តាំងស៊ី ដឹងថាបាយក្តាំងនេះអង្គការទុកឲ្យជ្រូកស៊ីទេឬ?" ខ្ញុំងាកមើលក្រោយឃើញមនុស្សចាស់ដែលជាអ្នកចាត់ចែងផ្នែកចុងភៅមានកាន់វែកឆានៅនឹងដៃស្ទុះមកវាយក្បាលខ្ញុំ ដូចវាយក្បាលឆ្កែ ហើយស្រែកថា "ចេញទៅៗអាកុមារ ១៧ មេសា។"

ខ្ញុំដើរចេញពីកន្លែងនោះដោយយកដៃខ្ទប់ក្បាលនៅកន្លែងរបួសដែលមានឈាមហូរចេញមកដោយឈឺផ្សាទាំងទឹកភ្នែកហូររហាមយ៉ាងកម្សត់ជាទីបំផុត។ (សូមបញ្ជាក់ថា វែកឆាសម័យនោះធំណាស់ដែលគេយកចបដីកចាស់ៗយកទៅលត់នឹងភ្លើងដំឲ្យសំប៉ែត រួចយកមកប្រើសម្រាប់ដួសបាយសម្លហើយស្លាកស្នាមដំបៅរបួសក្បាលមានដល់សព្វថ្ងៃនេះ)។

ខ្ញុំអស់សង្ឃឹមដើរតម្រង់ទៅផ្ទះទាំងការស្រេកឃ្លាន និងភាពឈឺផ្សារបួសក្បាលខ្លោកៗមានឈាមហូរមកក្រហមច្រាល។



រូបគំនូរ៖ មេចុងភៅរោងបាយវាយក្បាលខ្ញុំនឹងវែកឆា ធ្វើពីចបដីក ដោយសារខ្ញុំលួចបាយក្តាំងហូប។ (ឡុង វង្សសមិទ្ធ/សៀវភៅទួលពិឃាដ)

មកដល់ផ្ទះ បងស្រីរង់ចាំប្អូនយ៉ាងអន្ទះសា។ គាត់ស្ទុះពីកាំជណ្ដើរមករកខ្ញុំ ហើយពោលថា "ថ្ងៃនេះចាំគោយូរម្ល៉េះ ប្អូនហូបបាយហើយឬនៅ?"។ ខ្ញុំខំទប់ទឹកភ្នែកមិនឲ្យហូររួចងក់ក្បាលជាសញ្ញាថារួចរាល់ហើយ។ នេះគ្រាន់តែជាពាក្យភូតលាក់ការពិត ដើម្បីឲ្យបងស្រីស្ងប់អារម្មណ៍សោកសៅអាណិតប្អូនតែប៉ុណ្ណោះ។ បន្ទាប់មកបងស្រីក៏ដឹកដៃខ្ញុំទៅផ្ងូតទឹកអណ្ដូងដូចសព្វមួយដង។

បងស្រីជ្រមុជដងថ្នឹងឫស្សីនឹងធុងធ្លុះធ្លាយចូលក្នុងអណ្ដូង ដើម្បីទាញយកទឹកមកស្រោចលើប្អូនដែលមានសុទ្ធតែភក់ ដៃជើងប្រេះស្រកា សក់រីងកន្ទ្រើង។ ខ្ញុំខំយកដៃខ្ទប់ក្បាលកន្លែងរបួសនឹងវែកឆាកុំឲ្យបងស្រីដឹង។ វាពិតជាឈឺពិតផ្សាណាស់ ទឹកអណ្ដូងរដូវរំហើយមហាត្រជាក់ប៉ះនឹងរបួស តែខំទ្រាំធ្វើដូចធម្មតា។

រួចរាល់ហើយបងស្រីដឹកដៃមកផ្ទះ រួចចូលទៅលូនក្រាបដេកលើកន្ទេលស្លឹកត្នោតកញ្ចាស់ធ្លុះធ្លាយ។ ខ្ញុំសម្លឹងមើលជីដូនកំពុងត្របោមក្បាលជង្គង់ ដៃកាន់ប្រណាកបុកស្លាម្លូ ទំពាមួយៗ ក្នុងទិដ្ឋភាពក្បាលរាងញ័រៗងាកមកសួរខ្ញុំថា "ចៅវង្សថ្ងៃនេះចាំគោយូរម្ល៉េះ?" ខ្ញុំមិនបានតបទៅគាត់ទេ ដោយខំប្រឹងសម្ងំដេកជាមួយនឹងរបួសឈឺចាប់ខ្លោកៗ និងការស្រេកឃ្លានដែលមិនមានចំណីអាហារក្នុងពោះមួយគ្រាប់សោះតាំងពីព្រឹកមក។ ឡុង វង្សសមិទ្ធ

(តនៅលេខក្រោយ)

# បងប្រុសរបស់ខ្ញុំដែលបាត់ខ្លួន




ហួន ស៊ីម និងប្អូនប្រុសឈ្មោះ ហួន ឆុន។
(អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពង់ឆ្នាំង)





ម្តាយ និងឪពុករបស់ ហួន ស៊ីម ឈ្មោះ ពុត ស៊ុម និង អ៊ូ ផន
(អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពង់ឆ្នាំង)

ខ្ញុំឈ្មោះ ហួន ស៊ីម ភេទស្រី អាយុ៥៥ឆ្នាំ រស់នៅភូមិត្បែង ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់គឺ៖ ទី១) ឈ្មោះ ហួន ផេន ២) ហួន ផល ៣) ហួន យុន ៤) ខ្ញុំ (ហួន ស៊ីម) និង ទី៥) ប្អូនប្រុសឈ្មោះ ហួន ឆុន។

ខ្ញុំគឺជាកូនស្រីតែម្នាក់គត់នៅក្នុងគ្រួសារ ដែលមានឪពុកឈ្មោះ អ៊ូ ផល និង ម្តាយ ឈ្មោះ ពុត ស៊ុម ។ នៅពេលដែលខ្មែរក្រហមកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅក្នុងឃុំទួលខ្ពស់ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ ម្តាយរបស់ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យដាំបន្លែ និងធ្វើចុងភៅ ចំណែកឪពុកខ្ញុំដឹកជញ្ជូនអង្ករ។

ខ្ញុំមិនសូវចងចាំមុខមាត់បងប្រុសច្បាស់ទេ ប៉ុន្តែម្តាយខ្ញុំប្រាប់ថា បងប្រុស មានរូបរាងខ្ពស់ សម្បុរស និងមាឌធំ។ កាលពីឆ្នាំ១៩៧៥ ខ្ញុំមានអាយុប្រហែល៨ឆ្នាំ ខ្ញុំនៅចាំថា ថ្ងៃមួយនៅកងកុមាររបស់បងប្រុសខ្ញុំ អង្គការបានចែកនំអាកោឲ្យម្នាក់មួយ ហើយបងប្រុសរបស់ខ្ញុំក៏ទទួលបានចំណែកមួយដែរ។ បងប្រុសរបស់ខ្ញុំមិនហ៊ានហូបខ្លួនឯងទេ គាត់ទុកចំណែករបស់គាត់ឲ្យមកខ្ញុំ។

ក្រោយមកបងប្រុសរបស់ខ្ញុំឈ្មោះ ហួន ផេន ត្រូវបានអង្គការចាត់តាំងឲ្យទៅរស់នៅកងកុមារដែលនៅឆ្ងាយពីកន្លែងខ្ញុំស្នាក់នៅ។ បន្ទាប់ពីគាត់ទៅរស់នៅកងកុមាររយៈពេល៣ខែ បងប្រុស ហួន ផេន ស្នើសុំអង្គការមកលេងផ្ទះ។ ពេលនោះគឺជាលើកចុងក្រោយដែល ខ្ញុំបានជួបគាត់។ ចាប់តាំងពីពេលនោះមក ខ្ញុំបាត់ដំណឹងរបស់គាត់សូន្យរហូតមកដល់សព្វថ្ងៃ។ នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២២ ខ្ញុំបានជួបអ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយ ខ្ញុំផ្តល់ព័ត៌មាននេះដើម្បីប្រកាសស្វែងរកបងប្រុសរបស់ខ្ញុំ។

ខ្ញុំនៅតែចងចាំនិងនឹករឭកបងប្រុសរបស់ខ្ញុំជាពន់ពេក។ ប្រសិនបើមានបងប្អូនធ្លាប់ស្គាល់ឬមានព័ត៌មានប្រហាក់ប្រហែលនឹងការរៀបរាប់ខាងលើ សូមទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯសារកម្ពុជាដែលមានអាសយដ្ឋានផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេសាបាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬទំនាក់មកនាងខ្ញុំតាមរយៈទូរសព្ទលេខ ០៧១ ៨៨ ៦៥ ០៨៦ ឬ ០៧៨ ៦៩ ៨៣ ៣៣ ដោយក្តីអនុគ្រោះ។ សូមអរគុណ!

រូបក្របមុខ៖
អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម
នៅស្រុកអង្គរជ័យ ខេត្តកំពត។ (ផាត ពន្ទក/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖
កងសិល្បៈខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 266, February 2022 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.